# របាយការណ៍ស្តីពីកម្មវិធី
# កិច្ចប្រជុំសមាជិកសម្ព័ន្ធអង្គការកូសេកាំ
# នៅក្រុងព្រះសីហនុ




**ថ្ងៃទី ១៧-២១ ខែធ្នូ ឆ្នាំ ២០០៤**

**រៀបចំដោយ**

**សម្ព័ន្ធអង្គការកូសេកាំ**

COSECAM

# មាតិកា


ទំព័រ

សេចក្តីសង្ខេប ........................................ ១

សេចក្តីផ្តើម ........................................ ២

## ថ្ងៃទី ១ (ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៤)

កម្មវិធីនៃការបង្ហាញពីលទ្ធផលនៃកម្មវិធីរបស់កូសេកាំ (ដោយកម្មវិធីទាំង៤ផ្នែក) ........................................ ៣

ការបង្ហាញរបស់ អ្នកស្រី កៅ សុខផែត, កម្មវិធីស្រាវជ្រាវ ........................................ ៣

ការបង្ហាញរបស់ លោក អ៊ុំ រតនា, កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ........................................ ៦

ការបង្ហាញរបស់ អ្នកស្រី សៅ សុវិទ្យា, កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្ម ........................................ ៩

ការបង្ហាញរបស់ លោក ទួន វិចិត្រ, កម្មវិធីតស៊ូមតិ ........................................ ១៥

ការបង្ហាញពីបញ្ហាទាក់ទងទៅនឹងបញ្ហាអនុគណៈកម្មការ ដោយ លោក អ៊ុំ រតនា ........................................ ១៧

ការបង្ហាញតាមក្រុមលើវិធីសាស្ត្រដោះស្រាយទាក់ទងទៅនឹងបញ្ហាអនុគណៈកម្មការ ........................................ ១៨

ការបង្ហាញពី មណ្ឌល (Notion of Constituency of NGOs) ដោយលោក John Vijghen ........ ១៩

ការបង្ហាញរបស់កញ្ញា ឃ្លីត សុវណ្ណារី លើការតស៊ូមតិ ........................................ ២១

ការបង្ហាញរបស់ក្រុមពិភាក្សា ........................................ ២៤

## ថ្ងៃទី ២ (ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៤)

ការពិភាក្សាតាមក្រុម ........................................ ២៧

ការបង្ហាញពីលទ្ធផលកិច្ចពិភាក្សារបស់ក្រុមពិភាក្សា ........................................ ២៧

ក្រុមទី១: ផ្នែកផ្តល់ជំរក ........................................ ២៧

ក្រុមទី២: ការគាំទ្រផ្នែកច្បាប់ ........................................ ២៨

ក្រុមទី៣: ផ្នែកសិទ្ធិមនុស្ស ........................................ ២៨

ការផ្តល់ការអធិប្បាយរបស់លោក ទួន វិចិត្រ ទៅលើការបង្ហាញរបស់ក្រុមទាំង ៣ ........................................ ២៩

ការធ្វើការបោះឆ្នោត ដើម្បីសំរេចលើទំរង់ប្រព័ន្ធសមាជិកភាព ........................................ ៣១

ការបង់ថ្លៃវិភាគទានរបស់សមាជិកភាព ........................................ ៣២

ការដាក់ពាក្យសុំចូលជាសមាជិកភាព ........................................ ៣២

ការបង្ហាញរបស់អង្គការដែលសុំចូលជាសមាជិក ........................................ ៣៣

អង្គការអភិវឌ្ឍន៍កុមារ និងជនពិការកម្ពុជា (CCHDO) ........................................ ៣៣

អង្គការកុមារកម្ពុជានៃក្ដីសង្ឃឹម (CHO) ........................................ ៣៥

អង្គការអនាគតកុមារ ANAKOT KUMAR (AK) ........................................ ៣៦

អង្គការកុមារឥតព្រំដែន (KnK) ........................................ ៣៨

អង្គការកុមារនៃក្ដីសង្ឃឹម (KNKS) ........................................ ៣៩

ការធ្វើការសំរេចចិត្តចំពោះអង្គការដែលបានដាក់ពាក្យសុំចូលជាសមាជិក ........................................ ៤៤

## ថ្ងៃទី ៣ (ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៤)

ការបញ្ជាក់របស់លោក John ពីសកម្មភាពរបស់សម្ព័ន្ធកូសេកាំ ........................................ ៤៧

ការសម្របសម្រួលពិភាក្សាលើផែនការកម្មវិធីសំរាប់ឆ្នាំ ២០០៥ ដោយលោក អ៊ុំ រតនា ........................................ ៤៩

ការបង្ហាញរបស់ក្រុមពិភាក្សាលើកម្មវិធីសំរាប់ឆ្នាំ ២០០៥ ........................................ ៤៩

ក្រុមអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ........................................ ៤៩

ក្រុមការងារតស៊ូមតិ ........................................ ៥១

ក្រុមស្រាវជ្រាវ ........................................ ៥២

ក្រុមការស្ដារនីតិសម្បទា និងសមាហរណកម្មទៅក្នុងសហគមន៍ ........................................ ៥៣

ការបិទកម្មវិធីដោយលោក ទូន វិចិត្រ ........................................ ៥៤

បញ្ជីឈ្មោះអ្នកចូលរួមក្នុងសិក្ខាសាលាប្រចាំឆ្នាំ ........................................ ៥៥

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ A: ការវិភាគស្ដីពីកម្មវិធី សំរាប់កិច្ចប្រជុំសមាជិកសម្ព័ន្ធអង្គការកូសេកាំ នៅក្រុងព្រះសីហនុ

ឧបសម្ព័ន្ធ B: សញ្ញាណអំពី មណ្ឌល សំរាប់អង្គការក្រៅរដ្ឋាភិបាល

ឧបសម្ព័ន្ធ C: Discussion Paper on COSECAM Program from Year 2005 onwards

# សេចក្តីសង្ខេប

នៅថ្ងៃទី ១៧-២១ ខែធ្នូ ឆ្នាំ២០០៤ សម្ព័ន្ធកូសេកាំ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ (Annual Retreat) នៅសណ្ឋាគារប្រាសាទមាស ក្រុងព្រះសីហនុ ដោយមានអ្នកចូលរួមមកពីសមាជិកសម្ព័ន្ធទាំងអស់ចំនួន ១៨ និង សមាជិក ដែលដាក់ពាក្យសុំចូលថ្មីចំនួន ៥ ដើម្បីធ្វើការពិភាក្សា និងធ្វើការសរុបលទ្ធផលលើកម្មវិធីឆ្នាំកន្លងមក និងផែនការថ្មីសំរាប់ឆ្នាំ ២០០៥។ លទ្ធផលដែលទទួលបានតាមរយៈការប្រជុំមានដូចខាងក្រោម:

## ➲ កម្មវិធី ២០០៥ បានអនុម័តដោយសមាជិកចូលរួម

- កម្មវិធីតស៊ូមតិនៅក្នុងកម្មវិធីនេះកម្មវិធីទាំងអស់ត្រូវបានរក្សាទុក ហើយបន្ថែមនូវបញ្ហាសំខាន់ពីរបន្ថែមទៀតគឺ បញ្ហាពេស្យាចារ និងសិទ្ធិអំណាចក្នុងការគ្រប់គ្រងកុមារ (Child Custodianship Rights)
- កម្មវិធីស្រាវជ្រាវនៅក្នុងកម្មវិធីនេះ កម្មវិធីភាគច្រើនត្រូវបន្តពីឆ្នាំចាស់
- កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្សនៅក្នុងកម្មវិធីនេះ កម្មវិធីចាស់ត្រូវបានបន្ត ហើយមានបន្ថែមកម្មវិធីមួយទៀតគឺ ការធ្វើគំរោងពង្រឹងសមត្ថភាពបុគ្គលិកអង្គការជាសមាជិក (Capacity Building Planning)
- កម្មវិធីស្តារនិតិសម្បទា និង សមាហរណកម្ម នៅក្នុងកម្មវិធីនេះគឺបន្តកម្មវិធីពីឆ្នាំចាស់

## ➲ អនុគណៈកម្មាការ

អង្គប្រជុំបានសំរេចរក្សាទុកចំនួនអនុគណៈកម្មាការអោយនៅដដែល ដោយចំនួនសមាជិកក្នុងអនុគណៈកម្មាការនីមួយៗ មានពី ៥ ទៅ ៧ នាក់។

## ➲ ឋានៈនៃសមាជិកភាព

សមាជិករបស់សម្ព័ន្ធអង្គការ កូសេកាំ ត្រូវបានបែងចែកជាពីរប្រភេទ:

- សមាជិកសកម្ម (Active Member)
- សមាជិកបំរុង (Associate Member)

សមាជិកថ្មីនៃអង្គការចំនួន ៥ គឺ CCHDO, CHO, AK, KnK, និង KNKS ត្រូវបានសមាជិកចូលរួមឯកភាពអោយចូលរួមជាសមាជិកបំរុងសំរាប់រយៈពេល៦ខែសិន ដើម្បីពិនិត្យមើលការអនុវត្តន៍របស់គេ បន្ទាប់មកទើបសំរេចចិត្តថា តើគេអាចចូលជាសមាជិកពេញសិទ្ធិប្រភេទណា។ ដោយឡែកអង្គការ KnK អាចចូលត្រឹមតែជាសមាជិកបំរុង តែប៉ុណ្ណោះ ព្រោះជាអង្គការអន្តរជាតិ ។

ចំណែកសំណើរការកសាងសមត្ថភាពរយៈពេលពីរឆ្នាំ សំរាប់អង្គការទាំងអស់ជាសមាជិកនឹងរៀបចំឡើងបន្ទាប់ពី ការប៉ាន់ប្រមាណតំរូវការបណ្តុះបណ្តាល (Training Need Assesment)។ សំណើរនេះនឹងផ្តល់មូលនិធិដោយអង្គការ KIA, Netherlands ។

## សេចក្តីផ្តើម

នៅថ្ងៃទី ១៧-២១ ខែធ្នូ ឆ្នាំ ២០០៤ អង្គការកូសេកាំបានរៀបចំអោយមានកិច្ចប្រជុំ (Coalistion Member's Retreat) នៅសណ្ឋាគាប្រាសាទមាស ក្រុងព្រះសីហនុ ដោយមានអ្នកចូលរួមមកពីសមាជិកសម្ព័ន្ធទាំងអស់ចំនួន ១៨ និងសមាជិកដែលដាក់ពាក្យសុំចូលថ្មីចំនួន ៥ ដើម្បីធ្វើការពិភាក្សា និងធ្វើការសរុបលទ្ធផលលើផែនការចាស់ដើម្បីរកវិធីសាស្ត្រ និងដំណោះស្រាយសំរាប់ផែនការថ្មីដែលត្រូវអនុវត្តឆ្នាំ ២០០៥ ដោយធ្វើយ៉ាងណាអោយមានប្រសិទ្ធិភាព។ ក្រៅពីនេះអង្គការបានរៀបចំអោយមានកិច្ចពិភាក្សាពីសមាជិកភាពការបង្ហាញរបស់អង្គការដែលដាក់ពាក្យសុំចូលថ្មី និងការចូលជាសមាជិកថ្មីរបស់អង្គការដែលដាក់ពាក្យសុំ។ ចំនុចពិសេសមួយទៀតដែលអង្គការកូសេកាំចង់បង្ហាញនោះគឺ ការផ្តល់ការហ្វឹកហ្វឺនអំពីសញ្ញាណនៃមណ្ឌលរបស់អង្គការសង្គមស៊ីវិល (NOTION OF CONSTITUENCY OF NGOs) និងមានការបង្ហាញពីគំនិតថ្មីៗ ដែលទទួលបានពីការចូលរួមសន្និសីទរបស់លោក ទូន វិចិត្រ និង លោក John នៅប្រទេសថៃក្នុងពេលថ្មីៗនេះ។

## ថ្ងៃទី ១ (ថ្ងៃ ទី ១៨ ខែធ្នូ ឆ្នាំ ២០០៤)

(សកម្មភាពលំអិតប្រចាំថ្ងៃ សូមមើលឧបសម្ព័ន្ធ A)

បន្ទាប់ពីអ្នកចូលរួមបានមកជួបជុំគ្នាហើយ លោក ទូន វិចិត្រ អ្នកសំរបសំរួលសម្ព័ន្ធអង្គការកូសេកាំបានធ្វើការគោរពដល់អ្នកចូលរួមទាំងអស់ ហើយលោកក៏បានប្រកាសបើកកម្មវិធីនៃអង្គប្រជុំ។ លោកបានបញ្ជាក់ពីប្រវត្តិខ្លះៗរបស់សម្ព័ន្ធអង្គការកូសេកាំ ដូចជាសម្ព័ន្ធត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០១ ដោយមានការផ្តួចផ្តើមពីសំណាក់អង្គការធំៗ ដែលបច្ចុប្បន្នជាគណ:កម្មការនាយករបស់ កូសេកាំ ដូចជា ADHOC, CDP, CWCC ជាដើម ហើយលោកក៏បានជំរាបពីហេតុផលក្នុងការបង្កើតជាសម្ព័ន្ធនេះគឺ ដើម្បីពង្រឹងការងារអោយមានភាពកាន់តែខ្លាំងក្លា ព្រោះអង្គការមួយតែឯងមិនមានកំលាំងរឹងមាំនោះទេ វាហាក់បីដូចជាចង្កឹះនោះដែរ។ ហេតុដូចនេះគំនិតនៃការបង្កើតជាសម្ព័ន្ធ នេះក៏បានកើតឡើង។ ការចូលជាសម្ព័ន្ធនេះ ជាដំបូងមានអង្គការចំនួនតែ ៣ ប៉ុណ្ណោះហើយបន្ទាប់មកកើនដល់ចំនួនពី ៣-៥-៧-១០-១៥ ហើយក្រោយមកទៀត កើនដល់ ១៨ អង្គការ ហើយជាពិសេសនៅថ្ងៃនេះយើងមានបេក្ខជនចំនួន ៥អង្គការ ទៀតដែលបានមកដាក់ពាក្យសុំចូលជាសមាជិក។ ប្រវត្តិសកម្មភាពការងាររបស់អង្គការគឺ ការងាររបស់អង្គការចេះតែរីកចំរើនឡើងជាលំដាប់នៅក្នុងគ្រប់កម្មវិធី ហេតុដូចនេះហើយម្ចាស់ជំនួយមានការកោតសសើរ និងទុកចិត្តហើយគេបានបង្កើនជំនួយរហូតដល់ជិត ៤០០ ០០០ ដុល្លាហើយនៅពេលក្រោយនេះ យើងបានរៀបគំរោងបង្កើនថវិកាជិតដល់ទៅ ៦០០ ០០០ ដុល្លាសំរាប់ឆ្នាំ ២០០៥។ ចំពោះការអនុវត្តន៏ការងារវិញ ថ្វីបើការងារមានដំណើរការល្អ ក៏នៅមានផលវិបាកមួយចំនួនដែលអង្គការ និង

សមាជិកបានជួបប្រទះដូចជាការ ចូលរួបប្រជុំរបស់សមាជិកមិនបានទៀងទាត់ ព្រោះគាត់មានបណ្តាញជាមួយការងារច្រើនពេក ហើយគាត់រវល់ និងការងារស្មុលរបស់គាត់ទៀត និងការលំបាកក្នុងការសំរបសំរួលរបស់អនុគណៈកម្មការ ។ នៅក្នុងសម្ព័ន្ធនេះ យើងបានបង្កើតអោយមានអនុគណៈកម្មការចំនួន ៤ គឺ អនុគណៈកម្មការការតស៊ូមតិ, អនុគណៈកម្មការស្រាវជ្រាវ, អនុគណៈកម្មការស្តារនីតិសម្បទា និងសមាហរណកម្ម, និងអនុគណៈកម្មការអភិវឌ្ឍន៏ស្ថាប័ន និងធនធានមនុស្ស ។ សំខាន់នៅពេលនេះគឺ យើងត្រូវធ្វើការពិភាក្សាពីអនុគណៈកម្មការទាំងនេះថា តើយើងត្រូវរក្សាទុកអនុគណៈ កម្មការណាខ្លះ? ហើយអនុគណៈកម្មការណា ដែលមានសន្ទុះខ្លាំងជាងគេ?

ក្រៅពីនោះ យើងនិងធ្វើការពិភាក្សាពីការចូលជាសមាជិក ថាតើពួកគេត្រូវចូលជាសមាជិកធម្មតា ឬសមាជិកសកម្ម ។ ការធ្វើបែបនេះគឺ ដើម្បីសំរួលដល់ការប្រជុំ និងធ្វើសេចក្តីសំរេចផ្សេងៗ ។ ចំនុចមួយទៀត ដែលយើងត្រូវធ្វើការពិភាក្សាដែរគឺ ពាក្យថាមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល (Notion of Constituency of NGOs) ។ គោលបំណងសំខាន់គឺ ផ្តោតទៅលើការអនុវត្តកម្មវិធីរបស់យើង តើយើងធ្វើយ៉ាងដូចម្តេចដើម្បីកែលំអកម្មវិធីរបស់យើង ជាពិសេសទាក់ទងទៅនឹងក្រុមគោលដៅរបស់យើង ។

បន្ទាប់មកគឺ ការបង្ហាញ និងការពិនិត្យទៅលើការសំរេចបានរបស់កម្មវិធី ដែលបង្ហាញដោយអ្នកសំរបសំរួល និងបុគ្គលិកកូសេកាំ ដោយអនុញ្ញាតអោយមានការចោទសួរជាសំនួរទៅលើចំនុចមួយចំនួន ដែលមានភាពមិនច្បាស់លាស់ ។

## កម្មវិធីនៃការបង្ហាញពីលទ្ធផលនៃកម្មវិធីរបស់សម្ព័នអង្គការកូសេកាំ

### ការបង្ហាញរបស់ អ្នកស្រី កៅ សុខម៉ែត

### កម្មវិធីស្រាវជ្រាវ (Research Program)

**គោលបំណង:** ប្រមូលផ្តុំពតិមានស្តីពីការជួញដូរផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា និងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការវាយតំលៃពីស្ថានភាពបញ្ហា និងរកដំណោះស្រាយមួយសមស្របនិងមានប្រសិទ្ធភាព ។ កម្មវិធីនេះគឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីទាំង ៤ ហើយមានគោលបំណងដើម្បីរកដំណោះស្រាយ និងរកវិធីទប់ស្កាត់ការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទកុមារ ។ ក្នុងកម្មវិធីនេះ មានប្រធានបទសំខាន់ៗ ៣ គឺ:

- ការប៉ាន់ប្រមាណពីសមត្ថភាពអង្គការក្នុងស្រុក
- ការសិក្សាពីកត្តាតំរូវការរបស់កុមារ
- ការវិភាគពីស្ថានភាពនៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

**សកម្មភាព:**

## ១. ការប៉ាន់ប្រមាណពីសមត្ថភាពរបស់អង្គការក្នុងស្រុកៈ

ប្រមូលទិន្នន័យពីអង្គការក្នុងស្រុក ទាក់ទងទៅនឹងការកេងប្រវ័ញ្ច និងការជួញដូរកុមារ ។

**លទ្ធផលសសង្ឃឹមទុក** : ថានឹងបានទិន្នន័យពេញលេញ

**លទ្ធផលទទួលបាន** : បានទទួលទិន្នន័យពីអង្គការចំនួន ១៦ គឺ: Wathnakpheap, CCPCR, PJJ, Damnok Teuk / Goutte d’Eau-Cambodia, CRF, CWCC, CDP, CAMP, CWDA, ADHOC, SKK, HCC, LSCW, KMR CCASVA, PTD

**បញ្ហាជួបប្រទះ :**

- អង្គការមួយចំនួនតូចមិនផ្តល់កិច្ចសហការណ៍
- អង្គការមួយចំនួនមិនបានបំពេញពតិមានគ្រប់គ្រាន់តាមទំរង់សំនួរ
- មានការយឺតយ៉ាវក្នុងការផ្ញើរទំរង់សំនួរត្រលប់មក កូសេកាំវិញ

**ការសិក្សាពីការគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាកុមារ**

**លទ្ធផលទទួលបាន** : ទទួលបានរបាយកាណ៏រចុងក្រោយ និងអនុសាសន៏រួមមួយ ហើយបានធ្វើការបង្ហាញជូនអង្គ សិក្ខាសាលានិងវេទិកាតុមូល ។

**លទ្ធផលរំពឹងទុក** : នឹងបានអនុសាសន៏ដ៏ប្រសើរមួយសំរាប់អង្គការនានាធ្វើសកម្មភាពទៅមុខឱ្យមានប្រសិទ្ធិភាព ។

**បញ្ហាជួបប្រទះ** : មិនសូវមានការសហការពីអង្គការនានា ។

## ២. ការសិក្សាពីកត្តាតំរូវការរបស់កុមារ

**សកម្មភាពទី ១** : **ទស្សនៈវិស័យរបស់កុមាររងគ្រោះដោយការជួញដូរផ្លូវភេទ**

**លទ្ធផលរំពឹងទុក** : នឹងទទួលបានមតិយោបល់កុមាររងគ្រោះដោយការជួញដូរ ។

**លទ្ធផលទទួលបាន** : ទទួលបានពតិមានជាមូលដ្ឋានចំនួន ៥ ខេត្ត និងបានចងក្រងជាឯកសារសំរាប់ធ្វើការវិភាគ ។

**បញ្ហាជួបប្រទះ :**

- អង្គការមួយចំនួនមិនសូវធ្វើការសហការ ។
- ការណែនាំអង្គការសំរាប់ធ្វើការសំភាសមិនចំគោលដៅ ពោលគឺមិនចំកុមារដែលរងគ្រោះពិត ។
- មណ្ឌលមួយចំនួនទាមទាអោយមានសំភារៈលើកទឹកចិត្តកុមារ ។

| | | |
|---|---|---|
| **សកម្មភាពទី ២** | : | **ទស្សនវិស័យរបស់អ្នកធ្វើការជាមួយកុមាររងគ្រោះ** |
| **លទ្ធផលទទួលបាន** | : | ពង្រាងរបាយការណ៏ត្រូវបានបញ្ចប់ តែមិនទាន់បានបោះពុម្ព។ |
| **លទ្ធផលរំពឹងទុក** | : | ថានឹងទទួលបានទិន្នន័យពិតមួយស្តីពីមូលហេតុដែលនាំអោយមានការជួញដូរ |
| **បញ្ហាជួបប្រទះ** | : | ពិបាកទាក់ទងជាមួយអ្នកធ្វើការថែទាំកុមារ។ |

## ៣. ការវិភាគពីស្ថានភាពការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ

**គោលបំណង:** មានគោលបំណងដើម្បីប្រមូលទិន្នន័យសំរាប់ធ្វើការវាយតំលៃនិងធ្វើការរិះរកវិធីសាស្ត្រសំរាប់ដោះស្រាយអោយមានប្រសិទ្ធភាព។

| | | |
|---|---|---|
| **សកម្មភាព** | : | **ប្រមូលទិន្នន័យនិងឯកសារដែលពាក់ពន្ធ័។** |
| **លទ្ធផលរំពឹងទុក** | : | របាយការណ៏ស្តីពីការវាយតំលៃនឹងត្រូវបានចងក្រងឡើង។ |
| **លទ្ធផលទទួលបាន** | : | បានប្រមូលទិន្នន័យមួយចំនួន តែមិនទាន់មានលក្ខណៈគ្រប់គ្រាន់សំរាប់ចងក្រងនៅឡើយ |
| **បញ្ហាជួបប្រទះ** | : | ខ្វះប្រភពទិន្នន័យ |

## វេទិការសំនួរចំលើយ

### Q. តើលទ្ធផលនៃការស្រាវជ្រាវនោះទទួលបានទាំងអស់ដែររឺទេ? (លោក សាក់)

យើងបានប្រមូលទិន្នន័យហើយ តែមិនទាន់បានយកមកវិភាគ។ ការសិក្សានោះមានភាពមិនច្បាស់លាស់ល្អដោយសារការចុះទៅជួបសំភាសផ្ទាល់មិនបានជួបជាមួយកុមារដែលទទួលរងគ្រោះពិតប្រាកដ ហើយថវិការប្រើប្រាស់មិនបានគ្រប់គ្រាន់តាមតំរូវការជាក់ស្តែង និងម្ចាស់ជំនួយតែងតែចង់បានគំរោងណា ដែលចេញជាលទ្ធផលជាក់ស្តែងផ្ទាល់តែម្តង។ ម្យ៉ាងទៀតមានបុគ្គលិកខ្លះគាត់ចុះធ្វើការតែពាក់កណ្តាលពេល និងមានបុគ្គលិកជំនាញការធ្វើការមិនពេញម៉ោង (ធ្វើការតែក្នុងរយៈពេល ៣ ថ្ងៃ ក្នុងមួយខែ)។

### Q. តើការប្រមូលទិន្នន័យយកមកចងក្រងជាឯកសារនេះគឺ មានគោលបំណងដូចម្តេច?

- ដើម្បីធ្វើការវិភាគពីសភាពការណ៏របស់អង្គការនិមួយៗថា តើអង្គការនិមួយៗបានធ្វើសកម្មភាពសមស្របដែររឺទេ។
- ធ្វើការវាយតំលៃពីសកម្មភាពនៃការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិក ហើយសម្ព័ន្ធកូសេកាំ អាចកំនត់សកម្មភាពណាមួយសំរាប់ជួយដល់បុគ្គលិកបណ្តាញ។

- ធ្វើការស្រាវជ្រាវសំរង់ពត៌មានដើម្បីធ្វើការវិភាគពីស្ថានភាពថា តើស្ថានភាពនៃការជួញដូរឈាន ដល់កំរិតណាហើយ?
- អនុវត្តកម្មវិធី RAINBOW PROGRAMME : គឺដើម្បីបំពេញចន្លោះ និងជួយរកវិធីសំរាប់ ដោះស្រាយបញ្ហាទាំងឡាយណាដែលបុគ្គលិកសម្ព័ន្ធមិនអាចធ្វើបាន។

**Q. តើអង្គការមួយចំនួនមិនបានផ្តល់កិច្ចសហការណ៍ទៅលើចំនុចអ្វីខ្លះ?**

- បំពេញទំរង់សំនួរដែលអង្គការយើងបានស្នើរសុំ
- អង្គការមួយចំនួនបំពេញទំរង់សំនួរមិនបានគ្រប់ជ្រុងជ្រោយ

**Q. តើទៅថ្ងៃអនាគតសម្ព័ន្ធអង្គការមានគំរោងដូចម្តេច? តើសម្ព័នអង្គការកូសេកាំ ប្រមូលពត៌មានតែអង្គការ ១៦ នេះ រឺយ៉ាងណា?**

- យើងធ្វើតែអង្គការណា ដែលធ្វើសកម្មភាពទាក់ទងទៅនឹងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទតែប៉ុណ្ណោះ

**Q. តើលទ្ធផលដែលទទួលបាន អង្គការគួរតែដាក់អោយបណ្តាញជួយត្រួតពិនិត្យ និងកែសំរួលដែរឺទេ?**

- យើងធ្វើតែចំពោះអង្គការសមាជិក ហើយលទ្ធផលដែលទទួលបានយើងនឹងដាក់អោយសមាជិកទាំង អស់ជួយពិនិត្យវិញបន្ទាប់ពីបានចងក្រងរួចហើយ។ បន្ទាប់មកយើងធ្វើសិក្ខាសាលា និងពិភាក្សារក ចំនុចកែលំអរ ហើយបើមានការប៉ះពាល់ខ្លាំង អង្គការយើងនឹងផ្ញើរទៅសាមុីអង្គការធ្វើការកែលំអរ ជាចុងក្រោយ។

## ការបង្ហាញរបស់លោក អ៊ុំ រតនា

## កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD Program)

## ១. កម្មវិធី Rainbow និងយុទ្ធសាស្រ្តសំរាប់បង្កើតគំរោង

ចំពោះកម្មវិធីនេះ សម្ព័ន្ធអង្គការកូសេកាំបានធ្វើសកម្មភាពដូចខាងក្រោមនេះ :

១.១ ការប្រមូលពត៌មាននិងប៉ាន់ប្រមាណពីសកម្មភាពអង្គការសមាជិកទាំង ១៨អង្គការ ដើម្បីរកឱ្យ ឃើញថា តើអង្គការនិមួយៗមានកម្មវិធីនិងវិធីសាស្រ្តអ្វីខ្លះ ដែលទាក់ទងទៅនឹងការទប់ស្កាត់ ការការពារ និងការស្តារនីតិសម្បទា និងសំរាប់អនុវត្តការងារអោយមានប្រសិទ្ធិភាព ពិសេសទៅ លើកិច្ចការពារ និងការទប់ស្កាត់ការជួញដូរ និងការធ្វើសមាហរណកម្មកុមារទៅក្នុងសង្គម។ ក្រោយពេលដែលយើងប្រមូលពត៌មានបានហើយ យើងធ្វើការវិភាគ និងរកវិធីសាស្រ្តសំរាប់ ដោះស្រាយបញ្ហាទាំងនោះអោយមានប្រសិទ្ធិ។

១.២ ធ្វើយុទ្ធនាការទស្សនកិច្ច នៅជុំវិញបឹងទន្លេសាបដែលមានរយៈពេល ៨ថ្ងៃ (២១-២៨) ខែឧសភា ឆ្នាំ ២០០៤ ដែលមានអ្នកចូលរួមទាំងអស់ប្រហែលជា ១១០នាក់ មកពីអង្គការនានា និងស្ថាប័នរដ្ឋ។ ការធ្វើទស្សនកិច្ចនេះមានគោលបំណងសំខាន់គឺ ការចុះពិនិត្យមើលពីសកម្មភាពដែលអង្គការបានធ្វើ និងដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

១.៣ ការធ្វើសិក្ខាសាលានៅក្នុងខេត្តចំនួន ១៣ ដែលនៅក្នុងនោះមានខេត្តចំនួន ៨ យើងបានធ្វើតាមដំណើរទស្សនៈកិច្ច ហើយយើងបានអញ្ជើញអ្នកចូលរួមពីគ្រប់មជ្ឈដ្ឋាន តាំងពីប៉ូលីស មន្ត្រីសំខាន់ៗរបស់រដ្ឋាភិបាល គ្រូបង្រៀន ក្រសួងសង្គមកិច្ច កិច្ចការនារី ស្ថាប័នអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត និងជនរងគ្រោះ។ ការធ្វើបែបនេះគឺយើងធ្វើ ដើម្បីរកការពិតអោយឃើញ និងដើម្បីបានពត៌មានមួយដែលអាចទុកចិត្តបាន។

១.៤ សិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមាររងគ្រោះ : យើងមានធ្វើសិក្ខាសាលាជាបន្តបន្ទាប់គ្នាជាមួយកុមាររងគ្រោះ ពិសេសកុមារដែលត្រូវគេយកទៅលក់នៅប្រទេសថៃ និង ម៉ាឡេស៊ី។

១.៥ ការធ្វើសិក្ខាសាលានៅខេត្តសៀមរាប ដែលមានកុមារចំនួន ២១ នាក់បានចូលរួម។ សិក្ខាសាលានេះគឺយើងធ្វើឡើងដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងចង់ដឹងថា តើអង្គការទាំងនោះគេបានធ្វើសកម្មភាពអ្វីខ្លះសំរាប់ជួយជនរងគ្រោះ? ហើយធ្វើយ៉ាងណាដើម្បីទប់ស្កាត់បញ្ហាទាំងនោះ។ តើអង្គការនិងរដ្ឋាភិបាលបានធ្វើអ្វីខ្លះដើម្បីជួយពួកគេ និងចង់ដឹងថា តើពួកគេចង់បានអ្វី ហើយយើងជួយដោយរបៀបណា។

១.៦ ការធ្វើសិក្ខាសាលានៅទីក្រុងភ្នំពេញ : សិក្ខាសាលានេះត្រូវបានធ្វើឡើងឡើងនៅមុនសន្និសីទជាតិដោយមានការចូលរួមពីកុមារ ដែលបានគេចផុតពីការជួញដូរកំលាំងពលកម្ម និងការជួញដូរផ្លូវភេទ។ មានកុមារចូលរួមមកពីមណ្ឌលចំនួន ៧ ដែលមានកុមារទាំងអស់មានចំនួន ៣៦ នាក់ ។ នៅក្នុងសិក្ខាសាលានេះ កុមារទាំងអស់បានលើកឡើងពីការព្រួយបារម្ភរបស់ពួកគេ និងអាចលើកជាសំណូមពរដល់អង្គការស្ថាប័ននានាអោយជួយទៅតាមអ្វីដែលគេចង់បាន។

១.៧ សន្និសីទជាតិ : កម្មវិធីនេះរៀបចំឡើងដោយសម្ព័ន្ធកូសេកាំ សហការជាមួយអង្គការអ៊ិកផាត-កម្ពុជា ដែលមានអ្នកចូលរួមមកពីគ្រប់មជ្ឈដ្ឋាន ព្រមទាំងមានកុមារដែលរងគ្រោះមកចូលរួមពិភាក្សា និងធ្វើជាសំណូមពរផ្ទាល់ដល់អ្នកដែលគេចង់អោយជួយផងដែរ។ សិក្ខាសាលានេះគឺ ធ្វើឡើងដើម្បីធ្វើការពិភាក្សាលើយុទ្ធសាស្ត្រដែលបានប្រើកន្លងមកថា តើវាមានប្រសិទ្ធិភាពដល់កំរិតណា? ក្រុមកុមាររងគ្រោះមានការពេញចិត្តហើយឬនៅ? ម្យ៉ាងទៀតសន្និសីទនេះគឺ ធ្វើឡើងដើម្បី

រកយុទ្ធសាស្ត្រល្អៗបន្ថែមទៀតសំរាប់យកទៅអនុវត្តនៅក្នុងផែនការជាតិ ៥ឆ្នាំ ២០០៥-២០០៩ ខាងមុខ។

## ២. ការធ្វើទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍តាមមណ្ឌលផ្សេងៗ

ធ្វើឡើងដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងគំនិតយោបល់ដើម្បីយកទៅអនុវត្តសំរាប់កម្មវិធីរបស់ខ្លួន។

## ៣. កិច្ចប្រជុំក្រុមពិភាក្សា និងវគ្គផ្តល់ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រសង្គម

ធ្វើឡើងដើម្បីអោយដឹងថា តើអង្គការនិមួយៗធ្វើការផ្តល់ការប្រឹក្សាយោបល់អោយអតិថិជនរបស់គេដូចម្តេច ហើយនឹងអោយដឹងថា តើទៅអនាគតត្រូវផ្តល់ការគាំទ្រដល់ពួកគេដូចម្តេច។

## ៤. ការផ្តល់ការបណ្តុះបណ្តាលពីការចាត់ចែងសំរបសំរួល

យើងបានធ្វើការផ្តល់ការអប់រំចំនួន ៤វគ្គ

- វគ្គធ្វើគំរោង និងការត្រួតពិនិត្យគំរោង
- វគ្គបង្កើនការយល់ដឹងពីយេនឌ័រ
- វគ្គចាត់ចែងនិងគ្រប់គ្រងខួបគំរោង
- វគ្គសិក្សាពីការធ្វើរបាយការណ៍សំរាប់ធ្វើការតស៊ូមតិ

## ៥. វេទិកាជួបជុំគ្នារបស់បុគ្គលិកមណ្ឌលនៅក្នុងទីក្រុងភ្នំពេញ

មានការជួបជុំគ្នារៀងរាល់ខែរបស់បុគ្គលិក ដើម្បីបន្តធ្វើការពិភាក្សាលើការពិពណ៌នាពីមុខតំណែងចំនួន ៩ របស់មណ្ឌល។

## ៦. កិច្ចប្រជុំផ្សេងៗទៀត

**ការបង្កើតច្បាប់បទបញ្ជាសំរាប់កុមារនៅតាមមណ្ឌលៈ** មន្ត្រីកម្មវិធីនេះតែងតែទៅចូលរួមកិច្ចប្រជុំជាច្រើនជាមួយ Unicef ដើម្បីធ្វើការកំនត់បទដ្ឋានអប្បបរិមាសំរាប់សហគមន៍ ដូចជាការមើលថែរក្សាកុមារនៅតាមផ្ទះតាមវត្តអារាមជាដើម។

## សេចក្តីសន្និដ្ឋាន

ជាទូទៅកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ៩០% បានទទួលជោគជ័យ បើគិតពីការធ្វើសកម្មភាព, ការចាត់ចែងធនធាន និងបានធ្វើសកម្មភាពបានចប់តាមកាលកំនត់។ លទ្ធផលទាំងនេះគឺ ជាលទ្ធផលដែលចេញពីអនុគណៈកម្មការ, សហអ្នកសំរបសំរួល និងការសហការគ្នាធ្វើការផ្តល់យោបល់ពីសមាជិករបស់សម្ព័ន្ធអង្គការទាំង ១៨។

## សំនួរនិងចំលើយ

**Q. តាមរបាយការណ៍យើងឃើញសុទ្ធតែជាភាសាអង់គ្លេស ហើយអង្គការយើងសុទ្ធតែជាអង្គការក្នុងស្រុក ហើយបុគ្គលិកមិនអាចមើលយល់នោះទេ តើអង្គការកូសេកាំមានគំរោងធ្វើការបកប្រែដែរទេ?**

អង្គការយើងនឹងធ្វើការបកប្រែនៅពេលក្រោយ ។ ហេតុដែលយើងមានរបាយការណ៍តែជាភាសាអង់គ្លេសនេះ គឺដោយសារយើងប្រមូលពតិមានយឺត ហើយយើងប្រញាប់ផ្ញើរជូនម្ចាស់ជំនួយគេពិនិត្យ ។

**Q. បន្ទាប់ពីប្រមូលទិន្នន័យហើយ តើសម្ព័ន្ធកូសេកាំ បានចុះទៅពិនិត្យ និងតាមដានពីស្ថានភាពផ្ទាល់របស់អង្គការនិមួយៗហើយរឺនៅ?**

- អង្គការយើងមិនទាន់បានធ្វើនៅឡើយទេ ដោយសារពតិមានយើងទើបតែនឹងទទួលបាន ហើយធ្វើការបញ្ចប់ការប្រមូលក្នុងពេលថ្មីៗនេះ និងដោយសារតែយើងទើបតែនឹងធ្វើសន្និសីទជាតិជាចុងក្រោយ តែយើងនឹងធ្វើការចុះតាមដានរាល់សកម្មភាពទាំងនេះនៅឆ្នាំ ២០០៥ ថា តើគេយកសកម្មភាពដែលគេលើកឡើងនោះទៅអនុវត្តដែររឺទេ ហើយនិងទទួលបានលទ្ធផលក៏រិតណា ។
- ឯកសាររបស់កូសេកាំ ត្រូវបានក្រុមប្រឹក្សាដើម្បីកុមារនៅកម្ពុជាយកជាទិន្នន័យសំរាប់ធ្វើការប្រជុំនាទីក្រុងបាងកក និងសំរាប់យកទៅបញ្ចូលទៅក្នុងផែនការជាតិឆ្នាំ ២០០៥-២០០៩ ។

## អនុសាសន៏:

- ពេលធ្វើសិក្ខាសាលាសូមអោយមានការចូលរួមពីសំណាក់តុលាការ មេធាវី និងស្ថាប័នប៉ូលីសដែលពាក់ព័ន្ធចូលរួម ដើម្បីអោយមានការវែកញែកពីហេតុផលអោយបានច្បាស់លាស់ ។
- សូមអញ្ជើញអ្នកដែលមានសិទ្ធិសំរេចចិត្ត រឺអ្នកដែលមានអនុភាពក្នុងការរាយការណ៏ទៅស្ថាប័នកំពូល រឺថ្នាក់លើ ។
- គួរតែដាក់បញ្ចូលរបាយការណ៏នេះទៅក្នុងផែនការរបស់រដ្ឋាភិបាល និងផ្ញើរទៅអង្គការសមាជិកផ្សេងៗ

## ការបង្ហាញរបស់ អ្នកស្រី សៀ សុវិទ្យា

## កម្មវិធីការស្តារនីតិសម្បទា និងសមាហរណកម្មកុមារនៅក្នុងសង្គម

**Rehabilitation & Reintegration Program**

កម្មវិធីនេះមានបីផ្នែកធំៗគឺ:

❖ **ការបណ្តុះបណ្តាលបុគ្គលិកនៅតាមមណ្ឌល**

- ការបណ្តុះបណ្តាលអំពីការប្រឹក្សាពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រសង្គម

- ការបណ្តុះបណ្តាលអំពីការពិនិត្យតាមដានចំពោះកុមារ ដែលបានធ្វើសមាហរណកម្មសំរាប់ភ្នាក់ងារ NGOs

❖ **សេវាកម្មស្តារនីតិសម្បទាកុមារ**

- ត្រូវមានក្រុមប្រឹក្សាយោបល់ចល័ត
- មានក្រុមគ្រូបង្រៀនចល័ត
- ការពិនិត្យតាមដានដានចំពោះកុមារដែលបានធ្វើសមាហរណកម្ម
- មូលនិធិផ្តល់អាហាររូបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈ
- ផ្សព្វផ្សាយគំរោងបីតំបន់ គឺនៅប៉ោយប៉ែត បាត់ដំបង និងសៀមរាប
- បង្កើតគណកម្មការបណ្តាញប្រចាំតំបន់ និងមានការចុះជាអនុសារណៈ ដើម្បីចូលជាបណ្តាញ ( អង្គការផ្សេងទៀត ក៏អាចសំរេចបានដែរ )
- ផ្សព្វផ្សាយការផ្តល់អារហាររូបករណ៍តាមយោបល់ផ្ទាល់ និងបណ្តាញ (បណ្តាញជួយដល់បណ្តាញផ្សេងទៀត)
- សំភាសន៍ជ្រើសរើសបេក្ខជនធ្វើតាមរយៈការសំភាសន៍ជនរងគ្រោះពីអាយុ ១៥-២៥ ព្រោះអ្នកលើសពីនេះមិនសូវរងគ្រោះរឿងនេះទេ
- ស្រាវជ្រាវរកទីកន្លែងសំរាប់ធ្វើការបណ្តុះបណ្តាល និងទីផ្សារការងារសំរាប់អនាគត
- ការផ្តល់អាហាររូបករណ៍ដល់អតិថិជន ( មិនទាន់បានធ្វើនៅឡើយ)
- ការរៀបចំពិពណ៌ការងារជូនដល់អតិថិជន
- ការផ្តល់ការប្រឹក្សាយោបល់អំពីទីផ្សារការងារសំរាប់អតិថិជន
- ការពិនិត្យតាមដានដំណើរការបណ្តុះបណ្តាល ការកែសំរួលធ្វើឱ្យកាន់តែប្រសើរឡើង
- គោលបំណងសំខាន់របស់កម្មវិធីៈ

បើកទូលាយនូវជំរើសផ្សេងៗនៃជីវិត ដល់ស្ត្រីដែលទើបតែរួចផុតពីកេងប្រវ័ញ្ច និងស្ត្រីដែលទើបរួចផុតពីគ្រោះថ្នាក់ព្រមទាំងយុវជនដែលត្រូវគេជួញដូរ និងកេងប្រវ័ញ្ច ដើម្បីឱ្យពួកគេអាចមានលទ្ធភាពរកចំណូលផ្គត់ផ្គង់ខ្លួនឯងបានគ្រប់គ្រាន់ និងជួយកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ពួកគេពីការធ្វើអាជីវកម្មរបស់អ្នកដ៏ទៃ។

## ១- សកម្មភាពការងារ

- ការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រសង្គមក្នុងការពិគ្រោះយោបល់
- ការបណ្តុះបណ្តាលជាមូលដ្ឋាន ( មានតែទ្រឹស្តីនៅឡើយ)
- ការពិនិត្យតាមដានលើកាអនុវត្តជាក់ស្តែង

### ២- លទ្ធផលរំពឹងទុក

សិក្ខាកាមចំនួន១៥នាក់ មកពីបណ្តាញអង្គការផ្សេងៗដែលជាសមាជិកសម្ព័ន្ធរបស់ COSECAM និងមានជំនាញចិត្តសាស្ត្រសង្គមក្នុងការប្រឹក្សាយោបល់ ។

### ៣- លទ្ធផលជាក់ស្តែង

សិក្ខាកាមចំនួន ១៣នាក់ បានវគ្គបណ្តុះបណ្តាលស្តីពី មូលដ្ឋានជំនាញចិត្តសាស្ត្រសង្គមក្នុងការរៀបចំប្រឹក្សាយោបល់ ។

### ៤- បញ្ហា និងឧបសគ្គ

- ការមិនយល់ស្របគ្នារវាងអង្គការ SSC ជាមួយនិងអង្គការ COSECAM ទៅលើវិធីសាស្ត្រពិនិត្យតាមដានសកម្មភាពអនុវត្តន៍ជាក់ស្តែងរបស់សិក្ខាកាម
- គំរោងចំណាយដែលរៀបចំឡើងដោយ SSC ខ្ពស់ជាងលទ្ធភាពដែល COSECAM អាចទៅរួច
- មិនទាន់មានការព្រមព្រៀងជាមួយដៃគូថ្មី CMHC នៅតាខ្មៅ

## ការប្រជុំប្រចាំខែ

### ១- សកម្មភាពការងារ

ការប្រជុំប្រចាំខែរបស់អនុគណៈកម្មការស្តារនីតិសម្បទា និងសហរណកម្មដើម្បីត្រួតពិនិត្យមើលសកម្មភាពការងាររបស់កម្មវិធី ហើយនិងធ្វើការផ្តល់យោបល់ ដើម្បីឲ្យកាន់តែមានភាពប្រសើរឡើង និងមានសហជីព ៦នាក់ដែលជាសមាជិកសម្ព័ន្ធ COSECAM ។

### ២- លទ្ធផលរំពឹងទុក

យ៉ាងហោចណាស់ការប្រជុំនឹងត្រូវបានប្រព្រឹត្តឡើងចំនួន ១០ដង ក្នុងមួយឆ្នាំនៃគំរោង ប៉ុន្តែធ្វើបានតែបួនដង ព្រោះពេលដែលដល់ថ្ងៃនោះមិនមានមនុស្សគ្រប់គ្រាន់សំរាប់ធ្វើការពិភាក្សាឡើយ ។

### ៣- លទ្ធផលជាក់ស្តែង

- បានដំណើរការកិច្ចប្រជុំតែចំនួន បួនដងគត់ ដោយគិតតាំងពីខែ កុម្ភៈ ឆ្នាំ២០០៤ នេះ ។

### ៤- បញ្ហា និងឧបសគ្គ

- ចំលើយចូលរួមសំរាប់ការអញ្ជើញរបស់សមាជិកភាគច្រើនគ្មានភាពប្រាកដប្រជា
- ការសុំដកខ្លួនចេញរបស់ប្រធានអនុគណៈកម្មការដោយសារគាត់ជាប់រវល់

- សមាសភាពសមាជិកមួយចំនួនហាក់បីដូចជា មិនសូវចាប់អារម្មណ៍ចំពោះកម្មវិធីនេះ ហើយមិនសូវបានផ្តល់យោបល់ច្រើនទេ
- ដំណើរវគ្គយឺតយ៉ាវរបស់គំរោង VTF

## គំរោងមូលនិធិផ្តល់អាហាររូបករណ៍ និងវិជ្ជាជីវៈដល់ជនរងគ្រោះ (VTF)

### សកម្មភាពការងារ

- ផ្សព្វផ្សាយគំរោង
- ជ្រើសរើសអតិថិជនដើម្បីផ្តល់អាហាររូបករណ៍
- ស្រាវជ្រាវកន្លែងបណ្តុះបណ្តាល និង រកទីផ្សារការងារ
- ផ្តលការប្រឹក្សាយោបល់អំពីការហ្វឹកហ្វឺនជំនាញ និងការងារសំរាប់អនាគត

### លទ្ធផលជាក់ស្តែង

អតិថិជនចំនួន ៧៣នាក់ ឬស្មើនឹង ២៥.៣៣%នៃចំនួនសរុបដែលរំពឹងទុកបានទទួលអាហាររូបករណ៍សំរាប់ទៅរៀនជំនាញវិជ្ជាជីវៈ ហើយនឹងទទួលបានការងារថ្មី ក្រោយពេលរៀនចប់ដោយអាស្រ័យទៅតាមលទ្ធផលសិក្សារបស់អតិថិជននីមួយៗតាមជំនាញនោះ។

### លទ្ធផលរំពឹងទុក

យ៉ាងហោចណាស់កុមារី និងស្ត្រីដែលរងគ្រោះដោយសារការជួញដូរ និងកេងប្រវ័ញ្ចទៅលើផ្លូវភេទចំនួន ៣០០នាក់ និងបានរៀនជំនាញវិជ្ជាជីវៈ ហើយមានការងារធ្វើក្រោយពេលរៀនចប់។

### បញ្ហា និងឧបសគ្គ

- ផែនការយុទ្ធសាស្ត្រ, ថវិការ និងពេលវេលា មិនទាន់ស៊ីសង្វាក់គ្នា (គំរោងសាកល្បង) យឺតយ៉ាវ
- ភាពរុញរារបស់បណ្តាញអង្គការមួយចំនួន ដោយសារការយល់ច្រឡំអំពីផលប្រយោជន៍
- ពុំទាន់មានប្រពន្ធ័ផ្ទេរជនរងគ្រោះក្រោយពេលដែលសង្គ្រោះបាន និងអប់រំអំពីបំណិនជីវិតមិនបញ្ជូននិងខំរកដោយខ្លួនឯង
- ការស្រាវជ្រាវសំរាប់កាបណ្តុះបណ្តាល និងរកទីផ្សារការងារមានភាពយឺតយ៉ាវ
- ការបណ្តុះបណ្តាលក្នុងតំបន់មួយចំនួនគ្មានទីផ្សារការងារសមស្របសំរាប់អតិថិជន

ការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រសង្គមក្នុងការពិគ្រោះយោបល់ និងការធ្វើដំណើរការប្រជុំប្រចាំខែរបស់អនុគណៈកម្មការស្តារនីតិសម្បទា និងសមាហរណកម្មនឹងនៅតែបន្ត ដោយគ្រោងនិងពិចារណាកែសំរួលវិធីសាស្ត្រ

អោយកាន់តែមានប្រសិទ្ធិភាព និងមានភាពទាក់ទាញថែមទៀត។ ដោយលែកគំរោងមូលនិធិផ្តល់អាហាររូបករណ៏ជួយជនរងគ្រោះគឺ ជាអាទិភាពដែលតំរូវអោយមានការកែសំរួល និងលំអអោយកាន់តែមានប្រសិទ្ធភាពឡើងជាចាំបាច់។ ការកែសំរួលយុទ្ធសាស្រ្តដែលបានអនុវត្តកន្លងមកសំដៅធ្វើយ៉ាងណាឱ្យមានបណ្តាញអង្គការនានាកាន់តែយល់ច្បាស់អំពីផលប្រយោជន៏ជនរងគ្រោះ ហើយផលប្រយោជន៏សង្គម និងផលប្រយោជន៏សាម៉ីអង្គការខ្លួនផ្ទាល់ហើយបែងចែកឱ្យដាច់ដោយឡែកទៅនិងផលប្រយោជន៏បុគ្គល។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លទ្ធផលដែលយើងបានទទួលក្នុងមួយវគ្គគំរោងសំរាប់ឆ្នាំ ២០០៤ នេះមានមោទនភាពជាកំលាំងចិត្ត សំរាប់ការអនុវត្តបន្តក្នុងឆ្នាំខាងមុខផងដែរ ដោយយើងយោងទៅលើហេតុផលថា (បរិមាណត្រូវដើរទន្ទឹមគ្នានិងគុណភាព)។

## សំនួរ និង ចំលើយ

**Q. ការផ្តល់អាហារូបករណ៏មានការយឺតយាវ និងមិនអាចបំពេញតាមតំរូវការ។ តើអង្គការមានគំរោងដូចម្តេចទៅថ្ងៃអនាគត?**

នៅឆ្នាំ ២០០៥ អង្គការនឹងចាប់ផ្តើមទទួលពាក្យមុនកម្មវិធី ហើយទាក់ទងទៅនឹងបញ្ហានេះ យើងកំពុងតែជ្រើសរើសបុគ្គលិកកម្មវិធីម្នាក់ថែមទៀត។ បន្ទាប់មកយើង និងអញ្ជើញនិយោជកមួយចំនួនមកចូលរួមហើយយើងធ្វើការតាំងពិពណ៌ពីសមិទ្ធិផលសមត្ថភាពរបស់កុមាររបស់យើង ដែលបានទទួលការបណ្តុះបណ្តាលដែលយើងនឹងធ្វើនៅបន្ទាប់ពីចូលឆ្នាំខ្មែរហើយនេះ។

**Q. ក្នុងការផ្តល់ការសិក្សាដល់កុមារ តើត្រូវចំណាយថវិកាចំនួនប៉ុន្មានសំរាប់កុមារម្នាក់?**

វាអាស្រ័យលើមុខជំនាញដែលពួកគេរៀន ព្រោះមុខជំនាញខ្លះត្រូវការពេលវេលាយូរ ហើយនិងការចំណាយច្រើន ហើយយើងថែមទាំងផ្តល់ថវិកាសំរាប់គ្រួសារទៀត។ ហើយចំពោះអ្នកដែលមករៀនម្នាក់ត្រូវចំណាយអស់ ៧០០ ដុល្លា បើគិតជាមធ្យម។

**Q. តើអង្គការសមាជិកមានគំនិតដូចម្តេច ដើម្បីអោយកម្មវិធីផ្តល់អាហាររូបករណ៏សំរាប់ការសិក្សានេះ មានដំណើរការល្អ?**

រាល់ការសិក្សាត្រូវផ្សារភ្ជាប់ជាមួយនិងការអនុវត្ត។ ចំពោះមណ្ឌលទាំង ១២ យើងអាចផ្តល់អោយក្មេងដល់ទៅចំនួន ២០០-៣០០ នាក់។ ចំពោះចំនួនក្មេងក្នុងមណ្ឌលកន្លែងខ្លះមិនមានចំនួនក្មេងពិតប្រាកដទេ មានតែតួរលេខតែប៉ុណ្ណោះ ដូចនេះគេមិនបានបញ្ជូនក្មេងអោយមកចូលរួមនៅក្នុងវគ្គសិក្សានេះទេ ព្រោះខ្លាចគ្មានក្មេងនៅក្នុងមណ្ឌលខ្លួនឯង។ ពេលខ្លះអតិថិជនខ្លួនឯងនោះ មិនទាន់មានការជឿជាក់លើមុខជំនាញ និងអង្គការដែលផ្តល់

មុខជំនាញ។ ហេតុនេះយើងមានការលំបាកនៅក្នុងការរកអតិថិជនមកចូលរួមនៅក្នុងការសិក្សានេះ។ អ្វីដែលយើងចង់បានគឺ ការរកអ្នកដែលមានឆន្ទៈ និងការប្តេជ្ញាក្នុងការទទួលយកជំនាញសំរាប់អនាគតរបស់ពួកគេ។

ម្យ៉ាងទៀតចំពោះការងារ អង្គការមិនអាចធានាចំពោះការងារនោះទេ តែអង្គការនិងខិតខំទាក់ទង និងស្វែងរកការគាំទ្រពីសហគ្រាស និងស្ថាប័ននានាដែលគេអាចទទួលយកជំនាញដែលយើងផ្តល់។

**ការបញ្ជាក់របស់សមាជិក:** ចំពោះហេតុផលដែលថា អង្គការខ្លះមិនបានបញ្ជូនក្មេងមក កូសេកាំ គឺ ដោយសារក្មេងខ្លះទើបតែមកនៅក្នុងមណ្ឌលហើយពុំទាន់មានការអប់រំអោយមានភាពទុកចិត្តនៅឡើយ។ ហើយកុមារខ្លះពេលដែលយកមកដល់មណ្ឌលហើយ ត្រូវអាណាព្យាបាល រឹកងកំលាំងប៉ូលីសគេមកយកទៅវិញ។

**មតិរបស់កូសេកាំ:** ពេលដែលយើងជួយ គឺយើងចង់បានអ្នកដែលមានឆន្ទៈខ្លួនឯង ដូចនេះយើងត្រូវអោយមានអ្នកជួយធ្វើការតាមដានអោយបានច្បាស់លាស់ ចៀសវាងនៅពេលរៀនបានពាក់កណ្តាលវគ្គហើយគេឈប់ទៅវិញ។

ចំពោះហេតុផលដែលគាត់ចេញទៅវិញនេះ មានសមាជិកអង្គការខ្លះបានលើកឡើងថា គាត់ចេញទៅវិញហើយឈប់សិក្សានោះគឺ ដោយសារគាត់ជាអ្នករកចំណូលសំរាប់គ្រួសារ ហើយបើគាត់មករៀនគឺ គាត់មិនអាចមានអ្វីមួយសំរាប់គ្រប់គ្រងគ្រួសារនោះទេ។

ការប្រមូលពត៌មាននេះមានលក្ខណៈខុសៗគ្នា និងមិនអាចយកជាការបាន ហេតុដូចនេះសូមអោយសម្ព័ន្ធអង្គការកូសេកាំ ចុះទៅដល់ទីកន្លែងហើយពិនិត្យអោយបានច្បាស់។

ត្រូវខំស្វែងរកការងារអោយបាន ព្រោះបើរៀនហើយគាត់មិនមានការងារធ្វើមិនអាចរកលុយមកចិញ្ចឹមជីវិតបានគាត់ និងត្រឡប់ទៅកាន់កន្លែងដើមវិញ។

អ្នកខ្លះទៀតគាត់យល់ថា លុយដែលទទួលបានគឺ មិនស្មើនិងលុយដែលគាត់ទទួលបានពីការងារនោះទេ ទោះបីជាពេលខ្លះយើងបានផ្តល់ប្រាក់ហោប៉ៅរបស់គាត់ដល់ទៅ ២២ ដុល្លាសហរដ្ឋ ក៏ដោយ។ ហើយគាត់នៅតែវិលត្រឡប់ទៅរកកន្លែងដើមវិញ។

## អនុសាសន៍:

- បើសិនជាមានអ្នកណាមួយ ដែលគេចង់ចូលរួមក្នុងការសិក្សានេះ សូមអោយអង្គការចុះទៅជួបគេដោយផ្ទាល់ដល់ទីកន្លែងតែម្តង។
- គួរផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សាម៉ីអង្គការ ដែលគេចុះមកពិនិត្យតាមដានលើកុមារដែលគេបានមករៀនជំនាញ។
- សូមអោយ កូសេកាំ ផ្តល់សំភារៈ និងថវិកាមួយចំនួនសំរាប់អោយគាត់គាំទ្រជីវភាព នៅពេលដែលគាត់មកចូលរួមក្នុងវគ្គសិក្សានេះ។

# ការបង្ហាញរបស់ លោក ទួន វិចិត្រ

## កម្មវិធី តស៊ូមតិ (Advocacy Program)

## ១- គាំទ្រគោលនយោបាយដែលមានឥទ្ធិពល និងប្រកបដោយប្រសិទ្ធភាព (EPI)

**លទ្ធផល**

- សម្ព័ន្ធកូសេកាំ បានរៀបចំកិច្ចពិភាក្សាតុមូលចំនួន ៤ ដែលក្នុងនោះរួមមានៈ កិច្ចពិភាក្សាតុមូលមួយដែលបានធ្វើឡើងកាលពីថ្ងៃទី ១២ ខែមិនា ឆ្នាំ ២០០៤ ស្តីពី មណ្ឌលថែរក្សាកុមារ។ ចំណែកឯកិច្ចពិភាក្សាចំនួន ៣ទៀត ត្រូវបានរៀបចំឡើងនៅក្នុងយុទ្ធនាការជាតិប្រឆាំងនឹងការជួញដូរលើកុមារកាលពីថ្ងៃទី ២១-២៨ ខែឧសភា ឆ្នាំ ២០០៤ និងក្នុង កំឡុងពេលធ្វើសន្និសីទជាតិ ថ្ងៃទី ២៥-២៧ ខែសីហា ឆ្នាំ ២០០៤។
- ជាលទ្ធផល កូសេកាំបានរៀបចំកែសំរួលកិច្ចពិភាក្សាទាំងអស់នោះជា **VCDs** និងរបាយការណ៏សង្ខេបរួចរាល់ហើយ។

**បញ្ហា**

- បុគ្គលសំខាន់ៗមួយចំនួនតូចមិនបានចូលរួម និងការពារនូវតួនាទីរបស់ពួកគេក្នុងព្រឹត្តិការខាងលើទេ។

## ២- ការផ្សះផ្សារវាង អង្គការ CWCC ដែលជាសមាជិកកូសេកាំ ជាមួយនឹង IJM

**លទ្ធផល**

- ករណីដ៏សំខាន់នេះ ត្រូវបានដោះស្រាយតាមរយៈការបង្កើតឡើងនូវក្រុមការងារពីមុន។ **IJM** បានអះអាងថា ពួកគេនឹងចូលរួមយ៉ាងសកម្មតាមរយៈកិច្ចប្រជុំ និងពិភាក្សាជាមួយ **CWCC** ដោយសន្តិវិធី ដើម្បីដោះស្រាយនូវបញ្ហាទាំងអស់នោះ។
- ចំណែកឯរបាយការណ៏កំពុងតែដំណើរការទៅមុខ

**បញ្ហា**

- **IJM** មិនព្រមទទួលស្គាល់ក្រុមថា ជាការរំលោភបំពាន និងច្រានចោលនូវការស្នើសុំភស្តុតាងនៃការចោទប្រកាន់របស់ពួកគេ។

## ៣- ការស្ទង់មតិទៅលើកម្មវិធីតស៊ូមតិក្នុងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ-គាំទ្រពង្រឹងការគាំទ្រមណ្ឌល

**លទ្ធផល**

- ទិន្នន័យប្រមូលបានពីសមាជិកសម្ព័ន្ធកូសេកាំ
- ការវិភាគទិន្នន័យទៅលើអង្គការក្រៅរដ្ឋាភិបាលចំនួន ៩ ត្រូវបានបញ្ចប់ ហើយនឹងធ្វើការបង្ហាញនៅក្នុងអង្គប្រជុំប្រចាំឆ្នាំរបស់សម្ព័ន្ធ។
- របាយការណ៍ស្តីពីការស្ទង់មតិនេះនឹងផ្តល់ឱ្យនៅក្នុងអង្គប្រជុំប្រចាំឆ្នាំរបស់សម្ព័ន្ធ

**បញ្ហា**

- មានការលំបាកក្នុងការទទួលនូវពតិមានពិតប្រាកដ

## ៤- រៀបចំនូវកិច្ចប្រជុំស្តីពី ការឈឺរលោភទៅលើកុមារ-ផ្នែកការស្ទង់ទៅលើកុមារ

**លទ្ធផល**

- ក្រុមការងារស្តីពី ការរំលោភទៅលើកុមារ ត្រូវបានបង្កើតឡើង ប៉ុន្តែមិនទាន់មានលក្ខណៈជាក់លាក់នៅឡើយទេ។

**បញ្ហា**

- អ្នកចូលរួមភាគច្រើនបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ប៉ុន្តែមិនមានលក្ខណៈសកម្មទេ ដោយសារតែពួកគេមានការមមាញឹកក្នុងការងារ។ ជំនួសឱ្យសេចក្តីថ្លែងការណ៍ជាផ្លូវការ ដោយភ្នាក់ងារជាច្រើនយល់ថា ការរំលោភទៅលើកុមារគឺ ជាបញ្ហាបន្ទាន់មួយ។

## ៥- កិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការផ្តល់ប្រឹក្សាទៅលើការស្ទង់មតិស្តីពី គំរោងគោលនយោបាយ និងការស្ទង់មតិ ដែលរៀបចំឡើងដោយអង្គការ Pact

**លទ្ធផល**

- ពតិមានស្តីពី បញ្ហាស្ទង់មតិ ត្រូវបានគេចែករំលែក និងធ្វើការពិភាក្សាក្នុងចំណោមសមាជិកទាំងអស់

**បញ្ហា**

- កូសេកាំ មិនបានយល់ស្របទៅនឹងលក្ខណៈវិនិច្ឆ័យទាំងអស់នោះទេ ព្រោះវាមិនមានស្ថេរភាពទៅនឹងពតិមានដែលប្រមូលបាន។
- ដំណើរការនេះ គ្មានលក្ខណៈត្រឹមត្រូវ និងសុក្រឹត្យទេ

- ក្រុមការងារតំរោងគោលនយោបាយ និងការតស៊ូមតិ បានឆ្លើយតបថា លើកក្រោយដំណើរការនេះនឹងត្រូវបានគេធ្វើការផ្លាស់ប្តូរ ។

## ៦- ការបញ្ចេះបញ្ចូលសមាជិកសភាក្នុងការដោះស្រាយការរំលោភលើកុមារ

ការជួបសំណេះសំណាលជាមួយសមាជិកសភាត្រូវបានគេពន្យាពេល ដោយសារតែតំរូវការនៃនីតិវិធីត្រូវការចំណាយពេលយូរជាងការរំពឹងទុក ។ កិច្ចប្រជុំមួយដែលហៅថា "ការផ្តល់ប្រឹក្សាទៅលើកុមារដែលទទួលរងគ្រោះស្តីពី ការបញ្ចុះបញ្ចូល និងការតស៊ូមតិ" ត្រូវបានរៀបចំឡើងជំនួសឱ្យកិច្ចប្រជុំជាមួយសមាជិកសភា ។ ក្នុងកិច្ចប្រជុំនោះ មានកុមារចូលរួមចំនួន ១១នាក់ ដែលពួកគេទាំងអស់នោះមកពីមណ្ឌលផ្សេងៗដែលមានទីតាំងនៅភ្នំពេញ, បាត់ដំបង, បន្ទាយមានជ័យ និងក្រុងព្រះសីហនុ ។

វាគ្មិនចំនួន ៤រូប ត្រូវបានធ្វើការអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចប្រជុំនោះ ដែលរួមមានៈ

- ឯកឧត្តម កែ សុខស៊ីដនី ទីប្រឹក្សាក្រសួងសង្គមកិច្ច
- លោកជំទាវ គង់ ហាច សមាជិកសភា
- លោកស្រី ស៊ុន វណ្ណា អនុប្រធានការិយាល័យផ្លូវច្បាប់នៃក្រសួងកិច្ចការនារី
- លោក ថាវ គីមសាន អ្នកសំរបសំរួលសិទ្ធិកុមារនៃអង្គការ លីកាដូ

## ការបង្ហាញពីបញ្ហាទាក់ទងទៅនឹងបញ្ហាអនុគណៈកម្មការ ដោយលោក អ៊ុំ រតនា

**បញ្ហាដែលទាក់ទងទៅនឹងអនុគណៈកម្មការមានៈ**

- មានការយឺតយ៉ាវដោយសារអង្គការនិមួយៗមានការចងបណ្តាញជាមួយបណ្តាញច្រើន
- អ្នកខ្លះនៅតាមខេត្ត គាត់មានការលំបាកនៅក្នុងការធ្វើដំណើរ និងការចំណាយសំរាប់ពេលចូលរួមប្រជុំ
- អ្នកខ្លះជាអ្នកស្មគ្រ័ចិត្ត ហើយមានបទពិសោធន៍ការងារតិចតួច មិនមានការយល់ដឹងបានស៊ីជំរៅទៅលើការងារ
- អ្នកខ្លះមានការរវល់ខ្លាំងជាមួយការងារស្នូលនៅក្នុងអង្គការខ្លួន
- អ្នកខ្លះចូលរួមប្រជុំមានការយឺតយ៉ាវ មិនទាន់ពេល មានបញ្ហាផ្នែកវិន័យ
- ពុំទាន់មានបទបញ្ជាផ្ទៃក្នុងសំរាប់សមាជិកទាំងអស់

**ការពិភាក្សារកចំនុចដែលធ្វើអោយប្រសើរឡើង**

ការពិភាក្សាត្រូវបានគេបែងចែកជាបីក្រុម ហើយធ្វើការពិភាក្សាលើចំនុច ៥ ធំៗ:

- សមាជិកអនុគណៈកម្មការថា តើត្រូវមានប៉ុន្មាននាក់?
- លក្ខណៈសម្បត្តិរបស់សមាជិកអនុគណៈកម្មការថា តើត្រូវមានលក្ខណៈសម្បត្តិអ្វីខ្លះ?
- បទបញ្ជាផ្ទៃក្នុងថា តើត្រូវកំនត់ដូចម្តេច?
- ចំនួនអង្គប្រជុំរបស់អនុគណៈកម្មការថា តើត្រូវប្រជុំប៉ុន្មានដងក្នុងមួយខែ?
- យោបល់ និងអនុសាសន៍សំរាប់ធ្វើអោយកាន់តែប្រសើរឡើងសំរាប់ផែនការឆ្នាំ ២០០៥។

## ការបង្ហាញតាមក្រុមលើវិធីសាស្រ្តដោះស្រាយទាក់ទងទៅនឹងបញ្ហាអនុគណៈកម្មការ

### ក្រុមទី១

១. ត្រូវមានចំនួនសមាជិកប្រាំ (៥) នាក់ ហើយអនុគណៈកម្មការត្រូវមាន ៤ អនុគណៈកម្មការ

២. លក្ខណៈសប្បត្តិដែលត្រូវជ្រើសរើស

- បទពិសោធន៍ការងារ ពីរឆ្នាំឡើងទៅ
- អ្នកមានសម្ថតភាពការងារចាត់ចែងការងារ

៣. បទបញ្ជាផ្ទៃក្នុងៈ ត្រូវមានបទបញ្ជាផ្ទៃក្នុង ( ពេលវេលា. អាណត្តិ. វិន័យ )

៤. ការប្រជុំប្រចាំឆ្នាំៈ អង្គការមានការប្រជុំ វិសាមញ្ញ តាមតំរូវការ ការងារចាំបាច់

### សំណូមពរ

- បង្កើតអោយមានប្រអប់សំបុត្រ ដើម្បីទទួលយកការកែលំអពីគ្រប់បជ្ឈដ្ឋានទាំងអស់ ។
- សមាជិកនៃអនុគណៈកម្មការ មានឆន្ទៈក្នុងការអនុវត្តិន៍ការងារជាក់ស្តែងតែម្តង។

### ក្រុមទី២

**១. សមាជិកអនុគណៈកម្មការ គួរមានប្រាំ (៥) នាក់ៈ** ចំនួនអនុគណៈកម្មការ គួរតែរក្សាទុកទាំងបួនផ្នែក

**២ . លក្ខណៈសម្បត្តិ**

- អ្នកដែលមានតួនាទីក្នុងការធ្វើសេចក្តីសំរេចចិត្តផ្ទាល់
- មានឆន្ទៈក្នុងការលះបង់ពេលវេលា សំរាប់ការងារនោះ
- ត្រូវមានបទពិសោធន៍ដែលទាក់ទងទៅ និងការងាររបស់អនុគណៈកម្មការណាមួយក្នុងចំណោម អនុគណៈកម្មការទាំងបួននោះ

**៣. បទបញ្ជាផ្ទៃក្នុង:** ត្រូវតែរៀបចំឡើងដោយមានការចូលរួមពីសមាជិករបស់អនុគណៈកម្មការជំនាញនីមួយៗទាំងអស់ផងដែរ ។

**៤. ចំនួនការប្រជុំប្រចាំឆ្នាំ:** អាចបត់បែនពេលពេលវេលាបាន ទៅតាមតំរូវការប្រជុំជាក់ស្តែង

**៥. យោបល់ និងសំនួមពរ**

ក. គួរអោយមានការផ្លាស់ប្តូរជំនួសសមាសភាពចូលរួមរបស់អនុគណៈកម្មការ ដូចជា ( ការមកជំនួស)

ខ. គួរផ្តល់ការឧបត្ថម្ភហើយមានការលើកទឹកចិត្តខ្លះចំពោះបុគ្គលិក

គ. គួរមានអាណត្តិចំពោះការងាររបស់អនុគណៈកម្មការ

## <u>ក្រុមទី៣</u>

១. មានអនុគណៈកម្មការចំនួនពីរ

- ការតស៊ូមតិ និង អភិវឌ្ឍន៍ស្ថាបន័
- ក្រុមស្រាវជ្រាវ និង ការស្តារនីតិសម្បទា និង សមាហរណកម្ម

២. ត្រូវមានសមាជិកយ៉ាងតិច៧នាក់

៣. លក្ខណៈសម្បត្តិ

- បុគ្គលិកដែលមានបទពិសោធន៍ផ្នែកពាក់ពន្ធ័
- មានសិទ្ធិក្នុងការសំរេចចិត្ត
- ជាការល្អត្រូវមានតែម្នាក់ជាអ្នកទទួលខុសត្រូវ

## អនុសាសន៍:

- ការប្រជុំត្រូវធ្វើក្នុងរយៈពេល ១ ខែម្តង ព្រោះយើងមានការងារជាច្រើនដែលត្រូវពិភាក្សាគ្នា ។
- ចំពោះការងាររបស់អនុគណៈកម្មការ ដើរលឿនឬយឺតគឺត្រូវពិនិត្យមើលទំហំការងាររបស់គេ ។

## រសៀលថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៤

## ការបង្ហាញពីមណ្ឌល ( Notion of Constuency of NGOs ) ដោយលោក John Vighen

### សំរបសំរួលដោយលោក ប៉ុល ឃាំម និងបកប្រែដោយលោក អ៊ុំ រតនា

### អ្វីទៅជាមណ្ឌល?

មណ្ឌល គឺជាអ្វីមួយដែលមិនមែនជារឿងនយោបាយនោះទេ ។ វាហាក់បីដូចជាគ្រួសារមួយដែលមានសមាជិកប្រហែលជា ២០នាក់ ដូច្នោះដែរ ។ ប្រសិនបើគ្រួសារត្រូវការធ្វើអ្វីមួយនោះ វាតំរូវអោយសមាជិក

ទាំងអស់មានការចូលរួម។ ពេលនោះគេនឹងអោយ Uncle ជាអ្នកកាន់កម្មវិធី។ ប្រសិនបើកម្មវិធីនោះមានដំនើរការមិនល្អ Uncle នោះនឹងទទួលការស្តីបន្ទោស។ ហើយបើកម្មវិធីមានដំណើរការល្អ សមាជិកទាំងអស់នឹងប្រាប់ទៅ Aunt ថាការងារនោះមានដំណើរការល្អ។ នេះជាឧទាហរណ៍ដ៏តូចមួយ ប៉ុន្តែវាហាក់បីដូចជា Constituency (មណ្ឌល) ដែរ។ Constituency គឺជាក្រុមសមាជិកនៅក្នុងក្រុមមួយ។ ដូចជាយើងមានរដ្ឋាភិបាល តើមានអ្នកណាអាចប្រាប់ពីរដ្ឋាភិបាលបានទេ? តើរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះអ្នកណាខ្លះ? តើអ្នកណាដែលរដ្ឋាភិបាលត្រូវរាយការណ៍អោយ?

រដ្ឋាភិបាលត្រូវរាយការណ៍អោយដល់រដ្ឋសភា ហើយសភាត្រូវសំរេចសកម្មភាពនិងផ្តល់ការយល់ព្រមឱ្យដល់រដ្ឋាភិបាល។ ប្រជាពលរដ្ឋគឺជាមណ្ឌលរបស់រដ្ឋសភា ហើយសភាគឺ ជាមណ្ឌលរបស់រដ្ឋាភិបាល។ ឥឡូវនេះសូមធ្វើការសំរេចចិត្តទៅលើបញ្ហាខាងក្រោមនេះ :

ប្រសិនបើយើងមានសង្គមស៊ីវិលដូចជា អង្គការ, ស្ថាប័នឯកជន, សហគ្រាស, ប្រព័ន្ធផ្សព្វផ្សាយជាដើម។ ក្នុងនេះប្រព័ន្ធផ្សព្វផ្សាយត្រូវរាយការណ៍ទៅអ្នកកែសំរួល។ តើអង្គការត្រូវរាយការណ៍ទៅដល់អ្នកណាចំពោះសកម្មភាពដែលគេបានធ្វើ?

**ឧទាហរណ៍:** ថ្ងៃម្សិលម៉ិញ ខ្ញុំបានទៅចូលរួមសិក្ខាសាលាស្តីពីសិទ្ធិកុមារ ដែលមានឈ្មោះថា National Conference on Monitoring CRC.

យើងមានកុមារ និង សន្និសិទជាតិ ដែលរៀបចំឡើងដោយអង្គការ CRF ។ ក្រុមគោលដៅរបស់យើងគឺក្រុមក្មេងៗ, ក្រុមក្លឹបកុមារ និងជនរងគ្រោះផ្សេងៗទៀត។ ដូចនេះពេលដែលចូលរួមមិនមែនមានកុមារទាំងអស់ចូលរួមនោះទេ គឺក្រុមកុមារដែលចូលរួមនេះជាតំណាងរបស់ពួកគេ។ បន្ទាប់ពីនោះមកគេវិលត្រឡប់ទៅស្រុក ឬទីកន្លែងរបស់គេវិញ គេនឹងប្រាប់អ្នកផ្សេងទៀតដែលមិនបានមកចូលរួម។ ដូចនេះក្រុមអ្នកចូលរួមនេះគឺ ជាមណ្ឌល (Constituency) ។ ដូចនេះគេមិនគ្រាន់តែចូលរួមនោះទេ គេថែមទាំងបានប្រាប់នូវអ្វីដែលគេបានសិក្សាផងដែរ។ ដូចនេះបើយើងគិតពីកូសេកាំ តើអ្នកណាដែលកូសេកាំត្រូវរាយការណ៍ទៅអោយនោះគឺ អ្នកទាំងអស់គ្នាដែលជាគណៈប្រតិភូទាំងអស់ដែលបានចូលរួម។ ពេលដែលអ្នកទាំងអស់គ្នាត្រឡប់ទៅវិញ អ្នកនឹងរាយការណ៍ប្រាប់ដល់អង្គការរបស់លោកអ្នក។ ដូចនេះមណ្ឌលគឺ ជាក្រុមដែលយើងទាំងអស់គ្នាជាស្ថាប័នស៊ីវិលត្រូវរាយការណ៍អោយពីអ្វីដែលយើងបានធ្វើ។ ប្រហែលនេះជាបញ្ហាមួយនៅថ្មីនៅឡើយក្នុងប្រទេសកម្ពុជា។ ដូចនេះ សូមធ្វើការនឹកស្រម៉ៃថា រូបអ្នកផ្ទាល់បានធ្វើកិច្ចការមួយសំរាប់គ្រួសាររបស់លោកអ្នក ហើយពេលដែលអ្នកត្រឡប់មកផ្ទះវិញ ពេលនោះសមាជិកនៅក្នុងគ្រួសាររបស់ លោកអ្នកនិងសួរពីអ្វីដែលអ្នកបានធ្វើ ហើយអ្នកដែលនៅផ្ទះនោះអាចនឹងមិនយល់ស្របជាមួយរូបលោក ព្រោះអ្នកបានចំណាយលុយច្រើនពេក។ ដូចនេះអ្នកត្រូវតែទទួលខុសត្រូវចំពោះរឿងនេះ។ ដូចគ្នានេះដែរ កូសេកាំ ត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានធ្វើចំពោះសមាជិកសម្ព័ន្ធរបស់ខ្លួន។

ចំពោះអង្គការផ្សេង ៗទៀតដែរដូចជា CCASVA ខ្ញុំសូមសួរទៅប្រធានអង្គការថា អង្គការត្រូវរាយការណ៍ពីអ្វីដែលខ្លួនធ្វើទៅអតិថិជនរបស់យើងដែរឬទេ? (មិនមែនចំពោះអ្នកផ្តល់ជំនួយនោះទេ) ។

ចំពោះក្រុមគោលដៅគឺ អ្នកដែលយើងធ្វើសកម្មភាពក្នុងលក្ខណៈជាតំណាងអោយពួកគេ។ ដូចជា សភាដែរ សភាធ្វើការជាតំណាងអោយប្រជាពលរដ្ឋ ហើយអង្គការសង្គមស៊ីវិលធ្វើការក្នុងនាមតំណាងអោយអ្នកដែលជាក្រុមគោលដៅរបស់យើង។ ចំពោះករណីជាច្រើន យើងត្រូវតែរាយការណ៍អោយពួកគេ ប៉ុន្តែក្រុមគោលដៅមានច្រើនយើងមិនអាចទៅជួបពួកគេទាំងអស់នោះទេ។ ដូចនេះយើងត្រូវតែធ្វើការជ្រើសរើសអ្នកដែលជាតំណាង។ ចំពោះការដែលយើងរាយការណ៍សកម្មភាពគឺ យើងធ្វើចំពោះក្រុមគោលដៅរបស់យើង មិនមែនម្ចាស់ជំនួយនោះទេ ដូចជារដ្ឋាភិបាលដែលត្រូវទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ដែលគេតំណាងអោយនោះ។ សរុបមកមណ្ឌល (constituency) គឺជាក្រុមមនុស្សដែលអង្គការនានាធ្វើសកម្មភាពក្នុងនាមជាតំណាងអោយ។ (ពត៌មានបន្ថែមសូមមើល ឧបសម្ព័ន្ធ B)

## ការបន្ថែមយោបល់របស់លោក ឡូន ឌិចិត្រ

វាមិនមែនជាអ្វីដែលប្លែកនោះទេចំពោះពាក្យថាមណ្ឌល (constituency) នេះ បើយើងធ្វើការប្រៀបធៀបជាមួយពាក្យថា ក្រុមគោលដៅ រឺ អ្នកទទួលផលនោះ។ បើយើងគិតពីអង្គការរបស់យើងវិញគឺ យើងធ្វើសកម្មភាពទាំងអស់គឺ ដើម្បីក្រុមគោលដៅរបស់យើង បន្ទាប់មកយើងខិតខំរកនូវយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាទាំងនេះ តែសំខាន់គឺការកំនត់បញ្ហា។ ការកំនត់បញ្ហាទាំងនេះគឺ យើងធ្វើអោយសហគមន៍ចូលរួមផងដែរ ដើម្បីអោយមានភាពច្បាស់លាស់ ហើយធ្វើតាមអ្វីដែលគេចង់បាន។

## ការបង្ហាញរបស់កញ្ញា ហ៊្វូត សុខណ្ឌារី លើការតស៊ូមតិ

ការងារតស៊ូមតិនេះធ្វើឡើងដោយលេខាធិការដ្ឋានសម្ព័ន្ធអង្គការកូសេកាំក្នុងអំឡុងខែកញ្ញា ឆ្នាំ ២០០៤។ អង្គការបានធ្វើការសំភាសន៍ជាមួយអង្គការសមាជិកចំនួន ៩ ដែលមានកម្មវិធីតស៊ូមតិទៅលើការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ អង្គការទាំងនោះមាន : CDP, ADHOC, HCC, PJJ, CRF, CCPCR, SCCO និង CCASVA ។ នេះជាការងារតស៊ូមតិទាក់ទងនិងកិច្ចការទូទៅដែលទាក់ទង ទៅនិងការជួញដូរ។

## គោលបំណងនៃការធ្វើសង្ខេបមតិលើការងារតស៊ូមតិ

ការងារតស៊ូមតិនេះមានគោលបំណង:

- ពង្រឹងការការពារសិទ្ធិកុមារ
- កាត់បន្ថយការជួញដូរកំលាំងពលកម្ម និង ផ្លូវភេទរបស់កុមារ

- និងការធ្វើអោយមានការផ្លាស់ប្តូរនៅតាមសហគមន៍
- ដើម្បីអោយមានការផ្លាស់ប្តូរចរិត និងនយោបាយឆ្ពោះទៅរកការរីកចំរើនផ្នែកសិទ្ធិមនុស្ស

**សកម្មភាព**

- ការជួបជាមួយអ្នកដឹកនាំមូលដ្ឋាន និងអ្នកដឹកនាំធំៗ
- កម្មវិធីផ្សព្វផ្សាយជាតិ និងអន្តរជាតិ
- ការផ្សព្វផ្សាយតាមប្រពន្ធ័ផ្សព្វផ្សាយពីទោសកំហុសនៃការប្រព្រឹត្តិបទល្មើស
- ការរៀបចំសិក្ខាសាលាដោយមានការអញ្ជើញអ្នកមានអំណាចសំខាន់ៗចូលរួម
- វេទិការសំនួរចំលើយសាធារណៈ និងវេទិការតុមូល
- កម្មវិធីដឹកនាំកុមារជួបជាមួយតំណាងរាស្ត្រ
- ការបោះពុម្ពផ្សាយនូវព្រឹត្តិបត្តិសំរាប់ធ្វើការតស៊ូមតិទៅកាន់រដ្ឋាភិបាល និងសង្គមស៊ីវិល
- កម្មវិធីពង្រឹងសមត្ថភាពកុមារ ឪពុកម្តាយ និងអាជ្ញាធរ តាមរយៈការធ្វើសិក្ខាសាលាស្វែងរក គំនិត និងដំណោះស្រាយរួមគ្នា។
- ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមាររងគ្រោះ

**បញ្ហាជាអាទិភាព**

ចំពោះបញ្ហាអង្គការបានកំនត់យកបញ្ហាជាអាទិភាពមួយចំនួនដូចជាៈ

- បញ្ហាការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ និងកំលាំងពលកម្មកុមារ
- សិទ្ធិកុមារ
- សេវាកម្មច្បាប់ ប្រព័ន្ធតុលាការ អំពើហឹង្សាក្នុងគ្រួសារ
- នីតិរដ្ឋ (ធម្មាធិបតេយ្យ)
- លិទ្ធិប្រជាធិបតេយ្យ សុខភាព ការកាត់បន្ថយភាពក្រីក្រ

**ក្រុមគោលដៅរបស់អង្គការ**

ចំពោះក្រុមគោលដៅ អង្គការបានកំនត់យកក្រុមមនុស្សដូចខាងក្រោមនេះ:

- កុមារដែលត្រូវគេរំលោភផ្លូវភេទ
- កុមារប្រើប្រាស់គ្រឿងញៀន និងកុមារអនាថា
- អ្នករងគ្រោះ និងផ្ទុកមេរោគអេដស៍
- អាជ្ញាធរមូលដ្ឋាន និង អ្នកមានអំណាចក្នុងរដ្ឋាភិបាល

- គ្រូបង្រៀននៅតាមសាលានានា
- នាយកដ្ឋានយុវជននៃក្រសួងអប់រំ
- គណកម្មការការពារសិទ្ធិកុមារខេត្ត
- គណៈរដ្ឋមន្ត្រី គណៈមេធាវី និងចៅក្រម

**តំបន់គោលដៅ**

យើងមានធ្វើនៅក្នុងតំបន់មួយចំនួនដូចជានៅក្នុងខេត្ត :

- កំពង់ចាម កំពត ពោធិសាត់ បន្ទាយមានជ័យ ព្រៃវែង កណ្តាល តាកែវ មានបីអង្គការ
- ខេត្តកំពង់សោម សៀមរាប កោះកុង ស្វាយរៀង កំពង់ស្ពឺ មានអង្គការចំនួន ២
- បាត់ដំបងមានអង្គការចំនួន ៥
- ខេត្តក្រចេះ កំពង់ធំ កំពង់ឆ្នាំង និងព្រៃវែង មានអង្គការចំនួន ១

សំរាប់កម្មវិធីការងារតស៊ូមតិនេះ អង្គការបានទទួលមូលនិធិពីម្ចាស់ជំនួយមួយចំនួន តែម្ចាស់ជំនួយមិនបានកំនត់ចំនួនថវិការនោះទេ គឺគេអោយសំរាប់សកម្មភាពទូទៅតែម្តង។

ម្ចាស់ជំនួយទាំងនោះរួមមាន: NewAID, AUSAID, Forum Syd,EastWest Management Institute, UNCHCHR, Globals Opportunities Fund of Foreign, Commonwealth East Office, UNICEF, Save the Children Norway, SKN, Plan Cambodia, TAF, NOVIP, Oxfarm DCA, Canada Fund, ILO/IPEC, English Embassy, Khanna and World Food Program.

**សំនួរ និងចំលើយ**

Q. **តើយើងធ្វើការតស៊ូមតិបែបណាដើម្បីអោយបានទទួលជោគជ័យ?**

តាមបទពិសោធន៍របស់អង្គការទាំង ៩ នេះ ការតស៊ូមតិដែលទទួលបានជោគជ័យគឺ យើងធ្វើតាមប្រព័ន្ធឃោសនាដូចជាវិទ្យុ និងទូរទស្សន៍ជាដើម ដែលមានប្រសិទ្ធិភាពទៅដល់ទាំងប្រជាពលរដ្ឋ, រដ្ឋាភិបាល និងសង្គមស៊ីវិលដូចគ្នា។ ការធ្វើការតស៊ូមតិ យើងត្រូវកំនត់ក្រុមគោលដៅរបស់យើងអោយបានច្បាស់ដូចជា ឋានានុក្រមរចនាសម្ព័ន្ធ ហើយនិងអ្នកទទួលខុសត្រូវនៅក្នុងស្ថាប័ននិមួយៗគឺ អ្នកណាដែលមានសិទ្ធិនៅក្នុងការធ្វើការសំរេចចិត្ត។ ចំនុចមួយទៀតអំពីការងារធ្វើការតស៊ូមតិនេះគឺ មានតាំងពីយូរយារមកហើយ តែគ្រាន់តែយើងមិនទាន់បានប្រើពាក្យនេះ។

**ការចូលរួមមតិរបស់លោក ប៉ុល ហាំម :**

ខ្ញុំធ្លាប់ជាសមាជិកសភាធម្មនុញ្ញ ហើយខ្ញុំធ្លាប់ជាអ្នកទទួលធ្វើកិច្ចការងារតស៊ូមតិនេះនៅក្នុងឆ្នាំ ១៩៩៣ និងធ្លាប់ធ្វើការអប់រំដល់មន្ត្រីរាជការអំពីសិទ្ធិ និងអភិបាលកិច្ចល្អ ហើយចុងក្រោយបានធ្វើការបណ្តុះបណ្តាលពីការធ្វើការតស៊ូមតិនេះ។ ការជោគជ័យរបស់កិច្ចការនេះគឺ ទាក់ទងទៅនឹងបញ្ហាជាច្រើន ទី១ គឺ យើងជាអ្នកដែលធ្វើការតស៊ូមតិនោះត្រូវមានសមត្ថភាព និងត្រូវដឹងពីរបៀបនៃការធ្វើការតស៊ូមតិនេះ ហើយត្រូវដឹងថាអ្វីទៅថាការងារតស៊ូមតិនោះ។ ទី២ គឺ យើងត្រូវរៀបចំផែនការធ្វើការងារតស៊ូមតិនេះ ហើយនិងយើងត្រូវធ្វើការតស៊ូមតិជាមួយអ្នកដែលធ្វើការសំរេចចិត្តលើរាល់កិច្ចការដែលយើងចង់បាន ហើយយើងត្រូវចេះធ្វើការទំនាក់ទំនងជាមួយជនដែលយើងត្រូវធ្វើការតស៊ូមតិជាមួយ។

## ការបង្ហាញរបស់ក្រុមពិភាក្សា

**ក្រុមទី១**

**១- កត្តាសំខាន់ៗទាក់ទងទៅនឹងទស្សនៈរបស់មណ្ឌល**

- ត្រូវកំណត់ក្រុមគោលដៅ និងតំរូវការអោយបានច្បាស់លាស់
- មានអ្នកតំណាងក្រុមគោលដៅ
- មានការទទួលខុសត្រូវ និងឆ្លើយតបរបស់ក្រុមគោលដៅ

**២- ទ្រឹស្តីនិងការអនុវត្តន៍ផ្ទាល់**

- ហើយការងារច្បាស់លាស់ តែតំរូវការនៅមានកំរិតនៅឡើយ
- ត្រូវមានទំនាក់ទំនងល្អរវាងតំណាង និង ក្រុមគោលដៅ
- មានការពិគ្រោះយោបល់លើគំរោងផែនការជាមួយក្រុមគោលដៅ, ធ្វើការវាយតំលៃ និងការបង្ហាញ អំពីលទ្ធផលសំរេចបាន និងបានពិគ្រោះយោបល់ជាមួយក្រុមគោលដៅព្រមទាំងចិត្តសាស្ត្រ សំរាប់ឆ្នាំបន្តទៅទៀត។

**ក្រុមទី២**

**១- កត្តាសំខាន់ៗដែលជាទស្សនៈរបស់មណ្ឌលដូចជា**

- យើងត្រូវមានធនធានមនុស្ស ហើយនឹងថវិកាជាកត្តាសំខាន់
- គ្រប់គ្រងជាលក្ខណៈប្រជាធិតេយ្យ
- ការតស៊ូមតិដើម្បីអោយមានការផ្លាស់ប្តូរនូវរាល់ចំនុចទាំងឡាយណាដែលមិនល្អសំរាប់សង្គម

## ២- ទ្រឹស្តីនិងការអនុវត្តផ្ទាល់

- ធ្វើអ្វីៗទាំងអស់ដើម្បីផលប្រយោជន៍មណ្ឌលជាក់ស្តែង
- ដូចជាផលប្រយោជន៍រួម ផលប្រយោជន៍បក្សពួក ម្ចាស់ជំនួយ ហើយនិងខ្លួនផ្ទាល់

## ៣- សំណើរ

- សុំអោយមានធានមនុស្សប្រកបទៅដោយសមត្ថភាព
- យើងមានគោលបំណង និងផែនការសកម្មភាព និងត្រួតពិនិត្យ ហើយនិងវាយតំលៃច្បាស់លាស់ពិតប្រាកដលើការងារនោះ

**<u>ក្រុមទី៣</u>**

## ១- កត្តាសំខាន់ៗដែលជាទស្សនៈរបស់មណ្ឌលដូចជា

- អ្នកតំណាង ហើយនិងអ្នកមកជួយដល់ការធ្វើអោយសំរេចបំណងរបស់ពួកគេ
- អ្នកតំណាងត្រូវទទួលខុសត្រូវក្នុងការផ្លាស់ប្តូរវិជ្ជមាន
- អ្នកចូលរួមគំនិត និង ក្រុមគោលដៅ
- អ្នកតំណាងស្វែងរកបញ្ហា និងធ្វើការស្វែងយល់ពីក្រុមគោលដៅ
- យើងមានគំរោង និង ចេះប្រើប្រាស់ធនធានមនុស្ស និងសក្តានុពលភាពរបស់មណ្ឌល
- ត្រូវមានគំរោងរាយការណ៍ប្រាប់ទៅដល់ក្រុមគោលដៅ
- ត្រូវមានតំណាងគ្រប់ផ្នែក និងគ្រប់ជំនាញផងដែរ
- យើងត្រូវមានការផ្តល់ប្រយោជន៍របស់ក្រុមគោលដៅគឺការទទួលខុសត្រូវលើរបស់តំណាងនិមួយៗ

## ២- ទ្រឹស្តីនិងការអនុវត្តន៍ផ្ទាល់

- ដោយសារការទទួលខុសត្រូវការអនុវត្តន៍លំអៀងទោទៅរកខាងម្ចាស់ជំនួយ និងម្ចាស់អំណោយមិនដូចអ្វីដែលបានចារក្នុងទ្រឹស្តី
- ការរាយការណ៍ទៅមណ្ឌលជាបុគ្គលម្នាក់ៗ (ធ្វើតាមបុគ្គលម្នាក់ៗ)
- ចំពោះការដោះស្រាយជាបញ្ហាអាទិភាព
- អង្គការធ្វើការស្រាវជ្រាវពីបញ្ហារបស់គោលដៅមុន និងរៀបចំផែនការសំណើរ និងអនុសាសន៍
- ហើយតំណាង និងក្រុមគោលដៅធ្វើផែនការអភិវឌ្ឍន៍
- ប្រឹងប្រែងដើរតាមទ្រឹស្តីអោយអស់លទ្ធភាព
- អ្នកបង្កើតទ្រឹស្តីផ្តល់នូវការសិក្សាជាគំរូ

**ការផ្តល់នូវការអធិប្បាយនៅលើសកម្មភាពថ្ងៃទី ១៨ ខែធ្នូ ដោយលោក ទូន វិចិត្រ**

លោក ទូន វិចិត្របានធ្វើការថ្លែងអំណរគុណដល់អ្នកចូលរួម និងការខិតខំធ្វើការពិភាក្សារកចំនុចល្អៗ សំរាប់សកម្មភាពទៅថ្ងៃអនាគត។ បើយើងពិនិត្យទៅលើក្រុមទាំងបីយើងឃើញថា ក្រុមទី ១ និងក្រុមទី ៣ បាន រកឃើញនូវចំនុចប្រហាក់ប្រហែលគ្នា។ ចំណែកឯក្រុមទី ២ បានរកឃើញចំនុចពិសេសបន្ថែមមួយចំនួនទៀតដូចជា លក្ខណៈប្រជាធិបតេយ្យ ធនធាន និងថវិកាការអនុវត្តមិនបានឆ្លើយតបទៅតាមតំរូវការ។ ក្រៅពីនេះនៅមាន សំណូមពរ សូមអោយសមាជិកទាំងអស់ធ្វើការអោយស៊ីសង្វាក់គ្នា ហើយនិងសុំឱ្យអ្នកតំណាង និងក្រុមគោលដៅ ធ្វើការសហការគ្នាអោយបានល្អក្នុងការធ្វើអោយសំរេចជោគជ័យ។

នៅថ្ងៃនេះដែរ មុននឹងបញ្ចប់កម្មវិធីសំរាប់ថ្ងៃទី ១ លោក ប៉ុល ហំម ដែលជាអ្នកសំរបសំរួលបានលើក សំនួរពីរ សំនួរមួយសំរាប់ លោក John Vighen និងសំនួរមួយទៀតសំរាប់លោក កែម សម្បត្តិ ឬកញ្ញា សុវណ្ណារី ហើយសុំអោយធ្វើការបកស្រាយអោយច្បាស់នៅថ្ងៃទី ២។

**សំនួរទី ១ :** អ្វីទៅដែលហៅថា មណ្ឌល (constituency)? សូម លោក **John** ធ្វើការបញ្ជាក់អោយច្បាស់ ហេតុអ្វីចាំបាច់បង្កើតពាក្យនេះទៀត បើយើងមានពាក្យថា Target Group និង Beneficiaries ហើយ?

**សំនួរទី ២ :** ហេតុអ្វីបានជាយើងត្រូវការធ្វើការស្ទង់មតិនេះ?

## ថ្ងៃទី ២ (ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៤)

(សកម្មភាពលំអិតប្រចាំថ្ងៃ សូមមើលឧបសម្ព័ន្ធ A)

មុននឹងចាប់ផ្តើមធ្វើការងារបន្តនៅថ្ងៃទី ២ លោក ទូន វិចិត្រ ដែលជាអ្នកសំរបសំរួលបានធ្វើការបញ្ជាក់ បន្ថែមពីអ្វីដែលត្រូវធ្វើសំរាប់ថ្ងៃនេះ ហើយលោកក៏បានធ្វើការឆ្លើយបំភ្លឺថា ហេតុអ្វីបានជាត្រូវធ្វើការស្ទង់មតិនោះ។ ការស្ទង់មតិគឺ យើងផ្តោតទៅលើអង្គការមួយចំនួនថា តើគេប្រើវិធីសាស្ត្រអ្វីក្នុងការធ្វើសកម្មភាពដើម្បីបំរើអោយ ក្រុមគោលដៅ ដូចជាក្មេងអនាថានៅតាមផ្លូវកុមាររងគ្រោះដោយការរំលោភ និងកុមាររងគ្រោះផ្សេងៗទៀត។ ដូចនេះយើងធ្វើការស្រាវជ្រាវអោយដឹងពីការពិតថា តើគាត់បានធ្វើការងារបំរើអោយក្រុមគោលដៅពិតប្រាកដ ឬទេ។ ក្នុងការអនុវត្តជាក់ស្តែងគឺ គាត់ធ្វើការទៅតាមតែចំណេះដឹងរបស់គាត់ ហើយគាត់មិនដែលបានចុះទៅដល់ ក្រុមគោលដៅរបស់គាត់ដោយផ្ទាល់នោះទេ ហេតុនេះយើងធ្វើការស្ទង់មតិនេះឡើងដើម្បីអោយដឹងពីការពិត។

ម្យ៉ាងទៀត ការធ្វើការស្ទង់មតិនេះគឺ យើងធ្វើឡើងដើម្បីអោយមានការផ្លាស់ប្តូរចំពោះក្រុមគោលដៅ ណាមួយ។ នេះយើងចង់ដឹងថា អង្គការណាមួយធ្វើដល់កំរិតណា តើអ្នកណាធ្វើបានជាតំណាងគោលដៅដល់កំរិតណា។

**សំនួរៈ តើយើងគួរតែប្រើមធ្យោបាយសំបណាដើម្បីធ្វើការតាមដានសកម្មភាពអោយមានប្រសិទ្ធិភាព?**

**លោក សាក់ អង្គការវឌ្ឍនភាព :** យើងគួរតែប្រើវិធី PRA ដោយយើងធ្វើការចុះទៅដល់សហគមន៏ដោយផ្ទាល់តែម្តង ដើម្បីសួរពីការពិត និងសូមការយល់ព្រមពីក្រុមគោលដៅ ហើយយើងយកទិន្នន័យនោះមកធ្វើការវិភាគរួចយើងផ្ញើរជូនទៅម្ចាស់ជំនួយធ្វើការពិនិត្យ ។ ទោះបីជាយ៉ាងណាក៏ដោយក៏យើងមិនអាចអនុវត្តអោយបាន ១០០% ដូចដែលមាននៅក្នុងទ្រឹស្តីនោះបានដែរ ។

## ការពិភាក្សាតាមក្រុម

ចំពោះកិច្ចពិភាក្សាតាមក្រុម អ្នកសំរបសំរួលបានសូមអោយអ្នកចូលរួមទាំងអស់ធ្វើការពិភាក្សាទៅតាមប្រភេទរបស់អង្គការ ដូចជាអង្គការផ្នែកការផ្តល់ជំរក (៥) ផ្នែកច្បាប់ (២) ផ្នែកសិទ្ធិមនុស្ស (២) និងផ្នែកអភិវឌ្ឍន៏កុមារ (៥) ។

## ការបង្ហាញពីលទ្ធផលកិច្ចពិភាក្សារបស់ក្រុមពិភាក្សា

### ក្រុមទី១ : (ផ្នែកផ្តល់ជម្រក)

**យុទ្ធសាស្ត្រដើម្បីឈានដល់ការបង្កើតមណ្ឌល**

១- រកទីតាំងមានសុវត្ថិភាព ហើយចំគោលដៅ

២- ត្រូវសិក្សាពីបញ្ហាដែលពួកគេកំពុងជួបប្រទះក្នុងសហគមន៏ផងដែរ

៣- ហើយកំណត់គោលដៅច្បាស់

៤- រៀបចំនីតិវិធីក្នុងការជួយដល់ក្រុមគោលដៅការងារ

៥- រៀបចំផែនការក្នុងការអនុវត្តការងារ

៦- ចេះទំនាក់ទំនងរកជំនួយពីខាងក្រៅដើម្បីដោះស្រាយ

៧- មានកិច្ចសហការណ៍ជាមួយស្ថាប័នដែលពាក់ពន្ធ័ និង ការងារនោះ

**សំនួរៈ តើអ្នកណាដែលក្រុមទី១កំនត់ថា ជាមណ្ឌល (constituency)?**

គឺយើងបានកំនត់ក្រុមកុមារក្នុងតំបន់ប្រតិបត្តិការរបស់អង្គការ ។

## ក្រុមទី២ : ការគាំទ្រផ្នែកច្បាប់

### យុទ្ធសាស្ត្រសំរាប់ឈានទៅរកការបង្កើតបណ្តុល

១- កំណត់តំបន់គោលដៅនិងក្រុមគោលដៅអោយបានច្បាស់លាស់

២- ការកំណត់បញ្ហា និង តំរូវការសំរាប់ក្រុមគោលដៅ

៣- ស្វែងរកការគាំទ្រ និង ការគាំទ្រពីក្រុមគោលដៅ ហើយនិងស្ថាប័នដែលពាក់ពន្ធ័

៤- កំណត់អ្នកតំណាង

៥- បង្កើតផែនការ និងសកម្មភាពដោយមានការចូលរួមពីក្រុមគោលដៅ និងតំណាងរបស់ពួកគេ។

## ក្រុមទី៣ : ផ្នែកសិទ្ធិមនុស្ស

### សំនួរៈ តើយើងមានយុទ្ធសាស្ត្រណាខ្លះ ដើម្បីអោយយើងឈានទៅដល់ការបង្កើតមណ្ឌល?

១- ប្រមូលពត៌មានពីការរំលោភសិទ្ធិមនុស្ស ដើម្បីជ្រើសរើសតំបន់គោលដៅសំខាន់ៗ

២- ផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ដល់តំបន់គោលដៅ

៣- ប្រមូលតំបន់គោលដៅ ហើយនិងក្រុមគោលដៅ

៤- ជ្រើសរើសតំណាងអោយក្រុមគោលដៅ ដោយបង្រៀនបំប៉នចំណេះដឹង នៅក្នុងមណ្ឌល

**ផ្តើផ្ទាៈ យើងត្រូវដោះស្រាយអោយបានរាល់បញ្ហាផ្សេងៗនៅក្នុងមណ្ឌលរបស់យើង ។**

## សំនួរ និងចំលើយៈ

### សំនួរៈ ហេតុអ្វីបានជាមានការរំលោភសិទ្ធិកុមារកាន់តែខ្លាំង នៅពេលដែល NGOs ធ្វើការកាន់តែខ្លាំង?

នេះគឺដោយសារការទទួលពត៌មាន ដែលពីមុនមកយើងមិនដែលបានទៅធ្វើការសង្កេតពីហេតុការណ៏នេះឱ្យបានច្បាស់លាស់។ ដូចនេះការកើនឡើងនេះគឺ ការកើនឡើងទៅលើស្ថិតិមិនមែនការកើនឡើងពីបទល្មើសក្នុងពេលបច្ចុប្បន្ននេះទេ។

## អនុសាសន៏:

- ចំពោះការធ្វើផែនការសកម្មភាព គឺយើងត្រូវប្រមូលពត៌មានអោយច្បាស់សិន ទើបយើងធ្វើការកំនត់តំបន់គោលដៅដែលជាអាទិភាព ដើម្បីអនុវត្តសកម្មភាពអោយបានល្អទៅតាមអ្វីដែលគេចង់បាន ព្រោះគាត់មានការយល់ដឹងពីអ្វីដែលគាត់ចង់បាន។

- យើងត្រូវកំនត់មណ្ឌល (constituency) អោយច្បាស់សិនមុននឹងយើងធ្វើសកម្មភាព។ បន្ទាប់មក យើងធ្វើការពិនិត្យមើលលើសិទ្ធិណា ជនណាដែលគេបំពាន។ (លោក សុខ សំអឿន)
- ដើម្បីសំរេចផលរបស់មណ្ឌល (constituency) យើងត្រូវស្គាល់អោយបានច្បាស់លាស់នូវអ្វី ដែលយើងត្រូវធ្វើ រួចហើយទើបយើងធ្វើផែនការសកម្មភាព និងរកយុទ្ធសាស្ត្រដើម្បីធ្វើ និងកំនត់ថាតំណាក់កាលណាត្រូវធ្វើអ្វី។ (លោក ប៉ុល ហំម)

## ការផ្តល់ការអធិប្បាយរបស់លោក ឡូន វិចិត្រ នៅលើការបង្ហាញរបស់ក្រុមទាំង ៣

លោកបានធ្វើការផ្តល់យោបល់ថា ជាការពិតណាស់ការយល់ដឹងនៃក្រុមទាំង ៤ មានការយល់ដឹងខុសៗគ្នា ហើយអង្គការដែលធ្វើការជាមួយសហគមន៍បានរកឃើញ និងមានការយល់ដឹងបានច្រើនជាង។ តែអង្គការដែលធ្វើការនៅផ្នែកច្បាប់ និងសិទ្ធិមនុស្សយើងឃើញថា សកម្មភាពរបស់គាត់ច្រើនតែមានលក្ខណៈជាថ្នាក់កណ្តាលដែលមានលក្ខណៈប្រយោលពីចំងាយ។ ទោះជាយ៉ាងណាក៏ដោយយើងឃើញថា ចំនុចទាំងអស់មានលក្ខណៈលំអិត និងបានឆ្លើយតបល្អទៅនឹងអ្វីដែលយើងចង់បាន តែផ្នែកច្បាប់គាត់ធ្វើការក្នុងលក្ខណៈជាប្រយោលជាង។

ទោះជាយ៉ាងណាក៏ដោយ សរុបមកយើងឃើញថា ការយល់ដឹងពីមណ្ឌលមានលក្ខណៈនៅខ្វះចន្លោះនៅឡើយ (ការយល់ដឹងនៅមានកំរិត) តែនេះក៏ដោយសារការបកប្រែពាក្យនោះមកជាភាសាខ្មែរ មិនមានភាពច្បាស់លាស់នោះដែរ ដែលជាហេតុធ្វើអោយមានការយល់ច្រឡំ។ តែយ៉ាងណាក៏ដោយ នេះគ្រាន់តែជាដំណាក់កាលដំបូងដែលជាការបំផុសគំនិតតែប៉ុណ្ណោះ។

ក្រៅពីនេះ លោក វិចិត្រ បានសួរទៅអង្គប្រជុំទាំងមូលថា ដោយសារការពិភាក្សាអស់មួយរយៈពេលហើយ តែនៅមិនទាន់មានការយល់ដឹងបានច្បាស់លាស់ ដូចនេះលោក វិចិត្រ បានសុំសួរយោបល់ដល់អ្នកចូលរួមទាំងអស់ បើមានអ្នកណាមានចំណាប់អារម្មណ៍សំរាប់ធ្វើការពិភាក្សាអោយបានច្បាស់ គាត់នឹងរកពេលវេលាណាមួយដែលសមស្របសំរាប់ពិភាក្សានិងសិក្សាអោយបានច្បាស់។

### ការសង្ខេបរបស់លោក ប៉ុល ហំម

លោកបានធ្វើការសង្ខេបពីអ្វីដែលអង្គប្រជុំបានធ្វើការពិភាក្សាកន្លងមកនៅក្នុងវេលាព្រឹកថ្ងៃទី ១៩ ដែលជាថ្ងៃទី ២។ សំរាប់សកម្មភាពដែលបានធ្វើមានដូចតទៅ:

ជាដំបូង មានការបញ្ជាក់បន្ថែមសំរាប់ការបង្ហាញពីមណ្ឌលដោយលោក John ទៅលើចំនុចដែលមិនទាន់មានភាពច្បាស់លាស់ ប៉ុន្តែនៅតែមានការយល់ច្រឡំខ្លះៗ។ លោកបានបញ្ជាក់ថា មណ្ឌលគឺជាជនទូទៅមិនមែនតែ

អ្នករងគ្រោះរឺក្រុមអ្នកបោះឆ្នោតនោះទេ។ សំរាប់អង្គការវិញមណ្ឌលគឺ ក្រុមណាមួយដែលយើងកំនត់សំរាប់ធ្វើសកម្មភាព។

កញ្ញា សុវណ្ណារី បានធ្វើការរៀបរាប់ពីក្របខណ្ឌ័សកម្មភាពរបស់អង្គការ ហើយបន្ទាប់មកមានការបែងចែកជា ៣ក្រុម ដើម្បីធ្វើការពិភាក្សា ហើយនៅពេលព្រឹកនេះមានការបញ្ជាក់អោយកាន់តែច្បាស់ពីភាពខុសគ្នារវាងក្រុមគោលដៅ និងអ្នកទទួលផល។ បន្ទាប់មកមានការពិភាក្សាដើម្បីស្វែងរកយុទ្ធសាស្រ្តល្អៗ និងមានប្រសិទ្ធិភាពដើម្បីធ្វើអោយសំរេចសកម្មភាពរបស់មណ្ឌល។ ការពិភាក្សាគឺ ត្រូវបានបែងចែកជា ៤ក្រុម ទៅតាមប្រភេទការងាររបស់អង្គការនិមួយៗ។ នៅចុងបញ្ចប់នេះយើងឃើញថា ការប្រជុំបូកសរុបលទ្ធផលការងារ និងការពិភាក្សាការងារបានទទួលលទ្ធផលប្រសើរ តែទាមទារអោយមានការស្រាវជ្រាវថែមទៀត។

ឆ្លងតាមការពិភាក្សាយើងឃើញថា មានការដាក់អាទិភាពលើចំនុចយុទ្ធសាស្រ្តនិមួយៗសមស្រប ហើយអង្គប្រជុំអាចដឹងថា គេត្រូវធ្វើអ្វីសំរាប់អតិថិជនរបស់គេ។ នៅចុងបញ្ចប់ កូសេកាំ សូមអោយអង្គការទាំងអស់មានការប្តេជ្ញាចិត្តក្នុងការសិក្សា និងអនុវត្តលើមណ្ឌលនេះទៅមុខទៀត។

## រសៀលថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៤

## សំរបសំរួលដោយ លោក អ៊ុំ រតនា

នាពេលរសៀលថ្ងៃទី ១៩ លោក John បានឡើងធ្វើការបង្ហាញពីសមាជិកភាព ហើយលោក អ៊ុំ រតនា ជាអ្នកបកប្រែ។ ក្នុងនោះដោយយោងទៅដល់ការលំបាកកន្លងមក លោកបានធ្វើការបែងចែកសមាជិកភាពជាពីរប្រភេទគឺ ***Key Members*** និង ***Associate Members.***

- ❖ ***Key Members:*** គឺជាសមាជិកសកម្មដែលអាចធ្វើការសំរេចចិត្តលើសកម្មភាព ហើយមានតែអង្គការក្នុងស្រុកប៉ុណ្ណោះដែលអាចចូលជាសមាជិក។
- ❖ ***Associate Members:*** គឺជាសមាជិកគាំទ្រ ដែលមានសិទ្ធិត្រឹមតែចូលរួមសកម្មភាព និងទទួលការសិក្សាប៉ុណ្ណោះ តែមិនមានសិទ្ធិធ្វើការសំរេចចិត្តនោះទេ។ អ្នកចូលជាសមាជិកអាចជាអង្គការក្នុងស្រុក និងអង្គការអន្តរជាតិ។

**ឧទាហរណ៍:** ដូចជាការជ្រើសរើស គណៈកម្មការនាយកជាដើម មានតែសមាជិកសកម្មទេដែលមានសិទ្ធិក្នុងការជ្រើសរើស តែសមាជិកគាំទ្រអាចមានសិទ្ធិចូលរួមក្នុងដំណើរការ ហើយនិងវគ្គសិក្សាផ្សេងៗ។ សមាជិកសកម្មមានភារកិច្ចចូលរួមក្នុងអនុគណៈកម្មការ និងជួយដល់សមាជិកគាំទ្រ។ ចំពោះហេតុផលដែលគេបង្កើតអោយមានប្រព័ន្ធថ្មីនេះ គឺដោយសារ កូសេកាំ បង្កើតឡើងដោយអង្គការក្នុងស្រុកផង និងអង្គការអន្តរជាតិចូលរួមផង។

តើអ្នកទាំងអស់គ្នាយល់ស្របឬទេ? បើយល់ស្របហើយ សូមធ្វើការសំរេចចិត្ត ថាតើអង្គការរបស់លោកអ្នកត្រូវចូលទៅក្នុងសមាជិកប្រភេទមួយណា?

### សំនួរ និងចំលើយ:

**Q. តើអង្គការដែលចូលជាសមាជិកថ្មី ត្រូវចូលសមាជិកមួយណា? អាចចូលជាសមាជិកសកម្មដែរឬទេ?**

- អង្គការដែលចូលជាសមាជិកថ្មីអាចចូលត្រឹមតែជាសមាជិកគាំទ្រ (associate members) ប៉ុណ្ណោះលុះដល់ពេលដែលយើង ធ្វើការពិនិត្យមើលឃើញថាមានលក្ខណៈគ្រប់គ្រាន់ហើយ ទើបអាចចូលជាសមាជិកសកម្មបាន ហើយអង្គការនោះត្រូវតែមានធនធានគ្រប់គ្រាន់ផងដែរ។ បើអង្គការថ្មីធ្វើអ្វីមួយខុសនោះគណៈកម្មការនាយកអាចដកអង្គការនោះចេញបាន។

**Q. តើយើងមានលក្ខណៈវិនិច្ឆ័យដូចម្តេចចំពោះអង្គការនិមួយៗថា ជាអង្គការអន្តរជាតិ រឺអង្គការក្នុងស្រុក?**

- គឺយើងមើលទៅលើប្រធានរឺអ្នកតំណាង បើអ្នកនោះជាជនបរទេសនោះ វាជាអង្គការអន្តរជាតិ។

**Q. តើ កូសេកាំ ចង់អោយអង្គការអន្តរជាតិក្លាយជាសមាជិកពេញសិទ្ធិដែររឺទេ?**

- គេអាចជាសមាជិកបាន តែក្នុងករណីនេះ អាចត្រឹមតែជាសមាជិកគាំទ្រប៉ុណ្ណោះ ។ ហើយចំពោះអង្គការសមាជិកចាស់ បើមិនអាចចូលរួមប្រជុំបានទេនោះ គេអាចដកខ្លួនមកត្រឹមជាសមាជិកគាំទ្រវិញក៏ បានដែរ

**Q. ចំពោះអ្នកដែលបានមកចូលរួមនេះ បើគាត់មិនមែនជាប្រធាន តើគាត់អាចធ្វើការសំរេចចិត្តបានដែររឺទេ?**

- ចំពោះអង្គការ អាដហុក អ្នកណាក៏ដោយដែលមកចូលរួម គាត់មានសិទ្ធិក្នុងការសំរេចចិត្តបាន តែក្នុងករណីធ្ងន់ធ្ងរ គាត់ត្រូវសុំយោបល់ពីប្រធានសិនដែរ។ (ចំលើយរបស់បុគ្គលិកអាដហុក)

## ការធ្វើការបោះឆ្នោត ដើម្បីសំរេចលើទំរង់ប្រព័ន្ធសមាជិកភាព

បន្ទាប់មកមានការធ្វើការបោះឆ្នោត ដើម្បីជ្រើសរើសប្រព័ន្ធសមាជិក ហើយលទ្ធផលទទួលបានក្នុងចំណោមអ្នកដែលចូលរួមទាំងអស់ ១២ អង្គការ គឺមានការយល់ស្របចំនួន ១១ អង្គការ ហើយមួយមិនយល់ស្រប។ ការបោះឆ្នោតនោះគឺធ្វើឡើងតាមប្រព័ន្ធ ៥០ បូក ១។ នៅក្នុងពេលនោះ លោក សុខ សំអឿន បានសុំអោយលើកក្រោយបើមានការធ្វើការបោះឆ្នោតទៀត សូមអោយយកទំរង់រូបមន្ត ២/៣ កុំអោយយកទំរង់ ៥០ បូក ១ ។

**បញ្ជាក់:** ការដែលយើងបានកំនត់អោយមានប្រព័ន្ធថ្មីនេះគឺ ដើម្បីផ្តល់ភាពងាយស្រួលនៅក្នុងការចាត់ចែងការងារ និង ដើម្បីផ្តល់ឱកាសអោយសមាជិកមួយចំនួន ដែលគាត់មិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមប្រជុំជ្រើសរើសប្រភេទ Member ដើម្បីចូលរួមទៅតាមលទ្ធភាព។

## ការបង់ថ្លៃវិភាគទានរបស់សមាជិកភាព

ក្រៅពីនោះអង្គប្រជុំបានធ្វើការពិភាក្សាពីការបង់វិភាគទានសំរាប់សកម្មភាពការងាររបស់សម្ព័ន្ធ តែពេលនោះអ្នកដែលចូលរួមមិនអាចធ្វើការសំរេចចិត្តបានដោយអ្នកចូលរួមមួយចំនួនមិនមែនជាប្រធានអង្គការហើយបានសំរេចអោយអ្នកចូលរួមទាំងនោះ ទៅធ្វើការពិភាក្សាជាមួយប្រធានហើយផ្តល់ពត៌មានជាក្រោយ ។

ចំពោះបញ្ហានេះ លោក John បានធ្វើការបញ្ជាក់ថា បើយើងនិយាយពីលុយនោះ វាមានការលំបាកសុំលុយពីអ្នកណា រឺអង្គការណានោះណាស់ ហើយពីមុនមកសមាជិកទាំងអស់គេបានសុំកុំអោយមានការយកលុយពីសមាជិក តែពេលធ្វើសំណើរទៅអោយម្ចាស់ជំនួយគេតែងតែសួរថា តើសមាជិកបានចំណាយអ្វីខ្លះ ក្នុងការចូលរួមនេះ ហើយម្ចាស់ជំនួយគេតែងតែមានការជំទាស់ទៅលើបញ្ហានេះ ហេតុនេះហើយទើបយើងសុំអោយសមាជិកជួយចូលរួមវិភាគទានវិញ។ ហេតុនេះគាត់សង្ឃឹមថា អ្នកចូលរួមទាំងអស់មានការយោគយល់។ ចំពោះប្រាក់វិភាគទាននេះ កូសេកាំ បានសុំអោយអង្គការសមាជិកផ្តល់តែ ១00 ដុល្លាប៉ុណ្ណោះ សំរាប់សកម្មភាពមួយឆ្នាំ។

### លោក សុខ សំអឿន

ចំពោះបញ្ហានេះ សូមអោយកូសេកាំជួយលើកបញ្ហានេះទៅ donors ផង។ ការបង់រឺមិនបង់វិភាគទាននោះ សូមអោយធ្វើការគិតពិចារណាមើលថា តើលុយនោះគេយកទៅណា? សំរាប់ធ្វើអ្វី? ហើយអ្នកណាមានសិទ្ធិចំណាយ?លុយនោះអាចទុកជាប្រាក់សន្សំ ហើយមិនប៉ះពាល់បានទេ? ហើយយើងធ្វើការសន្សំអោយបានច្រើនហើយបើអង្គការណាមួយមានភាពខ្វះខាត យើងអាចទុកសំរាប់ជួយអ្នកនោះបានទេ?

បន្ទាប់ពីការជជែកគ្នាមួយរយៈមក ហើយមិនបានសំរេចតាមអ្វីដែលចង់បាននោះ មានសំនួរពីរដែលលើកឡើង។

**ទី ១ :** តើបណ្តាញសមាជិកទាំងអស់មិនមានលទ្ធភាពបង់លុយ រឺ យ៉ាងណា?

**ទី ២ :** តើកូសេកាំ អាចរក្សាលុយនោះទុកក្នុងប្រព័ន្ធ Special Saving ដោយមិនមានប៉ះពាល់លុយនោះបានដែររឺទេ?

## ការដាក់ពាក្យសុំចូលជាសមាជិកភាព

### នីតិវិធីនៃការដាក់ពាក្យរបស់អ្នកចូលជាសមាជិកថ្មី

ចំពោះអង្គការថ្មី បើចង់ដាក់ពាក្យចូលជាសមាជិកថ្មីត្រូវមានលក្ខណ្ឌដូចខាងក្រោម:

- សរសេរពីកម្មវិធីគំរោង និងរចនាសម្ព័ន្ធរបស់អង្គការរបស់ខ្លួនអោយច្បាស់លាស់ ហើយធ្វើការដាក់ពាក្យមកកូសេកាំ។

- កូសេកាំទទួលពាក្យ ហើយធ្វើការពិនិត្យសំរាំង
- ត្រូវរកអ្នកធានាពីរអង្គការនៅក្នុងសម្ព័ន្ធកូសេកាំផ្ទាល់
- ធ្វើការបង្ហាញពីសកម្មភាពរបស់ខ្លួនដល់សមាជិកចាស់ពិនិត្យមើល
- ធ្វើការបោះឆ្នោតជាសំងាត់ដោយសមាជិកចាស់

**បញ្ជាក់:** អង្គការដែលដាក់ពាក្យ ត្រូវមានការយល់ព្រមពីសមាជិកចាស់ទាំងអស់ដែលមានវត្តមាន។ បើមានអង្គការណាមួយមិនយល់ស្រប អង្គការនេះមិនអាចចូលជាសមាជិកឡើយ។ ម្យ៉ាងទៀត បើអ្នកធានាមិនបានមកទេនោះ អ្នកសុំចូលនោះមិនអាចចូលបានទេ ព្រោះគេត្រូវការសួរអ្នកធានានូវពត៌មានផ្សេងៗ។

លោក សុខ សំអឿន បានបញ្ជាក់ថា បើយើងសំរេចទៅលើអ្វីមួយហើយគឺ យើងត្រូវតែធ្វើ។ បើមិនមានការថែងនៅក្នុងបទបញ្ជាក៏ដោយ ហើយសុំអោយយកការកត់ត្រាជាគោលវិភស្តុតាង។

លើសពីនេះទៅទៀត លោក សុខ សំអឿន បានសុំអោយកូសេកាំចេញថវិការជាសាហ៊ុយអោយអង្គការផ្សេងៗដែលចុះទៅស៊ើបអង្កេតពីករណីផ្សេងៗ ពិសេសទាក់ទងនឹងការសិក្សាអោយបានច្បាស់លាស់ពីប្រព័ន្ធអង្គភាពសហជីវិនថ្មី ហើយកូសេកាំក៏បានយល់ស្រប។

## ការបង្ហាញរបស់អង្គការដែលសុំចូលជាសមាជិក

### ១. អង្គការអភិវឌ្ឍន៍កុមារ និងផលពិការកម្ពុជា (CCHDO)

ដោយលោក ភា សារុន អ្នកសំរបសំរួលកម្មវិធី

### ប្រវត្តិអង្គការ

អង្គការបានចុះបញ្ជី និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ១៩៩៧ ដោយមានគោលបំណងធ្វើការលប់បំបាត់ការជួញដូរកំលាំងពលកម្មកុមារ ការការពារកុមារអោយផុតពីការប្រើប្រាស់ថ្នាំញៀន និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល និងសហគមន៍ដែលងាយរងគ្រោះតាមរយៈការផ្តល់ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ប្រជាពលរដ្ឋនៅប៉ោយប៉ែតរយៈពេល ៧ឆ្នាំ មកហើយ។ អង្គការធ្លាប់ជាសមាជិករបស់បណ្តាញក្រុមប្រឹក្សាភិបាលគ្រប់គ្រងអង្គការនៅខេត្តបន្ទាយមានជ័យ និងគណៈកម្មការការពារកុមារនិងស្ត្រីនៅខេត្តបន្ទាយមានជ័យ។ មានបុគ្គលិកចំនួន ២៩ នាក់ រួមទាំងបុគ្គលិកម្នាក់មកពីក្រសួងមហាផ្ទៃម្នាក់មកពីការិយាល័យទំនាក់ទំនងព្រំដែនថៃ-កម្ពុជា និងពីរនាក់មកពីក្រសួងអប់រំ និងម្នាក់មកពីក្រសួងសង្គមកិច្ច។

## បេសកកម្ម

CCHDO គឺជាអង្គការដែលមិនរកប្រាក់កំរៃ មិនទាក់ទងទៅនឹងរឿងនយោបាយ និងជាអង្គការមិនមែនរដ្ឋាភិបាល។ សកម្មភាពរបស់អង្គការ គឺដើម្បីធ្វើអោយស្ថានភាពសេដ្ឋកិច្ចគ្រួសារដែលមានស្ត្រីជាមេគ្រួសារកុមាររងគ្រោះពីការជួញដូរកុមារដែលកំពុងធ្វើការអោយមានភាពប្រសើរឡើង តាមរយៈការផ្តល់អប់រំការបណ្តុះបណ្តាលវិជ្ជាជីវៈ, ឥណទានប្រាក់កម្ចី, ការប្រឹក្សាយោបល់ និងអប់រំក្រៅប្រពន្ធ័។

## គោលដៅ

ការពារកុមារ និងស្ត្រីដែលរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ តាមរយៈការផ្តល់ការអប់រំការបណ្តុះបណ្តាលវិជ្ជាជីវៈ ឥណទានប្រាក់កម្ចី ការប្រឹក្សាយោបល់ និងអប់រំក្រៅប្រពន្ធ័ដល់កុមារស្ត្រីរងគ្រោះកុមារកំព្រាលើកកំពស់ការយល់ដឹងពីសិទ្ធិមនុស្ស ជាពិសេសសិទ្ធិកុមារ និងស្ត្រី។

លើកកំពស់ការយល់ដឹង និងការបង្កាទប់ស្កាត់ការប្រើប្រាស់ថ្នាំញៀន និងការរីកសាយជំងឺអេដស៍ តាមរយៈការផ្តល់អប់រំការបណ្តុះបណ្តាលវិជ្ជាជីវៈ ឥណទានប្រាក់កម្ចី ការប្រឹក្សាយោបល់ និងអប់រំក្រៅប្រពន្ធ័ដល់កុមារ ឪពុកម្តាយកុមារ និងអាណាព្យាបាលរបស់កុមារដែលងាយរងគ្រោះ។

## គោលបំណង

១. ការពារកុមារពីការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទ និងកំលាំងពលកម្ម និងការជួញដូរសាជាថ្មី

២. ការពារកុមារដែលធ្វើដំណើរមកពីប្រទេសថៃ និងអ្នកដែលធ្វើការនៅតាមព្រំដែនថៃ

៣. ជួយសំរួលដល់ការធ្វើសមាហរណកម្មកុមារដែលត្រូវបានគេធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ

៤. ផ្តល់ការអប់រំពីសិទ្ធិមនុស្ស ដែលផ្តោតសំខាន់ទៅលើសិទ្ធិស្ត្រី កុមារ និង យេនឌ័រ

៥. លើកកំពស់ការយល់ដឹងអំពីការប្រើប្រាស់ថ្នាំញៀន និងឥទ្ធិពលច្បាប់បង្រ្កាបថ្នាំញៀន កំលាំងយោធា និង អាជ្ញាធរមូលដ្ឋាន។

៦. ធ្វើការអប់រំដល់អ្នកប្រើប្រាស់ថ្នាំញៀន និងជនដែលទទួលរងគ្រោះដោយថ្នាំញៀន តាមរយៈការផ្តល់ការពិគ្រោះយោបល់ និងការផ្តល់សេវាព្យាបាលសុខភាព។

៧. ធ្វើយ៉ាងណាអោយមាននិរន្តភាពផ្នែកអប់រំបន្ទាប់ពីគំរោងត្រូវបានបញ្ចប់

## ក្រុមអ្នកទទួលផលក្នុងតំបន់គោលដៅ

**កំរិតទី ១** : កុមាររងគ្រោះដោយការជួញដូរ ការកេងប្រវ័ញ្ចកំលាំងពលកម្ម និង ការប្រើប្រាស់ថ្នាំញៀន

**កំរិតទី ២** : សមាជិកសហគមន៍ និងសិស្សសាលា

**កំរិតទី ៣** : បុគ្គលិកមន្ត្រីរាជការរបស់រដ្ឋាភិបាល

### តំបន់គោលដៅ

ផ្តោតទៅលើតំបន់នៅក្នុងស្រុក អូជ្រៅ ស្រុកម៉ាឡៃ និងស្រុកសេរីសោភណ្ឌ័។

### ម្ចាស់ជំនួយ

ចំពោះម្ចាស់ជំនួយ កន្លងមកយើងមានជំនួយពី Unicef, AusAID, UNOPS, UNODCP, និង DFID

### សំនួរ និងចំលើយ

Q. **តើអង្គការធ្លាប់ចូលជាសម្ព័ន្ធជាមួយអង្គការណាដែរឬទេ?**

- យើងធ្លាប់ចូលជាសមាជិករបស់អង្គការនៅខេត្តបន្ទាយមានជ័យ។

Q. **តើអង្គការមានថវិការសរុបចំនួនប៉ុន្មាន?**

- មិនហ៊ានឆ្លើយ ព្រោះមិនបានដឹងច្បាស់ បើតាមការស្មានប្រហែលជា ៦០ ០០០ ដុល្លា។

Q. **តើមានម្ចាស់ជំនួយពីណាខ្លះ?**

- មាន AUSAID, UNICEF

Q. **តើអង្គការមានបានចុះ** MoU **ដែរឬទេ?**

- យើងមានការចុះ MoU ជាមួយក្រសួងមហាផ្ទៃ។

## ២. ការបង្ហាញរបស់ អង្គការកុមារកម្ពុជានៃក្តីសង្ឃឹម (CHO)

អង្គការបានចាប់ផ្តើមនៅខែ មិថុនា ឆ្នាំ ២០០២ ដែលមានបុគ្គលិកពេញសិទ្ធិ ១៥នាក់ និងបុគ្គលិកស្ម័គ្រចិត្តចំនួន ២០នាក់ និងគណៈកម្មការនាយក ៧នាក់ ហើយក្នុងនោះមានអ្នកជំនាញការ ៣នាក់ និងមានទីប្រឹក្សាមកពីប្រទេសថៃ។

### តំបន់គោលដៅ

អង្គការធ្វើសកម្មភាពនៅអូបីជាន់ ស្រុកម៉ាល័យ និង ប៉ៃលិន។ ទៅអនាគតអង្គការមានគំរោងពង្រីកសកម្មភាពថែមទៀត តែម្ចាស់ជំនួយមិនទាន់បានយល់ព្រម។ ចំពោះការរកកំរៃ យើងមានការចុះកុងត្រាធ្វើកំរាលព្រំជាមួយក្រុមហ៊ុនថៃ ដែលមានតំលៃ ១ម$^{២}$ មានតំលៃ ៥០០ បាតប្រាក់ថៃ។ ចំពោះការចងបណ្តាញអង្គការយើងមានបណ្តាញនៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ និងមានទំនាក់ទំនងការងារជាមួយអង្គការនៅក្នុងប្រទេសថៃ និងបានចូលរួមសកម្មភាពជាមួយ កូសេកាំ ។

## សកម្មភាព

- អប់រំការទប់ស្កាត់ការជួញដូរកុមារ និង អប់រំពីជំងឺអេដស៍
- ការផ្តល់ការអប់រំផ្នែកវិជ្ជាជីវៈ ដូចជាកាត់ដេរ កំព្យូទ័រ និងជួសជុលម៉ូតូ
- ការផ្តល់ការអប់រំពីវិធីធ្វើម្ហូប និងមានបើកជាភោជនីយដ្ឋានសំរាប់លក់ជូនអតិថិជនផងដែរ
- ការធ្វើការថែរក្សាអ្នកផ្ទុកមេរោគអេដស៍នៅតាមផ្ទះ
- កម្មវិធីរកប្រាក់ចំណូល

## ជំនួយមូលនិធិ

អង្គការទទួលបានជំនួយពីម្ចាស់ជំនួយចំនួន ៣ គឺ Teafund UK, Geneva Global, and USDA. និងមានសប្បុរសជនផ្តល់ជំនួយផ្សេងៗទៀត។ មានថវិការសរុបចំនួន ១៦ ម៉ឺនដុល្លាកាលពីឆ្នាំមុន ហើយឆ្នាំបន្ទាប់មាន ១៩ ម៉ឺនដុល្លា។

## សំនួរ និងចំលើយៈ

Q. **អង្គការនេះជាអង្គការគ្រីស្ទ តើបុគ្គលិកត្រូវជ្រើសយកតែអ្នកកាន់សាសនានោះ រឺក៏រើសអ្នកដែលមិនមែនជាគ្រីស្ទសាសនិកដែរ?**

- ទោះបីវាជាអង្គការដែលផ្តល់ជំនួយដោយគ្រីស្ទសាសនាក៏ដោយ ការធ្វើសកម្មភាពរីការរើសបុគ្គលិកនោះ មិនមែនយកតែអ្នកកាន់សាសនានេះនោះទេ និងមិនមានការបង្ខិតបង្ខំថាត្រូវតែចូលនោះដែរ។

Q. **តើនៅអង្គការផ្ទាល់មានរៀបចំជាទីសក្ការៈបូជាសំរាប់គ្រីស្ទសាសនិកដែររឺទេ?**

- មិនមានទីសក្ការៈបូជានៅកន្លែងអង្គការនោះទេ។

## ៣. ការបង្ហាញរបស់អង្គការ អនាគតកុមារ ANAKOT KUMAR (AK)

ចំពោះការបង្ហាញរបស់អង្គការអនាគតកុមារមានដូចខាងក្រោមៈ

## ប្រវត្តិអង្គការ

អង្គការមានទីតាំងនៅភ្នំក្រវ៉ាញ ខេត្តពោធិសាត់ ហើយកាលពីអតីតៈ គឺជាដៃគូររបស់អង្គការ SKIP ។ អង្គការបានចុះ MoU ជាមួយក្រសួងមហាផ្ទៃនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០០២ ហើយបានផ្តាច់ពីអង្គការវឌ្ឍនភាព នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៣។

ជាអង្គការដែលមិនបំរើផលប្រយោជន៍នយោបាយ និងមិនប្រកាន់សាសនាគឺ ដើម្បីបំរើការអភិវឌ្ឍន៍សហគមន៍ និងអនុវត្តសិទ្ធិកុមារនៅកម្ពុជា ។ **ចក្ខុវិស័យៈ** សហគមន៍ កសាងកម្ពុជា

## បេសកម្ម

រួមចំណែកជួយធ្វើអោយប្រសើរឡើងនូវឱកាសកុមារដែលស្ថិតនៅក្នុងស្ថានភាពលំបាកគឺ គ្រួសារដែលមិនមានស្បៀងអាហារគ្រប់គ្រាន់សំរាប់រយៈពេលមួយឆ្នាំ។ លើកទឹកចិត្ត និងជួយអោយមានការរីកចំរើនលើការអនុវត្តន៍សិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

**គោលដៅ:** លើកកំពស់ជីវភាពរស់នៅរបស់សហគម ជាពិសេសកុមារស្ថិតនៅក្នុងសភាពរងគ្រោះ។

**ទិសដៅ:** លើកស្ទួយការរស់នៅរបស់កុមារដែលស្ថិតនៅក្នុងស្ថានភាពលំបាក តាមរយៈការផ្តល់ជំនាញ និងការសិក្សាពង្រឹងសមត្ថភាពសហគមន៍ និងកាត់បន្ថយភាពរងគ្រោះរបស់កុមារបង្កើនទំនាក់ទំនង និងបណ្តាញការងារជាមួយអង្គការជាតិ និងអន្តរជាតិ ស្ថាប័នរដ្ឋ និងសប្បុរសជន។

## កម្មវិធី

កម្មវិធីអភិវឌ្ឍន៍កុមារដោយយកសហគមន៍ជាមូលដ្ឋាន ដែលក្នុងនោះយើងមានកម្មវិធីតូច២ពីរទៀតគឺ:

- **កម្មវិធីអភិវឌ្ឍន៍កុមារ:** មានអ្នកសំរបសំរួលម្នាក់ សំរាប់ធ្វើការសំរបសំរួលដល់ការផ្តល់ការអប់រំទូទៅ (ថ្នាក់មត្តេយ្យ និងបឋម) និងការបណ្តុះបណ្តាលវិជ្ជាជីវៈ (សំរាប់មនុស្សធំ)។ ការអប់រំគឺ យើងផ្តោតទៅលើការអប់រំក្រៅប្រព័ន្ធដែលស្ថិតនៅតំបន់ដាច់ស្រយាល។

  **ផ្នែកសិទ្ធិកុមារ និងសុខមាលភាពសង្គម:** មានបុគ្គលិកចំនួន ៣នាក់ជាអ្នកទទួលខុសត្រូវធ្វើការងារនេះ

- **កម្មវិធីអភិវឌ្ឍន៍សហគមន៍:** មានពីរផ្នែកគឺ ផ្នែករកប្រាក់ចំណូល និង ការរៀបចំសហគមន៍។

### រចនាសម្ព័ន្ធរបស់អង្គការ



# ៤. ការបង្ហាញរបស់អង្គការកុមារឥតព្រំដែន (KnK)

## ៤-១ តើអង្គការកុមារឥតព្រំដែនជាអ្វី?

អង្គការឥតព្រំដែន (KnK) គឺជាអង្គការក្រៅរដ្ឋាភិបាល (NGO) នៃប្រទេសជប៉ុន ដែលបានបង្កើតដោយអង្គការ (MSF Medecins Sans Frontieres) នៃប្រទេសជប៉ុននៅឆ្នាំ ១៩៩៧ ដែលមានគោលបំណងបង្កើតអោយមានភាពស្មើគ្នារវាងកុមារនៅលើពិភពលោកហើយ និងពង្រីកការរស់នៅរបស់កុមារដែលក្រលំបាកហើយមានការសិក្សាតិចតួច។ ទីស្នាក់ការធំរបស់កុមារឥតព្រំដែនគឺនៅប្រទេសជប៉ុន ហើយបច្ចុប្បន្ននេះមានសាខាចំនួន ៣ នៅក្រៅប្រទេសគឺ កម្ពុជា ប្រទេសហ្វីលីពីន និងប្រទេសវៀតណាម។ មានបុគ្គលិកពេញសិទ្ធិចំនួន ១៤នាក់ (ជនជាតិជប៉ុន ២នាក់) និងមានបុគ្គលិក ៤នាក់ផ្សេងទៀតដែលជាអ្នកធ្វើការទាក់ទងទៅនឹងព័ន្ធធនាគា។

## ៤-២ ព្រឹត្តិការណ៍

ដំណោះដែលប្រសើរគឺ ត្រូវតែយកចិត្តទុកដាក់ចំពោះកុមារ និងយុវវ័យទាំងអស់ ដែលរងនៅការលំបាកផ្សេងៗ កាលពីអតីតកាលរបស់ពួកគេ។ ដើម្បីអោយសំរេចបាននូវគោលបំណងខាងនេះ អង្គការរបស់កុមារឥតព្រំដែន (KnK) បានបើកបេសកកម្មរបស់ខ្លួននៅកម្ពុជា កាលពី ខែកញ្ញា ឆ្នាំ២០០០ ដោយផ្តល់កន្លែងស្នាក់នៅម្ហូបអាហារ និងតម្រូវការជាមូលដ្ឋានដល់យុវវ័យទាំងនោះ (ផ្ទះយុវវ័យ)

## ៤-៣ កម្មវិធីនៅប្រទេសកម្ពុជា

**ផ្ទះយុវវ័យនៅខេត្តបាត់ដំបង និងនៅភ្នំពេញ**

បច្ចុប្បន្ននេះអង្គការកុមារឥតព្រំដែនបានកំពុងជួយឧបត្ថម្ភដល់កុមារចំនួន ៦០នាក់ ដែលពីមុនពួកគេធ្លាប់ប្រឈមមុខគ្រោះថ្នាក់ ហើយត្រូវការសេវាកម្មគាំទ្រជាចាំបាច់។ អង្គការកុមារឥតព្រំដែនបានផ្តល់នូវការអប់រំជាមូលដ្ឋាន ហើយនិងវិជ្ជាជីវៈផ្សេងៗ ព្រមទាំងសេវាកម្មចិត្តសាស្រ្តផងដែរ។

## ៤-៤ ការគ្រប់គ្រងផ្ទះយុវជន័យ

**ការទទួលយក**

ការផ្តល់សេវាអប់រំ និងការអប់រំក្រៅប្រពន្ធ័

- ការអប់រំក្នុងប្រពន្ធ័ និងការអប់រំក្រៅប្រពន្ធ័
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការថែរក្សាសុខភាព
- ផ្តល់ពិគ្រោះយោបល់ចិត្តសាស្រ្តសង្គម
- ការអភិវឌ្ឍន៏បំណិតជីវិត

- កម្មវិធីពង្រឹងចំណេះដឹង
- សកម្មភាពនៃការកំសាន្តនានា
- លើកកំពស់នៃការធ្វើសមាហរណកម្ម
- ការស្វែងយល់គ្រួសារ
- ការផ្សះផ្សារជាមួយគ្រួសារ
- ការទាក់ទងជាមួយសហគមន៍
- ការគ្រប់គ្រងលើជំនាញការងាររកស៊ី
- កន្លែងធ្វើការ គ្រោងការអោយខ្ចីប្រាក់
- ការធ្វើសមាហរណកម្មទៅក្នុងសង្គម
- តាមដាន និងត្រួតពិនិត្យ

## ៤-៥ ទិសដៅផ្ទះយុវជន័យ

ជួយបំពេញនូវការខ្វះខាតរបស់ក្មេងអានាថា និងយុវវ័យដែលនឹងងាយរងគ្រោះ ក្នុងអំឡុងពេលដែលគេកំពុងផ្លាស់ប្តូរទៅនៅជាមួយមនុស្សពេញវ័យបន្ទាប់មកគេធ្វើសមាហរណកម្មទៅសហគមន៍វិញ អោយពួកគេអាចរស់នៅដូចប្រជាជនដ៏ទៃទៀតដែរ ។

គាំទ្រចំពោះការធ្វើសមាហរណកម្មយុវវ័យដែលងាយនិងរងគ្រោះ តាមរយៈបង្កើនការយល់ដឹងនូវបញ្ហារបស់យុវវ័យ និងកុមារអនាថាដែលបានជួបប្រទះ ដោយសហការជាមួយអាជ្ញាធរដែនដី ដើម្បីធ្វើអោយប្រសើរឡើងនូវសមត្ថភាពយល់ដឹងដល់ថ្នាក់សហគមន៍ និងអង្គការនានាដែលកំពុងមានសេវាគាំទ្រ។

# ៥.ការបង្ហាញរបស់អង្គការកុមារនៃក្តីសង្ឃឹម (KNKS)

## ប្រវត្តិអង្គការ

អង្គការកុមារនៃក្តីសង្ឃឹមគឺ អតីតកម្មវិធី 205 របស់អង្គការវឌ្ឍនៈភាព ក្នុងខេត្តពោធិសាត់ប្រចាំស្រុកកណ្តៀង អង្គការនេះត្រូវបានគេផ្ទេរឱ្យទៅជាអង្គការក្នុងស្រុកមួយនៅ ខែមករា ឆ្នាំ ២០០៣ ជាផ្លូវការដោយអង្គការវឌ្ឍនៈភាព និងបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ។ អង្គការកុមារនៃក្តីសង្ឃឹមមានម្ចាស់ជំនួយធំគឺ មូលនិធិប៉េស្តាឡូហ្ស៊ី ដែលហៅកាត់ថា ស្ពីប ប្រចាំប្រទេសស្វីស និងម្ចាស់ជំនួយបន្ទាប់ពីគឺ អង្គការឌីអ៊ីឌី និងស្ថានទូតជប៉ុន។ នៅក្នុងឆ្នាំ ២០០៤ នេះ អង្គការមានថវិកាសំរាប់ចំណាយចំនួនប្រមាណ ១៦០ ០០០ ដុល្លា។

សហគមន៍កសាងប្រទេសកម្ពុជា ចូលរួមជំរុញការអភិវឌ្ឍន៍ សិទ្ធិកុមារក្នុងប្រទេសកម្ពុជាធ្វើអោយប្រសើរឡើងនូវឱកាសរបស់កុមារដែលស្ថិតក្នុងស្ថានភាពលំបាក និងគ្រួសាររបស់គេ តាមរយៈការសំរបសំរួលធ្វើអោយសហគមន៍ក្លាយជាម្ចាស់លើកការផ្តួចផ្តើមគំនិត និងអនុវត្តន៍គ្រប់សកម្មភាពអភិវឌ្ឍន៍ដោយខ្លួនឯង។

## តំបន់គោលដៅក្នុងឆ្នាំ២០០៤

| ទីតាំង | ចំនួនឃុំសរុប | ចំនួនឃុំគោលដៅ | ភូមិសរុប | ភូមិគោលដៅ |
|---|---|---|---|---|
| ស្រុកកណ្តៀង | ៩ | ៧ | ១១២ | ២៨ |

## គោលបំណង និងសកម្មភាពរបស់កម្មវិធី

### ការអភិវឌ្ឍន៍កុមារ

#### ១- ផ្នែកអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- កុមារដែលមានអាយុចូលរៀនចាប់ពី បួនឆ្នាំ បានចូលរៀននៅសាលាសហគមន៍ និងសាលារដ្ឋ
- កុមារឬយុវវ័យ ដែលស្ថិតនៅក្នុងគ្រួសារក្រីក្រ ចាប់តាំងពីអាយុ ១៥-១៨ ឆ្នាំ មានឱកាសរៀនជំនាញវិជ្ជាជីវៈដែលផ្សារភ្ជាប់ទៅនិងតំរូវការទីផ្សារ និង ឱកាសការងារ
- សិស្សដែលបញ្ចប់ការសិក្សាជំនាញ យ៉ាងហោចណាស់ ៨៥ភាគរយ មានជោគជ័យក្នុងការងារ និងប្រកបមុខរបរចិញ្ចឹមជីវិតបាន។
- សំរបសំរួលអោយមានគណៈកម្មការអប់រំសហគមន៍ និងគណៈកម្មការមាតាបិតាសិស្ស និងគ្រូសហគមន៍
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិធីសាស្ត្របង្រៀនដល់គ្រូសហគមន៍ គ្រូជំនាញ
- ផ្តល់ការបណ្តុះបណ្តាលផ្នែកការចាត់ចែង និងគ្រប់គ្រង ដល់គណៈកម្មការអប់រំសហគមន៍
- សំរបសំរួលអោយមានកម្មវិធីអប់រំក្រៅប្រពន្ធ័ក្នុងសហគមន៍ និងសាលារដ្ឋ
- ជួយគាំទ្រអាហាររូបករណ៍ដល់សិស្សស្រី ដែលជាកូនគ្រួសារក្រីក្រលំបាកអោយបានបន្តការសិក្សាដល់ថ្នាក់អនុវិទ្យាល័យ ( ពីថ្នាក់ទី៥-៩)
- សំរួលអោយមានប្រារព្ធទិវាអក្ខរកម្មថ្ងៃ ៨កញ្ញា នៅតាមសហគមន៍
- សំរបសំរួលអោយមានការត្រួតពិនិត្យ និងជួយជំរុញពីគណៈកម្មការអប់រំសហគមន៍ដល់កុមារ ដែលបោះបង់ការសិក្សារៀនសូត្រ
- សំរបសំរួលអោយមានសេវាកម្ម បណ្ណាល័យចល័តភូមិ

## ២- ផ្នែកសិទ្ធិកុមារ និងសុខមាលភាពសង្គម

- សិទ្ធិកុមារ និងការថែរក្សាសុខភាពជាបឋមត្រូវបានយល់ដឹង និងអនុវត្តន៍នៅតាមគ្រួសារ និងសហគមន៍
- កុមារដែលស្ថិតនៅស្ថានភាពលំបាកបានទទួលការការពារពីភាពរងគ្រោះទាំងឡាយ ដោយសុវត្ថិភាព និង ទទួលសេវាកម្មសង្គមការអន្តរាគមន៍ និងការយល់ដឹងពីសិទ្ធិកុមារនៅតាមសហគមន៍របស់គេ។
- កុមារ និងគ្រួសារដែលស្ថិតក្នុងស្ថានភាពក្រលំបាកបានទទួលសេវាកម្មសុខភាពឃុំ និងមន្ទីរពេទ្យរដ្ឋ ដោយយកចិត្តទុកដាក់។
- បង្កើតអោយមានគណៈកម្មការទទួលខុសត្រូវផ្នែកសុខមាលភាពសង្គម ហើយមានជនសកម្ម និង ក្រុមឃ្លាំមើល ហើយនិងក្លឹបយុវជនក្នុងសហគមន៍ និងធ្វើការបណ្តុះបណ្តាលដល់ពួកគេ។
- បណ្តុះបណ្តាលសមត្ថភាពគណៈកម្មការទទួលសុខមាលភាពសង្គម ពីការគ្រប់គ្រងចាត់ចែងឥណទាន និងការត្រួតពិនិត្យសេវាកម្មសង្គម និងការអនុវត្តន៍សិទ្ធិកុមារ និងសុខភាពជាបឋមក្នុងសហគមន៍ ។
- សំរបសំរួលអោយមានទុនសុខមាលភាពសង្គមក្នុងសហគមន៍
- សំរបសំរួលអោយមានទិវាសិទ្ធិកុមារ និងទិវាអនាម័យភូមិ ទិវាដាំដើមឈើ និងទិវាយល់ដឹងពីអេដស៍ នៅតាមសហគមន៍។

## កម្មវិធីអភិវឌ្ឍន៍សហគមន៍

### ❖ ផ្នែកមុខរបរ និងប្រាក់ចំណូល

- សេវាកម្មឥណទានខ្នាតតូចក្នុងសហគមន៍ មានដំណើរការ និង មានការរីកចំរើន
- សមាជិកក្រុមគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពលំបាកពី ១-៣នាក់ បានទទួលការបណ្តុះបណ្តាល ជំនាញកសិកម្មបាន ៣មុខ និង ជំនួញខ្នាតតូច នៅក្នុងសហគមន៍

**សកម្មភាព**

- បណ្តុះបណ្តាលជំនាញកសិកម្មតាមបែបធម្មជាតិដល់គ្រួសារ ដែលស្ថិតនៅស្ថានភាពក្រលំបាកយ៉ាង តិច ១២៨ គ្រួសារក្នុងមួយឆ្នាំ ( ដោយមានការសហការជាមួយមន្ទីរ និងការិយាល័យកសិកម្មខេត្ត និងស្រុក។
- សំរបសំរួលអោយគេមានការជ្រើសរើសកសិកម្មគំរូក្នុងសហគមន៍
- សំរបសំរួល អោយមានដំនើរការសេវាកម្មឥណទានខ្នាតតូចយ៉ាងតិចបំផុត ២ក្រុម ក្នុងសហគមន៍ ( ក្រុមជួយខ្លួនឯង និងសន្សំប្រាក់ និងធនាគារស្រូវ )
- សំរបសំរួលអោយមានសហគមន៍ កសិកម្មក្នុងសហគមន៍ ផលិតផលកសិកម្ម និងផលិតផលសិប្បកម្ម

- សំរបសំរួលអោយមានហាងលក់ទំនិញសហគមន៍ នៅតាមថ្នាក់ខេត្តដើម្បីបង្ហាញ និងដាក់លក់ទំនិញសហគមន៍

❖ **ផ្នែកការរៀបចំសហគមន៍**

- គណៈកម្មការដឹកនាំសហគមន៍ដូចជា គណៈកម្មការអភិវឌ្ឍន៍ភូមិ ជំនួយការអភិវឌ្ឍន៍សហគមន៍ គណៈកម្មការអប់រំសហគមន៍ គណៈកម្មការសុខមាលភាពសង្គម គ្រួសារសហគមន៍ ក្រុមឃ្លាំមើល និងក្លឹបយុវជនសហគមន៍ មានភាពសកម្មលើការងារ ការដឹកនាំ រៀបចំចាត់ចែង និងត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍សហគមន៍ដោយខ្លួនឯងបាន ។
- ឯកសារគោលដៅ ផែនការ របាយការណ៍ និងឧបករណ៍ត្រួតពិនិត្យត្រូវបានបង្កើតឡើងដោយសហគមន៍

**សកម្មភាព**

- សំរបសំរួលសហគមន៍អោយមានការរៀបចំបង្កើតលក្ខណៈវិនិច្ឆ័យ ដើម្បីជ្រើសរើសជំនួយការអភិវឌ្ឍន៍សហគមន៍គណៈកម្មអប់រំសហគមន៍ គណកម្មការសុខមាលភាពសង្គមគ្រួសារសហគមន៍ ក្រុមឃ្លាំមើល និងក្លឹបយុវជនសហគមន៍។
- សំរួលអោយមានការបញ្ចូនការងារយេនឌ័រ ទៅគ្រប់សកម្មភាពអភិវឌ្ឍន៍ សហគមន៍ ជាពិសេសការចូលរួមរបស់ស្ត្រីក្នុងការសំរេចចិត្ត ការដឹកនាំ និងសកម្មភាពផ្សេងៗក្នុងការលើកកំពស់ និងអនុវត្តន៍សិទ្ធិស្ត្រីក្នុងសហគមន៍។
- បណ្តុះបណ្តាលសមត្ថភាពលើភាពជាអ្នកដឹកនាំ និងទស្សនះអភិវឌ្ឍន៍ ដល់គណៈកម្មការដឹកនាំសហគមន៍ទាំងអស់ និងសមាជិកក្រុមប្រឹក្សាឃុំ ។
- សំរបសំរួលថ្នាក់ដឹកនាំសហគមន៍ទាំងអស់ ក្នុងការរៀបចំបង្កើតគោលការណ៍សហគមន៍ និងគោលការណ៍រចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវ
- ផ្តល់ការបង្រៀនបណ្តើរ និងការអនុវត្តន៍បណ្តើរដល់ថ្នាក់ដឹកនាំសហគមន៍ទាំងអស់ ពីការងារតាមតួនាទី ដើម្បីបង្កើតក្រុមសកម្មភាពអភិវឌ្ឍន៍សហគមន៍ ការប្រជុំពិភាក្សា ការចូលរួមធ្វើរបាយការណ៍ ការត្រួតពិនិត្យសកម្មភាពជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ជាពិសេសគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពក្រលំបាកនោះ។
- សំរបសំរួលការកសាង និងជួសជុលគេហដ្ឋានរចនាសម្ព័ន្ធខ្នាតតូចក្នុងសហគមន៍ ដូចជាការជួសជុលស្ពាន និងផ្លូវថ្នល់ក្នុងភូមិ និងសាលប្រជុំ សាលាមតេយ្យ អណ្តូងទឹក ហើយនិងស្រះជាដើម ។ល។
- សំរបសំរួលថ្នាក់ដឹកនាំសហគមន៍ទាំងអស់ អោយបានទៅទស្សនះកិច្ចក្នុងនិងក្រៅខេត្ត ដើម្បីយកមកធ្វើបទពិសោធន៍ថ្មីៗពីកន្លែងដ៏ទៃមកអនុវត្តន៍ក្នុងសហគមន៍របស់ខ្លួនបានប្រសើឡើង។

### ❖ និរន្តរភាពសហគមន៍

- កុមារក្តីសង្ឃឹមមានផែនការធ្វើការជាមួយដៃគូរ ហើយមានរយៈពេល៦ឆ្នាំ ដោយ ២ឆ្នាំ ក្នុងដំណាក់កាលកសាងសមត្ថភាព ២ឆ្នាំទៀត ជំនាក់កាលពង្រឹងសមត្ថភាព និង២ឆ្នាំចុងក្រោយដល់ដំណាក់កាលដកថយ ។
- នៅពេលដែលអង្គការកុមារក្តីសង្ឃឹមដកថយ សហគមន៏មានផែនការច្បាស់លាស់ក្នុងការអនុវត្តន៏កម្មវិធីរបស់ខ្លួន ដោយកម្មវិធីបានសំរបសំរួលអោយគេអនុវត្តន៏សកម្មភាពអភិវឌ្ឍន៏សហគមន៏ដោយខ្លួនឯងតាំងពីឆ្នាំ ទី១ រហូតមក ដូច្នេះអ្នកដឹកនាំសហគមន៏ដោយខ្លួនឯងដូចជា ពង្រីកក្រុមសកម្មភាពក្នុងភូមិ ទំនាក់ទំនងបណ្តាញការងារដើម្បីជួយគាំទ្រសកម្មភាពភូមិ និងប្រមូលធនធានពីក្នុង និងក្រៅសហគមន៏ដឹកនាំការប្រជុំ និង រៀបចំកសាងផ្សេងៗរបស់ភូមិជាដើម ។

### ❖ ការត្រួតពិនិត្យ និងវាយតំលៃ

អង្គការកុមារនៃក្តីសង្ឃឹមបានមានផែនការវាយតំលៃពីខាងក្រៅ ១ឆ្នាំ ម្តងតាមផ្នែក ដូចជា :

- ឆ្នាំ ២០០២ មានការវាយតំលៃផ្នែករៀបចំសហគមន៏
- ឆ្នាំ ២០០៣ មានការវាយតំលៃផ្នែកមុខរបរ និង ប្រាក់ចំណូល
- ឆ្នាំ ២០០៤ មានការវាយតំលៃផ្នែកការអប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ឆ្នាំ ២០០៥ និងមានការវាយតំលៃផ្នែកសិទ្ធិកុមារ និង សុខមាលភាពសង្គម
- ឯប្រពន្ធ័ត្រួតពិនិត្យផ្ទៃក្នុង ក៏យើងមានឧបករណ៏ត្រួតពិនិត្យច្បាស់លាស់តាមផែនការដែរ រាល់ការវាយតំលៃ បានឆ្លុះបញ្ចាំងអោយយើងឃើញនូវចំណុចខ្វះខាតដែលត្រូវកែលំអជាបណ្តើៗ ព្រមទាំងកម្មវិធីនិងបុគ្គលិក

### ❖ កិច្ចសហការ និង បណ្តាញការងារ

#### បណ្តាញការងារនៅថ្នាក់ស្រុក និង ខេត្ត

ដើម្បីអោយកម្មវិធីមានដំណើការបានល្អភាពទំនាក់ទំនងត្រូវបានផ្សព្វផ្សាយភ្ជាប់ជាមួយមន្ទីរ និងស្ថាប័នអង្គការជាតិ និងអន្តជាតិ ដែលជាបណ្តាញការងារដែលពាក់ពន្ធ័ និងបណ្តាញការងារថ្នាក់ស្រុក និងថ្នាក់ខេត្ត ។

#### បណ្តាញការងារថ្នាក់ជាតិ

អង្គការនៃក្តីសង្ឃឹមបានចូលជាសមាជិក បណ្តាញការងារសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហា ដែលកេងប្រវញ្ចផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា

## ការធ្វើការសំរេចចិត្តចំពោះអង្គការដែលបានដាក់ពាក្យសុំចូលជាសមាជិក

លោក ទូន វិចិត្រ បានធ្វើការថ្លែងអំណរគុណដល់ក្រុមបង្ហាញទាំងអស់ ហើយលោកបានប្រគល់តួនាទីនេះទៅលោក សុខ សំអឿន ជាអ្នកផ្តល់ការសំរេចចិត្ត។

នៅពេលនោះលោក សុខ សំអឿន បានមានប្រសាសន៍ថា អង្គការនិមួយៗសុទ្ធតែមានផែនការច្បាស់លាស់ ហើយលោកអនុញ្ញាតអោយចូលជាសមាជិកបាន តែជាសមាជិកគាំទ្រ Associated Member ប៉ុណ្ណោះលុះពេលដែលសមាជិកចាស់ធ្វើការសង្កេតមើលសកម្មភាពនៅពេលខាងមុខឃើញថា សមស្របហើយទើបអនុញ្ញាតអោយចូលជាសមាជិកសកម្មបាន ។

ក្រៅពីនោះលោក សុខ សំអឿន បានជំរាបជូនដំណឹងពីក្រសួងយុត្តិធម៌ ដែលកំពុងតែធ្វើពង្រាងច្បាប់ពីការជួញដូរ ដូចនេះលោកសុំអោយអង្គការទាំងអស់ចូលរួមបញ្ចេញមតិ និងធ្វើការកែប្រែអោយមានលក្ខណៈសុក្រិត្យ ហើយលោកក៏បានប្រាប់ពីការរៀបចំសិក្ខាសាលាមួយនៅពេលខាងមុខស្តីពីការធ្វើពង្រាងច្បាប់ស្តីពីសិទ្ធិកុមារ ។

## ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៤

(សកម្មភាពលំអិតប្រចាំថ្ងៃ សូមមើលឧបសម្ព័ន្ធ A)

នៅព្រឹកថ្ងៃទី ២០ ខែ ធ្នូ ២០០៤ លោក អ៊ុំ រតនាធ្វើការប្រកាសបើកកម្មវិធី និង ធ្វើការសង្ខេបពីអ្វីដែលបាន ធ្វើអស់រយៈពេលពីរថ្ងៃមកហើយដូចជា នៅថ្ងៃទី ១៨ មានការធ្វើការបង្ហាញពីសកម្មភាពរបស់ កូសេកាំ និងមានការពិភាក្សាតាមក្រុមដែលមាន ៤ ក្រុម។ បន្ទាប់មកមានការពិភក្សាពីបញ្ហាសមាជិកភាពអនុគណៈកម្មការ តែមិនបានសំរេចនៅឡើយ។ John បានបង្ហាញពីសញ្ញាណនៃមណ្ឌល ហើយបន្ទាប់មកកញ្ញា សុវណ្ណារីឡើងបង្ហាញពីការធ្វើការស្ទង់មតិផ្នែក Advocacy។ បន្ទាប់មកមានការពិភាក្សាតាមក្រុមអំពី សញ្ញាណនៃមណ្ឌល និងវិធីសាស្ត្រក្នុងការបង្កើតមណ្ឌល និងរកវិធានការណ៍សំរាប់ធ្វើការអនុវត្តអោយបានប្រសើរឡើង។ នៅក្នុងដំណើរការនេះគឺមានលោក ប៉ុល ហំម ជាអ្នកសំរបសំរួល។ នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៤ មានការពិភាក្សាពីសមាជិកភាព និងការបង់វិភាកទានសំរាប់សម្ព័ន្ធ។ និងការបង្ហាញរបស់សមាជិកថ្មីអំពីសកម្មភាព ដែលអង្គការខ្លួនបានធ្វើ។ ក្រៅពីនោះលោក អ៊ុំ រតនា បានធ្វើការណែនាំពីសកម្មភាពដែលត្រូវធ្វើនៅថ្ងៃនេះគឺ ការកំណត់សកម្មភាពសំរាប់ផែនការឆ្នាំ ២០០៥ ទៅមុខទៀតទៅលើចំនុចទាំង ៤ ហើយផ្តោតលើប្រធានបទធំៗ ៣ គឺ តើមានអ្វីដែលត្រូវធ្វើបន្ត ហើយមានអ្វីដែលត្រូវលុបចោល និងមានអ្វីដែលត្រូវបន្ថែមសំរាប់ផែនការសកម្មភាពទៅមុខក្នុងឆ្នាំ ២០០៥ ដើម្បីអោយដឹងថាអ្វីត្រូវបន្ថែម ឬលុបចោលដោយអោយមើលឯកសារ ដែលអង្គការបានចែកអោយ និងឯកសារដែលបុគ្គលិក COSECAM បានបង្ហាញ ដើម្បីលើកយកចំនុចទាំងនោះមកធ្វើការពិភាក្សា

និងរកចំណុចបន្ថែមទៀត។ ចុងក្រោយ លោក រតនា បានអញ្ជើញលោក ទូន វិចិត្រ ធ្វើការណែនាំពន្យល់បន្ថែមទៀត។

លោក វិចិត្រ បានធ្វើការគោរព និងបញ្ជាក់ពីវត្តមានអ្នកចូលរួម និងបញ្ជាក់ពីអ្វីដែលត្រូវធ្វើនៅថ្ងៃនេះគឺការពិភាក្សារកដំណោះស្រាយសំរាប់ផែនការឆ្នាំ ២០០៥ ដោយផ្អែកទៅលើសកម្មភាពឆ្នាំ ២០០៤។ តើសកម្មភាពកន្លងមកសមស្របសំរាប់ឆ្នាំ ២០០៥ ដែរឺទេ? តើមានអ្វីត្រូវបន្ថែមទៀត? ក្រៅពីនេះលោកបានលើកឡើងពីទស្សនៈរបស់លោក យី សុខសាន្ត ថា កូសេកាំគួរតែធ្វើជាអ្នកសំរបសំរួលលើការធ្វើពង្រាងច្បាប់ការពារអនិតិជន ហើយធ្វើសិក្ខាសាលាមួយដើម្បីពិភាក្សាអោយបានល្អិតល្អន់។ តាមពិតយើងនៅមានសិក្ខាសាលាមួយទៀតដែលត្រូវធ្វើឡើងនៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៤នេះ។ បន្ទាប់មក លោក John បានឡើងធ្វើការបង្ហាញពីវិធីសាស្រ្ត និងបទពិសោធន៍ដែលទទួលបានពីប្រទេសថៃក្នុងពេលទស្សនកិច្ច ហើយលោកទទួលស្គាល់ថា ពួកគេមានវិធីសាស្រ្តល្អៗសំរាប់យកមកធ្វើជាគំរូ និងដែលអាចមានប្រសិទ្ធិភាព។ បន្ទាប់មកលោក រតនា សូមអញ្ជើញលោក John អោយឡើងធ្វើការពន្យល់ពីដំនើរការដែលទទួលបាននោះ ហើយមានខ្លឹមសារដូចតទៅៈ

ខ្ញុំមិននិយាយច្រើនទេ ដោយសារយើងបានដឹងហើយតាមរយៈឯកសារដែលបានចែកជូនពីលទ្ធផលគឺ ទី ១ យើងអាចធ្វើការទាមទាអោយមានការផ្លាស់ប្តូរខ្លះៗ តែមិនអាចធ្វើអោយមានការផ្លាស់ប្តូរទាំងស្រុងបានទេហើយ អ្វីដែលយើងត្រូវនិយាយនៅថ្ងៃនេះគឺ គំរោងថ្មីរបស់យើង និងការធ្វើយ៉ាងណាអោយមានប្រសិទ្ធិភាព។ អ្នកទាំងអស់គ្នាអាចនៅចាំបានពីសកម្មភាពនៃការធ្វើទស្សនកិច្ច TOUR ពីយុទ្ធនាការប្រឆាំង និងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ហើយអ្នកដែលមិនបានចូលរួមអាចមើលឯកសារដែលបានចែកជូន បន្ទាប់មកយើងមានសិក្ខាសាលានៅតាមខេត្ត និងបន្ទាប់មកមានសន្និសីទជាតិមួយទៀត។ ក្នុងពេលនោះ យើងបានធ្វើច្រើនហើយនេះជាយុទ្ធសាស្រ្តរបស់យើង និងមានគោលបំណងសំរាប់រកដំណោះស្រាយដ៏សមស្រប និងមានប្រសិទ្ធិភាពសំរាប់ធ្វើសកម្មភាព និងសំរាប់ដាក់បញ្ចូលទៅក្នុងផែនការជាតិ ៥ឆ្នាំ ទៅមុខទៀត។ នៅខែមិថុនាមានការរៀបចំអោយមានការប្រជុំមួយជាមួយ Unicef, IOM, និង ILO ។ នៅពេលនោះ ពួកគេទាំងអស់គ្នាបានជួយរកវិធីសាស្រ្តល្អៗ ដើម្បីអភិវឌ្ឍន៍ផែនការជាតិដែល CNCC កំពុងតែធ្វើ។ នៅពេលនោះមានការចូលរួមពីសំណាក់អង្គការជាច្រើនទាំងអង្គការក្នុងស្រុក និងអង្គការអន្តរជាតិ ហើយអង្គការទាំងអស់បានយល់ស្របថា Unicef ត្រូវតែជ្រើសរើសអ្នកជំនាញការបរទេស (Expert) មួយសំរាប់ធ្វើផែនការជាតិអោយបានប្រសើរឡើង។ តែជាការពិត Unicef មិនបានអោយយើងចូលរួមនោះទេ។ លោកអ្នកទាំងអស់គ្នាបានដឹងហើយថា ផែនការជាតិនេះនឹងផុតកំនត់នៅថ្ងៃ៣១ ខែធ្នូ ២០០៤ ហើយផែន ការជាតិថ្មីនិងចាប់ផ្តើមនៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៥ ហើយ CNCC មិនទាន់បានរៀបចំផែនការជាតិនៅឡើយ។ នៅក្នុងសប្តាហ៍កន្លងទៅថ្មីៗនេះ យើងបានទទួលទស្សនកិច្ចដែលជាទីប្រឹក្សារបស់ Unicef ជួលមកដើម្បីរៀបចំកម្មវិធី ដែលនឹងចាប់ផ្តើមនៅ ខែមិថុនា ឆ្នាំ ២០០៥។ បើតាម

ទីប្រឹក្សានោះ ក្នុងចន្លោះពេលនេះយើងមិនទាន់មានផែនការថ្មីសំរាប់អនុវត្តនៅឡើយទេ តែនេះវាមិនជាបញ្ហាទេ សំរាប់កូសេកាំ ដោយសារយើងមានការងាររបស់យើងសំរាប់ធ្វើហើយ ដូចនេះហើយអ្វីដែលកូសេកាំយើងបាន ស្នើរទៅអ្នកទាំងអស់គ្នានោះ គឺយើងត្រូវធ្វើកិច្ចការមួយតែមិនដូចមុននោះទេ។

យើងដឹងហើយថា អ្វីដែលយើងចង់បាននោះគឺគំនិតរបស់យើងត្រូវបានគេដាក់ក្នុងផែនការជាតិ។ សំនើរ ទាំងអស់មានពីរ ទី ១ គឺយើងរកទីប្រឹក្សាខ្មែរអោយទៅធ្វើការជាមួយទីប្រឹក្សាដែល Unicef ជួលមក ដើម្បីឱ្យ គំនិតដែលយើងខិតខំរកបាននេះ ត្រូវបានគេដាក់ទៅក្នុងផែនការថ្មី។ ទី ២ គឺ យើងត្រូវអញ្ជើញអ្នកដឹកនាំអង្គការ ធំៗ ដើម្បីផ្តល់គំនិតជាមួយទីប្រឹក្សាដែលជាខ្មែរ ដូចនេះអ្វីដែលយើងត្រូវធ្វើគឺការចាប់ផ្តើមពីអ្វីដែលមិនទាន់មាន សោះតាមរយៈឯកសារ ហើយបង្កើតផែនការដែលអាចអោយគំនិតរបស់យើងចូលទៅក្នុងផែនការជាតិថ្មី។ នេះជា សំនើរដែលកូសេកាំ លើកឡើងដើម្បីសុំយោបល់ពីអស់លោកទាំងអស់គ្នា។ ឥឡូវនេះអង្គការអន្តរជាតិជាអ្នក កំនត់នូវអ្វីដែលរដ្ឋាភិបាលត្រូវធ្វើ តែ CNCC ជាផ្នែកមួយរបស់រដ្ឋាភិបាល ហើយតាមការពិតការងារនេះគឺ អង្គការនានាជាអ្នកចូលរួមធ្វើមិនមែន CNCC ជាអ្នកធ្វើដោយផ្ទាល់ទាំងស្រុងនោះទេ។ ចំណែកសកម្មភាពរបស់ កូសេកាំ គឺជួយអង្គការផ្សេងៗអោយចេះធ្វើផែនការ ហើយឥឡូវនេះយើងដើរបានពាក់កណ្តាលផ្លូវហើយ ដូចនេះ យើងត្រូវកសាងសមត្ថភាពថែមទៀត ហើយចំណែកឯការធ្វើទំនាក់ទំនងជាមួយរដ្ឋាភិបាលក៏បានពាក់កណ្តាលផ្លូវ ហើយដែរ ។

លើសពីនេះទៅទៀត អ្វីដែលគួរអោយចាប់អារម្មណ៍ខ្លាំងនោះ គឺនៅពេលដែល CNCC គាត់ទៅប្រជុំ នៅទីក្រុងបាងកក គាត់បានលើកឡើងពីគំនិតទាំងអស់ដែលកូសេកាំប្រមូលបាន ហើយហេតុអ្វីបានជា CNCC តែងតែយកអ្វីដែលកូសេកាំធ្វើទៅលើកឡើងនោះគឺ យើងជាអ្នកធ្វើ។ ចំពោះការធ្វើសកម្មភាពថា ហេតុអ្វីបានជា កូសេកាំ ធ្វើទៅលើអ្នកដែលរងគ្រោះដោយសារការជួញដូរផ្លូវភេទនោះគឺ នៅក្នុងពាក្យថា CO<u>SE</u>CAM នេះ យើងមានពាក្យថា Sex Exploitation រួចហើយ ដូចនេះសកម្មភាពដំបូងរបស់យើង គឺផ្តោតទៅលើអ្នកដែល រងគ្រោះផ្លូវភេទ។ សំរាប់សមាជិកវិញ យើងមានក្រុមគោលដៅផ្សេងៗគ្នា ហើយនិងមានការអនុវត្តសកម្មភាព ទៅលើកុមារផងដែរ ហើយអ្នកណាគឺ ជាក្រុមគោលដៅដែលយើងធ្វើ? គឺកុមាររងគ្រោះ និងកុមារដែលងាយ រងគ្រោះ, កុមារអនាថាតាមចិញ្ចើមថ្នល់, កុមារកំព្រា និងកុមារគ្មានទីជំរក។

**ចំណាប់អារម្មណ៍របស់ លោក វាសនា:** សូមអោយអង្គការទាំងអស់ធ្វើការសង្កេតមើលពីការបំរើ និងការបែង ចែកកំរៃនៅក្នុងផ្ទះបនផង។ ( សេចក្តីលំអិត សូមមើលឧបសម្ព័ន្ធ B )

## ការបញ្ជាក់របស់លោក John ពីសកម្មភាពរបស់សម្ព័ន្ធកូសេកាំ

កូសេកាំ COSECAM : Sex Exploitation : $ ( Sex and Child Labor ) គឺជាក្រុមគោលដៅទី ១ របស់កូសេកាំ ហើយនៅក្នុងការអនុវត្តកន្លងមកយើងបានជួបក្រុមទី ២ គឺ Child Abuses ដូចជាការរំលោភសេពសន្ថវៈទៅលើក្មេង និងការរំលោភការងារដ៏ធ្ងន់ធ្ងរ (hazardous) និងក្មេងដែលដើរសុំទាន។ ចំពោះស្រីបំរើស្រាបៀវិញ ក៏យើងបានចាត់ចូលទៅក្នុងប្រភេទ Sex Exploitation ផងដែរ ព្រោះវាជាប់ពាក់ព័ន្ធជាមួយលុយកាក់។ តាមការកំនត់ពី Child victims ថាតើយើងគួរគិតពីក្មេងដែល គេយកទៅលក់នៅក្រៅប្រទេសដែរឺទេ? បាទ ក្រុមគោលដៅរបស់យើងគឺ កំនត់យកក្មេងដែលជាជនជាតិកម្ពុជាទាំងអស់ ទោះជាក្មេងនោះត្រូវបានគេយកទៅលក់នៅប្រទេសណាក៏ដោយ ហើយនិងក្មេងដែលជា ជនជាតិបទេសហើយត្រូវបានគេយកមកលក់នៅក្នុងប្រទេសកម្ពុជាយើង ហើយផ្តោតសំខានទៅលើតែការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទ។ ឧទាហរណ៏ អង្គការ CCHDO បានទៅធ្វើការជួយសង្គ្រោះកុមារនៅប្រទេសថៃ និង PJJ បានទៅរំដោះក្មេងនៅប្រទេសម៉ាឡេស៊ីជាដើម។

ចំពោះសកម្មភាពថ្មីដែលយើងទាំងអស់គ្នាត្រូវធ្វើនោះគឺ ការបង្កើតច្បាប់ការពារកុមារ (Child Protective Regulations)។ ដោយសារប្រទេសកម្ពុជាយើងមិនទាន់មានច្បាប់ការពារកុមារដែលគ្មានឪពុកម្តាយ និងកុមារដែលងាយរងគ្រោះ ដូចនេះ មជ្ឈមណ្ឌលដូចជា CCPCR, AFFASIP ជាដើមអាចមានបញ្ហា ព្រោះក្មេងនោះអាចត្រូវឪពុកម្តាយគេជំទាស់ក្នុងការយកកូនគេមកដាក់មណ្ឌលដើម្បីធ្វើការសង្គ្រោះ ហើយសំរាប់បញ្ហានេះកូសេកាំនិងធ្វើការពិភាក្សាជាមួយអង្គការផ្សេងៗទៀត ។ ឧទាហរណ៏ នៅក្នុងមណ្ឌលមួយ បើក្មេងអាយុក្រោម ១៨ឆ្នាំ ហើយឪពុកម្តាយក្មេងនោះជំទាស់ យើងត្រូវតែអោយក្មេងនោះទៅវិញ ទោះជាយើងដឹងថា ក្មេងនោះទទួលរងការធ្វើបាប ឬរំលោភក៏ដោយ។ ដូចនេះ យើងគួរតែមានច្បាប់ក្រមសីលធម៌មួយ (Moral Rights/duty to protect exploit / abused child)។ តែបញ្ហានោះនៅមានទៀត ថាតើយើងធ្វើការការពារដូចម្តេច បើយើងមានសិលធម៌ ហើយតែយើងគ្មានច្បាប់នោះ ដូចនេះយើងត្រូវតែខិតខំអោយមានច្បាប់សំរាប់ការពារអនីតិជន។ ចំពោះរឿងទី ២ គឺ យើងសូមអោយសមាជិកណាមួយរបស់កូសេកាំ ចូលរួមជាមួយក្រុមការងារ Working Group on Parental Power ហើយត្រូវបង្កើតក្រុមមួយដែលមានអ្នកច្បាប់ចូលរួមដើម្បីកំនត់អំណាចឪពុកម្តាយ ដែល CDP នឹងធ្វើជាអ្នកដឹកនាំ ហេតុនេះបើអស់លោក-លោកស្រីណាមានការចាប់អារម្មណ៏ សូមប្រាប់ទៅលេខារបស់កូសេកាំ។ ដូចអ្នកទាំងអស់គ្នាបានដឹងហើយថា អង្គការជាច្រើនបានធ្វើការងារផ្សេងៗពីគ្នា ក្នុងការដោះស្រាយបញ្ហាកុមារ ហើយអ្វីដែលខ្ញុំមានការខកចិត្តនោះគឺ យើងមិនបានលឺពីរបាយការណ៏ ស្តីពីការជួញដូរនៅក្នុងប្រទេសកម្ពុជា។ ដូចនេះអ្វីដែលយើងត្រូវធ្វើនោះគឺ ផែនការ ៥ឆ្នាំ ទៅមុខ ហើយយើងបានកំនត់យកពាក្យមួយសំរាប់មកដាក់គឺ *ATACC* គឺជាពាក្យមួយមកពី Assistance To Trafficking and Abused Children Coordination

ហើយនេះគ្រាន់តែជាឈ្មោះហើយ យើងទាំងអស់គ្នាអាចកែបាននៅពេលក្រោយ តែអ្វីដែលសំខាន់នោះគឺ គំនិត។ ដូចជានៅប្រទេសថៃ គេមានកម្មវិធីមួយឈ្មោះថា TRAFF CORD នៅតាមព្រំដែនភូមា ហើយក្រុមនោះជាអ្នកធ្វើការដែលពាក់ព័ន្ធជាមួយស្ថាប័នផ្សេងទៀតដូចជា ប៉ូលីស អង្គការនានា រដ្ឋាភិបាល តាមរយៈជំនួយពីអង្គការសហប្រជាជាតិ។ នៅកម្ពុជាយើង មានអង្គការដែលថែរក្សាក្មេងដោយឡែកពីគ្នាធ្វើការដោយមិនមានកិច្ចសហការណ៍គ្នានោះឡើយ។ ដូចនេះការធ្វើសកម្មភាពជួនកាលធ្វើជាន់គ្នា ហើយជួនកាលមានចំនុចមួយចំនួនដែលមិនបានធ្វើដូចគ្នា ហេតុនេះការជួយកុមាររងគ្រោះមិនបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ការធ្វើបែបនេះ យើងអាចផ្តល់សេវាដល់កុមារមួយចំនួន តែអ្នកខ្លះអង្គការមិនបានរកឃើញនោះឡើយ ដូចនេះយើងត្រូវសហការណ៍គ្នាក្នុងការអនុវត្តការងារ និងការផ្តល់ពតិមានអោយគ្នាទៅវិញទៅមក។ ម្យ៉ាងទៀតកុមារមួយចំនួនមានមណ្ឌលសំរាប់ថែរក្សាហើយ តែមណ្ឌលនោះវាមិនមានលក្ខណៈសមស្របទៅនឹងអ្វីដែលក្មេងចង់បាន ហេតុនេះយើងត្រូវបញ្ជូនក្មេងនេះទៅទីណា ដែលមានលក្ខណៈសមស្របតាមបំណងរបស់ពួកគេ។ ជាចុងក្រោយនោះគឺ យើងត្រូវធ្វើជាមួយកុមារមួយក្រុមទៀត ដែលមិនចង់ស្នាក់នៅក្នុងមណ្ឌលទេ តែគេត្រូវការអោយយើងជួយ។ សំរាប់គំរោងនេះយើងនឹងមានបុគ្គលិក TRAFF CORD គេនិងមកយកជួយចែករំលែកបទពិសោធន៏ និងផ្តល់នូវវិធីសាស្រ្តល្អៗសំរាប់រៀបចំគំរោង និងផែនការសកម្មភាព។ ក្រៅពីនេះយើងអាចធ្វើទស្សនកិច្ចទៅប្រទេសផ្សេងៗទៀត។ នៅក្នុងឆ្នាំទី ១ នេះ យើងនឹងពិនិត្យមើលការសហការរវាងអង្គការផ្សេងៗឆ្នាំទី ២ គឺ យើងធ្វើ Pilot និងឆ្នាំទី ៣ គឺជាតំណាក់កាលអនុវត្ត (Implementation) ។ ហើយនិងមាន ២ចំនុចទៀតគឺ ការផ្តល់ការហ្វឹកហ្វឺនដល់បុគ្គលិកអង្គការនានា ហើយមានម្ចាស់ជំនួយមួយគេបានយល់ព្រមពីការផ្តល់ Fund តែយើងត្រូវពិភាក្សាជាមួយសមាជិកសិនថា ត្រូវធ្វើអ្វី ហើយអ្វីដែលសមាជិកទាំងអស់ចង់បាន រួចហើយទើបយើងបង្កើតផែនការមួយសំរាប់ធ្វើសកម្មភាពផ្តល់ការកសាងសមត្ថភាពរបស់បុគ្គលិក ហើយគំរោងនេះយើងនឹងធ្វើចំពោះបុគ្គលិកជាទូទៅ មិនមែនធ្វើចំពោះតែថ្នាក់ដឹកនាំ ឬថ្នាក់លេខាធិកាដ្ឋាននោះទេ។ រួចហើយយើងធ្វើគំរោងផ្ញើរទៅអោយម្ចាស់ជំនួយ។

***សំរាប់ផែនការសកម្មភាពបន្តក្នុងឆ្នាំ ២០០៥ នោះគឺ យើងមានលុយ ៦០០ ០០០ដុល្លា។ តើយើងត្រូវធ្វើអ្វី?***

ជារៀងរាល់ឆ្នាំថវិការរបស់យើងតែងតែមានការកើនឡើង តែយើងត្រូវតែទទួលខុសត្រូវនៅក្នុងការចាយវាយ ដូចនេះត្រូវមានការប្តេជ្ញាចិត្តសំរាប់អ្នកដែលធ្វើការសំរេចចិត្ត និងអ្នកគ្រប់គ្រង។ ហេតុដូចនេះយើងត្រូវធ្វើការប្រជុំរវាងគណៈកម្មការនាយកដើម្បីរៀបចំ Basket Fund នេះ ហើយចំពោះអង្គការធំៗ គេតែងតែចាប់អារម្មណ៏លើលុយណាដែលមានចំនួនច្រើន តែមានលក្ខ័ណ្ឌមួយហើយដើម្បីបានការងារនេះ យើងត្រូវធ្វើការងាររួមគ្នាហើយយើងមិនទាន់បានលុយទេព្រឹកនេះ។ ម្ចាស់ជំនួយមានការចាប់អារម្មណ៏ ហើយមានតែអង្គការមួយចំនួនតូចទេដែលបានដឹងរឿងនេះ។ ឧទាហរណ៏ PJJ បានជំនួយពី LSCW ពីការដាក់ពាក្យសុំមូលនិធិ បើថ្ងៃ

ក្រោយ PJJ មានបញ្ហា LSCW អាចជួយ PJJ វិញ ដូចនេះទៅអនាគត PJJ អាចដាក់ពាក្យទៅ LSCW ការធ្វើបែបនេះវានឹងអាចបានផលប្រសើរ។ ដូចនេះនៅក្នុងពិភពពានិជ្ជកម្មនេះ គេហៅថា Join Venture។ ដូចនេះ យើងសូមជូនដំណឹងអោយសមាជិកទាំងអស់ពីការធ្វើការរួមគ្នា។ ដូចនេះនៅក្នុងថវិកាដែលយើងមាន ៦០០ ០០០ដុល្លា យើងបានរក្សាទុក ២៣០,០០០ ដុល្លាសំរាប់សកម្មភាពលើកុមារ (ថវិកា ១០០,០០០ សំរាប់ VTF និង ១៣០,០០០ ដូល្លា សំរាប់សកម្មភាពផ្សេងៗ)។ ដូចនេះ គំនិតនេះកូសេកាំមិនអាចធ្វើតែម្នាក់ឯងបានទេ តំរូវអោយមានការសហការរួមគ្នា និងការទទួលខុសត្រូវរួមគ្នាផងដែរ។ ហេតុនេះសូមធ្វើការពិចារណាអោយបានល្អិតល្អន់ ពីសកម្មភាពដែលត្រូវធ្វើ ហើយជាចុងក្រោយ សូមជូនពរអោយអ្នកទាំងអស់គ្នាជួបតែសេចក្តីរីករាយសំរាប់បុណ្យចូលឆ្នាំសកលយើងនេះ។ (សកម្មភាពលំអិតប្រចាំថ្ងៃ សូមមើលឧបសម្ព័ន្ធ C)

## ការសំរបសំរួលពិភាក្សាលើផែនការកម្មវិធីសំរាប់ឆ្នាំ ២០០៥ ដោយ លោក អ៊ុំ រតនា

- មានការសុំអោយចូលរួមសកម្មភាពនៃការធ្វើពង្រាងច្បាប់ការពារអនីតិជន ហើយសំអោយអង្គការទាំងអស់ជួយធ្វើការផ្តល់យោបល់និងកែសំរួលដល់ខ្លឹមសារនិងអត្ថន័យ។
- ការត្រួតពិនិត្យពីសកម្មភាពចាស់ដែលអង្គការនានាបានធ្វើ ហើយនិងអាចធ្វើការផ្លាស់ប្តូរលើចំនុចណាមួយបាន តែយើងមិនអាចធ្វើការផ្លាស់ប្តូរទាំងស្រុងនោះទេ។
- ការគ្រប់គ្រងកុមារនិងជនរងគ្រោះ និងរាល់គ្រប់ករណីទាំងអស់ដែលទាក់ទងទៅនិងការជួញដូរ។
- ត្រូវរកយុទ្ធសាស្ត្រសំរាប់អនុវត្តអោយមានប្រសិទ្ធិភាព និងអោយបានតាមតំរូវការរបស់អតិថិជន។
- ការកសាងសមត្ថភាព ដោយម្ចាស់ជំនួយបានយល់ព្រមផ្តល់មូលនិធិ សំរាប់ធ្វើការកសាងសមត្ថភាពបុគ្គលិក ទាំងបុគ្គលិកថ្នាក់ដឹកនាំ ទាំងបុគ្គលិកថ្នាក់ក្រោម។
- មានការប្រកាសប្រាប់ពីថវិកា ៦០០ ០០០ ដុល្លា និងសកម្មភាពដែលត្រូវធ្វើសំរាប់ឆ្នាំខាងមុខ។

### សំនួរនិងចំលើយ

Q. **តើពាក្យ** ATACC **ជាឈ្មោះថ្មីរបស់កូសេកាំ ឬក៏ជាផ្នែកមួយរបស់កូសេកាំ?**

នេះគ្រាន់តែជាកម្មវិធីមួយរបស់កូសេកាំតែប៉ុណ្ណោះ ចំពោះឈ្មោះយើងឥតមានការដោះដូរទេ។

## ការបង្ហាញរបស់ក្រុមពិភាក្សាលើកម្មវិធីសំរាប់ឆ្នាំ ២០០៥

### ១- ក្រុមអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (IHRD)

**មានការព្រមព្រៀងតាមសំនើរកម្មវិធី ២០០៥ របស់ COSECAM**

- o យើងត្រូវមានការប្រមូលពត៌មានដូចជា ( កម្មវិធីទាក់ទង និង កុមារ)
- o ការចូលរួមរបស់កុមារក្នុងការធ្វើផែនការតាមរយៈសិក្ខាសាលាហើយនិងការប្រជុំ
- o អង្គការមានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិក (បុគ្គលិកសម្ព័ន្ធធម្មតាថ្នាក់ដឹកនាំ និងបុគ្គលិកលេខាធិការរបស់ COSECAM)

**HRD ទទួលយកគំនិតបន្ថែម:**

- o បញ្ជូនបុគ្គលិកទៅរៀននៅក្រៅប្រទេស
- o ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករបស់មជ្ឈមណ្ឌលឬជំរក ( អ្នកគ្រប់គ្រងមណ្ឌលហើយ និងអ្នកពិគ្រោះយោបល់ និងអ្នកថែទាំសុខភាពរបស់ក្មេង) ។

**សំណូមពរ:**

សូមអោយមានការបណ្តុះបណ្តាលនៅនឹងកន្លែងឬតាមតំបន់

សូមអោយមានការបង្រៀនផ្ទាល់នៅក្នុងមជ្ឈមណ្ឌល ( ជំនាញ)

សូមអោយមានការពិគ្រោះយោបល់ ការថែទាំសុខភាពជាបឋមហើយនិងរបៀបគ្រប់គ្រងមណ្ឌល

ត្រូវតែមានផ្នែករដ្ឋបាល និងចំណាយចំណូលព្រមទាំងរបៀប អ្នកចេះសំរបសំរួលបញ្ហាផងដែរ

សុំអោយមានវគ្គបណ្តុះបណ្តាលបុគ្គលិក និងប្រធាន

សុំអោយមានវគ្គនៃការចាត់ចែងខួបគំរោង និងការគ្រប់គ្រងមជ្ឈមណ្ឌល (ស្រាវជ្រាវ, ធ្វើផែនការ, ការអនុវត្តន៍ ត្រួតពិនិត្យហើយនិងវាយតំលៃ)

សូមអោយមានរបៀបសរសេរសំណើរ និង ការស្វែងរកថវិការផងដែរ

យើងចេះរបៀបសរសេររបាយការណ៍

សូមអោយមានបង្រៀនផ្នែកច្បាប់ដែលទាក់ទងនឹងកុមារ ( ការចិញ្ចឹមរបស់មាតាបិតា)

សុំអោយមានការបង្រៀនទាក់ទងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

**សំនួរ និងចំលើយ សំរាប់ការបង្ហាញតាមក្រុម:**

Q. ***តើការធ្វើទស្សនកិច្ចទៅក្រៅប្រទេសនោះមានគោលដៅយ៉ាងណា?***

- គឺយើងចង់ទៅមើលកម្មវិធីរបស់គេ និងការរៀបចំសកម្មភាពនៅខាងក្រៅ និងដើម្បីដកស្រង់យកជាបទពិសោធន៍ ព្រោះប្រទេសផ្សេងៗក៏មានការជួញដូរដែរ ដូចនេះយើងអាចធ្វើការសិក្សារៀនសូត្រ និងដកស្រង់យកបទពិសោធន៍ល្អៗពីពួកគេ។

Q. ***នៅពេលដែលកូសេកាំផ្តល់អាហារូបករណ៍សំរាប់ជនរងគ្រោះ តើកូសេកាំអាចផ្តល់ដល់សមាជិកដែរឬទេ?***

- យើងអាចផ្តល់ការសិក្សាទៅលើផ្នែកណាដែលយើងត្រូវការ ហើយយើងត្រូវពិនិត្យមើលធនធានថា តើវាមាននៅក្នុងស្រុកខ្មែរ រឺនៅបរទេស។ ជាក់ស្តែង SKN មានគំរោងមួយផ្តល់ការសិក្សាពីជំនាញដែលមានទាំងលក្ខណៈរយៈពេលយូរ និងមានរយៈពេលខ្លី។
- កន្លងមក កូសេកាំ ផ្តល់ការសិក្សាទាំងអស់នៅឆ្នាំ ២០០៤ នោះ មិនមែនកូសេកាំជាអ្នកកំនត់នោះទេ តែជាតំរូវការរបស់សមាជិក។ ចំពោះការសិក្សាថាតើយើងត្រូវទៅធ្វើនៅក្រៅប្រទេស រឺក្នុងប្រទេសនោះ តំណាក់កាលនេះ យើងមិនទាន់អាចនិយាយពីទីកន្លែងដែលត្រូវទៅសិក្សាគឺ ត្រូវកំនត់ពីតំរូវការអោយច្បាស់ កំនត់បញ្ហាដែលជាអាទិភាព ហើយទើបយើងធ្វើការពិនិត្យមើលលើធនធាន និងរកយុទ្ធសាស្ត្រនៅពេលក្រោយ។

**សំណូមពរ:**

សូមឱ្យមានទស្សនៈកិច្ចដកស្រង់បទពិសោធន៏ក្រៅប្រទេសអោយបានច្រើន ឬក៏ទទួលបានវគ្គបណ្តុះបណ្តាលរយៈពេលខ្លីក្រៅប្រទេសអោយបានច្រើនដើម្បីដកយកបទពិសោធន៏មកអនុវត្តជាក់ស្តែង។

## ២. ក្រុមការងារតស៊ូមតិ

សកម្មភាពសំរាប់ផែនការជាតិ ២០០៥-២០០៩ មានដូចតទៅ:

ត្រួតពិនិត្យសកម្មភាព ៥ ឆ្នាំប្រឆាំងនឹងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនិងស្ត្រី

ត្រូវមានការឯកភាពគ្នាលើយុទ្ធសាស្ត្រដែលជាអាទិភាព

ធ្វើការតស៊ូមតិលើ ៤ចំនុចសំខាន់ៗពីបញ្ហាកុមារ:

ការរំលោភផ្លូវភេទលើកុមារ

បញ្ចុះបញ្ចូលដើម្បីអោយមានការការពារសិទ្ធកុមារ

ច្បាប់គ្រប់គ្រងស្ត្រីរកស៊ីផ្លូវភេទ

ច្បាប់ការពារអនីតិជន

**សំណូមពរ:**

- សូមអោយកូសេកាំ បើកវគ្គសិក្សាពីជំនាញការតស៊ូមតិ ព្រោះសូម្បីតែសមាជិករបស់បណ្តាញក៏នៅមិនទាន់យល់ពីការតស៊ូមតិនេះច្បាស់លាស់ដែរ។
- ច្បាប់យើងមានហើយ តែយកមកពីប្រទេសក្រៅដូចនេះ យើងត្រូវត្រួតពិនិត្យ និងធ្វើការកែលំអរព្រោះ CRC គេធ្វើហើយ តែបើយើងធ្វើដែរនោះវាអាចចេញជាលទ្ធផលមួយផ្សេង ហើយយើងអាចយកមក

ធ្វើការប្រៀបធៀបគ្នា។ ចំពោះបញ្ហានេះថា ធ្វើរឺមិនធ្វើនោះគឺជាការសំរេចចិត្តរបស់គណៈកម្មការនាយក ហើយ អ្វីដែលយើងចង់ធ្វើនោះគឺ ច្បាប់អំណាចមេបា។

Q. **តើយើងត្រូវធ្វើដូចម្តេចដើម្បីត្រួតពិនិត្យលើផែនការជាតិ ៥ឆ្នាំ ដែលបានអនុវត្តកន្លងមក?**

- យើងបានធ្វើតាមរយៈការធ្វើទស្សនៈកិច្ច តែបញ្ហាផ្សេងទៀត យើងត្រូវមើលទៅលើរដ្ឋាភិបាលផងដែរ ហើយកូសេកាំមិនត្រូវតែធ្វើតែការត្រួតពិនិត្យនោះទេ ត្រូវធ្វើផែនការសកម្មភាពជាក់ស្តែងផងដែរ។

## ៣. ក្រុមស្រាវជ្រាវ Research

## គោលបំណង

ប្រមូលពតិមានស្តីពីការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី ហើយនិងកុមារនៅក្នុងប្រទេសកម្ពុជាដើម្បីធ្វើអន្តរាគមន៍ទៅស្ថាប័នដែលពាក់ពន្ធ័ ដើម្បីរកដំណោះស្រាយដែលសមស្រប ។

## សកម្មភាពដែលត្រូវធ្វើ

- សិក្សាពីឥទ្ធិពល នៃការបិទតំបន់ស្វាយប៉ាក
- សិក្សាអំពីកម្មវិធី LOBBY
- ត្រូវតែត្រួតពិនិត្យលើពីបទអន្តរាគមន៍ ដែលប្រឆាំងនិងការជួញដូរ ហើយនិងការកេងប្រវ័ញ្ច
- លើកុមារ និងស្ត្រីវ័យក្មេង
- ការសិក្សាស្រាវជ្រាវពីការកេងប្រវ័ញ្ចពលកម្មលើស្ត្រីភេទ
- ការប៉ាន់ប្រមាណពីសមត្ថភាពរបស់អង្គការក្នុងស្រុក
- វាយតំលៃពីស្ថានភាពការជួញដូរផ្លូវភេទស្ត្រី ហើយនិងកុមារ

## សំនួរ និងចំលើយ

Q. **ហេតុអ្វីបានជាត្រូវលុបសកម្មភាពការប្រមូលពត៌មានចេញពីគំរោងរបស់កូសេកាំ បើអង្គការមួយចំនួនមិនទាន់ទាំងបានដឹងពត៌មានច្បាស់លាស់នៅឡើយ?**

- ដោយសារអង្គការទាំងអស់សុទ្ធតែបានធ្វើរបាយការណ៍ និងការវាយតំលៃអោយម្ចាស់ជំនួយរៀង១ខ្លួនហើយ។
- (លោក វិចិត្រ) អ្វីដែលយើងបានដាក់នេះ គឺដោយសារអង្គការទាំងនោះធ្វើការវាយតំលៃទៅលើ តែសកម្មភាពក្នុងតំបន់គោលដៅរបស់ខ្លួនតែប៉ុណ្ណោះមិនបានធ្វើជាទូទៅទូទាំងប្រទេសនោះទេ។ ម្យ៉ាងទៀតយើងធ្វើដើម្បីធ្វើការប្រៀបធៀបសំរាប់ឆ្នាំនិមួយ១ថា តើវាកើនឡើងរឺថយចុះ។

## ៤. ក្រុមការស្ដារនីតិសម្បទា និងសមាហរណកម្មទៅក្នុងសហគមន៍

### សកម្មភាពបន្ត

១. បណ្ដុះបណ្ដាលបុគ្គលិក ផ្នែកប្រឹក្សាពិគ្រោះយោបល់ និង ចិត្តសាស្ត្រសង្គម

២. ត្រូវមានក្រុមប្រឹក្សាយោបល់ និង គ្រូបង្រៀនចល័ត ( បំណិនជីវិតនិងអក្ខរកម្ម)

៣. VTF: កែសំរួលល័ក្ខខ័ណ្ឌក្នុងការផ្ដល់អាហាររូបករណ៏ និងបង្កើតអោយមានខ្នង់ថវិកាសំរាប់ (follow up) តាមដាន

### សកម្មភាពបន្ថែតថ្មី

១. សំរបសំរួល ការគាំទ្រហើយនិងការធ្វើសមាហរណកម្ម

២. សំរបសំរួល និង ការគាំទ្រសហគ្រាស ធុនតូច និង ធុនមធ្យម

៣. ការវិភាគ និងតាមដានច្រវ៉ាក់នៃផលិតផលរយៈពេល ៥ ឆ្នាំទៅមុខទៀត

### សំនួរ និងចំលើយ

Q. **តើសំរាប់សកម្មភាពថ្មីដែលប្រើពាក្យថាច្រវ៉ាក់ផលិតផល (chain products) នោះមានន័យដូចម្ដេច?**

- គឺការពិនិត្យមើលពីដំណើការផលលិតផលដែលគេត្រូវការជាបន្តបន្ទាប់គ្នាសំរាប់ថ្ងៃអនាគត ហើយដើម្បីផ្ដល់ពតិមានមកអង្គការដែលធ្វើសកម្មភាពផលិតផល ។
- ការធ្វើនេះយើងត្រូវពិនត្យមើលពីឱកាសដែលមានសក្ដានុពលរបស់ឧស្សាហកម្មផងដែរ ទើបយើងអាចទទួលបានផលល្អ ។

បន្ទាប់មកមានការពិភាក្សាពីបញ្ហាអនុគណៈកម្មការ និងការកំនត់សមាជិកបន្តទៀតដើម្បីធ្វើការសំរេចចិត្ត ។ ចំពោះបញ្ហាអនុគណៈកម្មការថា តើគួរសំរេចទុកចំនួនប៉ុន្មាននោះ ចុងក្រោយសំរេចយកអនុគណៈកម្មការចំនួន៣ ។ ចំពោះហេតុផលនៃការកាត់បន្ថយអនុគណៈកម្មការនេះ គឺដោយសាអនុគណៈកម្មការមួយមិនមានអ្នកដឹកនាំច្បាស់លាស់ ព្រោះអ្នកដឹកនាំគាត់បានលាឈប់ទៅហើយ ហើយការងារនោះតែងតែមានការរអាក់រអួល ដូចនេះយើងបានដាក់អនុគណៈកម្មការនេះចូលទៅក្នុងអនុគណៈកម្មការមួយទៀត ដើម្បីអោយមានការគ្រប់គ្រងត្រឹមត្រូវ ។ ទោះជាអនុគណៈកម្មការនៅសល់ចំនួនតែ ៣ ក៏ដោយក៏សកម្មភាពនៅតែរក្សាដូចដើមគឺ ៤ សកម្មភាពដដែល ។

### សំណូមពរ:

**លោក ឃឹម ប៉ូះ** សូមអោយអនុគណកម្មការមួយ មានសមាជិកសំខាន់ Key member មួយនៅក្នុងនោះហើយអនុគណៈកម្មការត្រូវជ្រើសរើសឡើងក្នុងជួរ សមាជិកសំខាន់នោះដែរ ។

**លោក អ៊ុំ រតនា:** លោកបានធ្វើសេចក្តីសង្ខេបលើសេចក្តីសំរេចចិត្តដូចខាងក្រោមៈ

ការកំនត់ចំនួនសមាជិកក្នុងគណកម្មការនិមួយៗត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត ហើយមានចំនួនចាប់ពី ៣ ទៅ ៧ នាក់ ហើយសមាជិកមិនអាចមានចំនួនតិចជាង ៣ នាក់នោះទេ ព្រោះបើមានតែ ២ ក្នុងករណីម្នាក់អវត្តមាន មានសមាជិកតែម្នាក់ប៉ុណ្ណោះ មិនអាចធ្វើការប្រជុំបានឡើយ។

**លោក សុខ សំអឿន:** ចំពោះអ្នកដែលនៅខេត្តប្រហែលជាមានការលំបាកនៅក្នុងការចូលរួមប្រជុំ ព្រោះគាត់នឹងមិនមានថវិការគ្រប់គ្រាន់សំរាប់ធ្វើដំណើរមកចូលរួមប្រជុំនោះទេ។

**លោក ទូន វិចិត្រ:** ចំពោះការចូលរួមនៅក្នុងអនុគណកម្មការ បើអង្គការដាក់ពាក្យសុំចូលនៅក្នុងអនុគណៈកម្មការណាមួយមានចំនួនលើស យើងអាចធ្វើការសុំយោបល់ពីគាត់អោយគាត់ចូលទៅជាមួយក្រុមណាដែលមានសមាជិកតិចវិញ។

## ការបិទកម្មវិធី

លោក ទូន វិចិត្រ អ្នកសំរបសំរួលសម្ព័ន្ធអង្គការកូសេកាំ បានធ្វើការប្រកាសបិទកម្មវិធី។ មុនពេលបិទអង្គប្រជុំលោក ទូន វិចិត្រ ធ្វើការសង្ខេបពីអ្វីដែលយើងបានធ្វើការនៅថ្ងៃចុងក្រោយ។ លោកបានបញ្ជាក់ថាតើសកម្មភាពដែលអង្គការកូសេកាំ និងអង្គការនិមួយៗបានធ្វើមកបានល្អដែររឺទេ អចិតិជនរបស់យើងគាត់មានការពេញចិត្តរឺនៅបានលទ្ធផលកំរិតណា ហើយយើងគួរធ្វើអ្វីតទៅទៀត។

លោកបានធ្វើការថ្លែងអំណរគុណដល់អ្នកដែលបានចូលរួមទាំងអស់ និងធ្វើការគោរពជូនពរដល់សមាជិកចូលរួម។ តែមុននឹងបញ្ចប់លោកសូមធ្វើការបញ្ជាក់ពីអ្នកដែលចង់ចូលរួមធ្វើការពិភាក្សាលំអិតពីពាក្យថា មណ្ឌល (constituency) ដើម្បីអោយមានការយល់ដឹងអោយកាន់តែច្បាស់លាស់ថែមទៀត តែដោយសមាជិកមួយចំនួនគាត់មានការរវល់ ហើយគាត់ត្រូវធ្វើដំណើរទៅមុន ដូចនេះសមាជិកសម្ព័ន្ធ កូសេកាំទាំងអស់បានសំណូមពរអោយលើកការពិភាក្សាពីពាក្យមណ្ឌលនោះទៅធ្វើការពិភាក្សានៅក្នុងកិច្ចប្រជុំនៅពេលក្រោយដើមឆ្នាំ ២០០៥។

កិច្ចប្រជុំប្រចាំឆ្នាំរបស់សមាជិកសម្ព័ន្ធកូសេកាំត្រូវបានបញ្ចប់នៅវេលាម៉ោង ១ និង ៤៥នាទី ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៤ ដោយទទួលបានលទ្ធផលល្អប្រសើរ និងបានប្រព្រឹត្តិទៅតាមកាលវិភាគដែលបានគ្រោងទុក។

# បញ្ជីឈ្មោះ
# អ្នកដែលបានចូលរួមនៅក្នុងសិក្ខាសាលាប្រចាំឆ្នាំ
# នៅសណ្ឋាគារប្រាសាទមាស ក្រុងព្រះសីហនុ
# ថ្ងៃទី ១៧-២១ ខែធ្នូ ឆ្នាំ ២០០៤

| ល.រ | ឈ្មោះ | ភេទ | អង្គការ | តួនាទី | ទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | សុក សំអឿន | ប | CDP | នាយកប្រតិបត្តិ | ០១២ ៩០១ ១៩៩ |
| ២ | ណុប ណាត | ប | KNKS | អ្នកសំរបសំរួល | ០៩២ ៨១៥ ៤៤០ |
| ៣ | ប៊ូ វរសាក់ | ប | WP | រដ្ឋបាល | ០១២ ៩១៣ ៥៣២ |
| ៤ | ប៉ុក ប៊ុណ្ណា | ស | KnK | បុគ្គលិកសង្គម | ០១២ ៧៣១ ៧៩៣ |
| ៥ | ម៉ី ចាន់វាសនា | ប | PJJ | អ្នកស៊ើបអង្កេត | ០១២ ៨០៤ ២៣៩ |
| ៦ | គឹម នារត្ន័ | ស | KMR | អ្នកគ្រប់គ្រង | ០១២ ៣៧០ ៨៩៧ |
| ៧ | ព្រឿង សារុន | ប | CCHDO | អ្នកសំរបសំរួល | ០១២ ៩៧១ ០២៤ |
| ៨ | ទី លីហេង | ប | ADHOC | អ្នកត្រួតពិនិត្យ | ០១១ ៧៤១ ៩២២ |
| ៩ | កែវ សារ៉ាវុធ | ប | AK | អ្នកសំរបសំរួល | ០១២ ២៩២ ៦១០ |
| ១០ | ម៉ែន សំណាង | ប | CAMP | ជំនួយការគំរោង | ០១២ ៩៨២ ២២៧ |
| ១១ | ភោគ ប៊ុនរឿន | ប | CCASVA | នាយកប្រតិបត្តិ | ០១២ ៨៨៨ ៦១៣ |
| ១២ | ឈូក ស៊ីថន | ស | CWDA | បុគ្គលិកផ្នែកពត៌មាន | ០១១ ៨៥៣ ៥១៤ |
| ១៣ | យឹម ប៊ូ | ប | CCPCR | នាយកប្រតិបត្តិ | ០១២ ៩៦៧ ៣៨៥ |
| ១៤ | សឿម វណ្ណា | ប | WVC | អ្នកសំរបសំរួលគំរោង | ០១២ ៩៤៨ ៨០៥ |
| ១៥ | សម និស្ស័យ | ប | LSCW | ជំនួយការផ្នែកច្បាប់ | ០១១ ៨១៦ ៤៩៧ |
| ១៦ | សៀ ស៊ុវិទ្យា | ស | COSECAM | មន្ត្រីកម្មវិធី ស្តារនីតិសម្បទា និងសមាហរណកម្ម | ០១២ ៤១៥ ៨០៨ |
| ១៧ | ស៊ុន វីរៈ | ប | HCC | អ្នកសំរបសំរួល ផ្នែកកិច្ចបង្ការទប់ស្កាត់ | ០១២ ៨៨៦ ៨៥៩ |
| ១៨ | ង៉ែត សុភាព | ប | COSECAM | ជំនួយការរដ្ឋបាល | ០១២ ៤៤១ ១០៤ |
| ១៩ | ទូន វិចិត្រ | ប | COSECAM | ប្រធានសំរបសំរួលសម្ព័ន្ធ | ០១២ ៩៦១ ៥៦៥ |

| | | | | | |
|---|---|---|---|---|---|
| ២០ | កៅ សុខដែត | ស | **COSECAM** | ជំនួយការកម្មវិធី ស្រាវជ្រាវ | ០១២ ៩៣៣ ១៣៥ |
| ២១ | អ៊ុំ រតនា | ប | **COSECAM** | មន្ត្រីកម្មវិធី អភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស | ០១២ ៣០៩ ៧០៧ |
| ២២ | ហ៊ួត សុវណ្ណារី | ស | **COSECAM** | ទីប្រឹក្សាកម្មវិធី តស៊ូមតិ | ០១២ ៩៧០ ៧០៤ |
| ២៣ | ព្រុំ ផលឌីន | ស | **COSECAM** | បុគ្គលិកស្ម័គ្រចិត្ត | ០១២ ៤៥៦ ៩៣៥ |
| ២៤ | យី សុខសាន្ត | ប | **PLAN** | ទីប្រឹក្សា | ០១២ ៨៧៧ ៩៧៥ |
| ២៥ | ខ្លូង ឌឹម | ប | **Sunrise** | អ្នកកត់ត្រា | ០១១ ៩២៤ ០១២ |
| ២៦ | អ៊ុំ មុំម៉ារី | ស | **COSECAM** | ជំនួយការគណនេយ្យ | ០១២ ៩២៧ ៧៧៨ |
| ២៧ | **John Vijghen** | ប | **COSECAM** | ទីប្រឹក្សា | ០១២ ៨៨៩ ៦២១ |
| ២៨ | កែម សម្បត្តិ | ប | **COSECAM** | | ០១២ ៨២៣ ២២២ |
| ២៩ | ម៉ៅ វណ្ណះ | ប | **COSECAM** | អ្នកបើកបរ និងរត់សំបុត្រ | ០១៦ ៧១២ ៤៣៤ |
| ៣០ | អ៊ិន ចំណូ | ប | **CHO** | អ្នកសំរបសំរួល | ០១២ ៨៣២ ៥០០ |
| ៣១ | មាស ស៊ុនសារ៉ាវុធ | ប | **SCCO** | នាយកប្រតិបត្តិ | ០១២ ៤៣៤ ៣០៣ |
| ៣២ | សម សុវណ្ណារិទ្ធ | ប | **Goutte D’eau** | នាយក | ០១២ ៩៨៥ ៣៨៤ |

**ឧបសម្ព័ន្ធ A**

# កាលវិភាគស្តីពីកម្មវិធី សំរាប់កិច្ចប្រជុំសមាជិកសម្ព័ន្ធអង្គការ កូសេកាំ នៅក្រុងព្រះសីហនុ ១៨-២១ ខែ ធ្នូ ២០០៤

## ថ្ងៃទី១: ថ្ងៃសៅរ៍ ទី ១៨ ខែធ្នូ ឆ្នាំ ២០០៤

| | |
|---|---|
| ០៨: - ០៨:១៥ | កិច្ចស្វាគមន៍ ព្រមទាំងការណែនាំអំពីកម្មវិធីប្រជុំ ដោយលោកតំណាងគណៈកម្មាការនាយក |
| ០៨:១៦-១០:០០ | ការបង្ហាញ និងពិនិត្យទៅលើការសំរេចបានរបស់កម្មវិធី បង្ហាញដោយ អ្នកសម្របសម្រួល និង មន្ត្រីកម្មវិធីសម្ព័ន្ធ |
| ១០:០១-១០:១៥ | សួរបញ្ជាក់, សំនួរ និង ចំលើយ |
| ១០:១៦-១០:៤០ | សំរាក |
| ១០:៤១-១២:០០ | បញ្ហារបស់អនុគណៈកម្មការ: បញ្ហា និង រកវិធីសាស្រ្តធ្វើឱ្យប្រសើរឡើង |
| ១២:០១-១៤:០០ | អាហារថ្ងៃត្រង់ |
| ១៤:០១-១៤:២០ | ការបង្ហាញ អំពី ទស្សនៈរបស់មណ្ឌល, បង្ហាញដោយ លោក ចន វីហ្គេន |
| ១៤:២១-១៤:៣០ | សំនួរ និង ចំលើយ |
| ១៤:៣១-១៤:៥០ | បង្ហាញស្តីពីការប៉ាន់ប្រមាណលើមណ្ឌល ដោយកញ្ញា សុវណ្ណានារី និងសម្របសម្រួលដោយ លោក ប៉ុល ហំម |
| ១៤:៥១-១៥:០០ | សំនួរ និង ចំលើយ |
| ១៥:០១-១៦:០០ | ពិភាក្សាតាមក្រុមតូច ចែកចេញជា៣ក្រុម- រួមបញ្ចូល ការសំរាកពិសារអាហារសំរន់: **សំនួរនាំមុខ** <br>● តើកត្តាសំខាន់ៗអ្វីខ្លះ ដែលជាទស្សនៈរបស់មណ្ឌល? <br>● ទ្រឹស្តី និង ការអនុវត្តន៏ផ្ទាល់ <br>● សំនើរ និង អនុសាសន៏នានា |
| ១៦:០១-១៧:០០ | ការបង្ហាញតាមក្រុមតូចៗ ព្រមទាំងមាន សំនួរ និង ចំលើយ |

## ថ្ងៃទី២: ថ្ងៃអាទិត្យ ទី ១៩ ខែធ្នូ ឆ្នាំ ២០០៤

០៨:០០-១០:០០ យុទ្ធសាស្ត្រសំរាប់ឈានដល់ការបង្កើតមណ្ឌល, សម្របសម្រួលដោយ លោក: ប៉ុល ហំម

- មណ្ឌល
- ការគាំទ្រផ្នែកច្បាប់
- សិទ្ធិមនុស្ស
- ជំនួយអភិវឌ្ឍន៏កុមារ

១០:០១-១០:៣០ សំរាក

១០:៣១-១២:០០ ដាក់អាទិភាព នៃយុទ្ធសាស្ត្រ, ធ្វើការសង្ខេប និងធ្វើការប្តេជ្ញាចិត្តចំពោះមណ្ឌល

១២:០១-១៤:០០ សំរាក

១៤:០១-១៥:០០ បញ្ហាសមាជិកភាព

- ប្រព័ន្ធ , ផ្នែក: សមាជិកសកម្ម និង សមាជិកចូលរួម
- កំរិត នៃការចូលជាសមាជិក
- និតិវិធីនៃការដាក់ពាក្យចូលជាសមាជិក

១៥:០១-១៥:៣០ ការបង្ហាញដោយអង្គការសុំចូលជាសមាជិកនីមួយៗ (សមាជិក ២នាក់): សំនួរ និង ចំលើយ រួមសមាជិកទាំងអស់ធ្វើសេចក្តីសំរេចចិត្ត តាមការបោះឆ្នោតជាសំងាត់។

១៥:៣១-១៥:៤៥ សំរាក

១៥:៤៦-១៧:៣០ ការបង្ហាញដោយអង្គការសុំចូលជាសមាជិកនីមួយៗ (សមាជិក៣នាក់): សំនួរ និង ចំលើយ រួមសមាជិកទាំងអស់ធ្វើសេចក្តីសំរេចចិត្ត តាមការបោះឆ្នោតជាសំងាត់។

## ថ្ងៃទី៣: ថ្ងៃច័ន្ទ ទី ២០ ខែធ្នូ ឆ្នាំ ២០០៤

### កម្មវិធីសំរាប់ឆ្នាំ ២០០៥

០៨:០០-០៩:០០ ទស្សនៈទូទៅ

០៩:០១-១១:២០ ការពិភាក្សាក្រុម តាមកម្មវិធីនីមួយៗ: អភិវឌ្ឍន៏ស្ថាប័ន និងអភិវឌ្ឍន៏ធនធានមនុស្ស, ការស្តារនីតិសម្បទា និងសមាហរណកម្ម, តស៊ូមតិ, និងកម្មវិធីស្រាវជ្រាវ

- សំរាក

១១:២១-១២:០០ ការបង្ហាញរបស់ក្រុមផ្នែកកម្មវិធីស្តារ និងសមាហរណកម្ម ព្រមទាំងមានសំនួរ-ចំលើយ

១២:០១-១៤:០០ សំរាក

១៤:០១-១៤:៤០ ការបង្ហាញរបស់ក្រុម ផ្នែកអភិវឌ្ឍន៏ស្ថាប័ន និងអភិវឌ្ឍន៏ធនធានមនុស្ស ព្រមទាំងមានសំនួរ-ចំលើយ

១៤:៤១-១៥:២០ ការបង្ហាញរបស់ក្រុម តស៊ូមតិ ព្រមទាំងមានសំនួរ និង ចំលើយ

១៥:២១-១៥:៤០ ការសំរាក

១៥:៤១-១៦:២០ ការបង្ហាញរបស់ក្រុម ស្រាវជ្រាវ ព្រមទាំងមានសំនួរ និង ចំលើយ

១៦:២១-១៦:៣៥ ធ្វើការសន្និដ្ឋាន និង បិទវគ្គសិក្ខាសាលា ដោយលោកៈ សុខ សំអឿន, ប្រធានគណៈកម្មការនាយក

**ថ្ងៃទី៤: ថ្ងៃ អង្គារ ទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤**

**ពេលព្រឹក** ដំណើរកំសាន្ត

**ពេលល្ងាច** ធ្វើដំណើរមកភ្នំពេញវិញ

## ឧបសម្ព័ន្ធ B

# សញ្ញាណអំពី មណ្ឌល សំរាប់អង្គការក្រៅរដ្ឋាភិបាល

កម្ពុជាគឺ ក្នុងចំណោមប្រទេសនានាដែលនិយមការបោះឆ្នោតក្នុងការរៀបចំរដ្ឋសភា តាមរយៈគណៈបក្សនយោបាយ។ នៅក្នុងផ្នែកនេះបង្ហាញថា កម្ពុជាគឺ មានលក្ខណៈប្រជាធិតេយ្យ។ សមាជិកសភា តំណាងឱ្យអ្នកបោះឆ្នោត តាមខេត្ត ដែលគេបានឈរឈ្មោះជាបេក្ខជន។ ក្រុមសន្លឹកឆ្នោតនេះ បង្កើតបាននូវមណ្ឌលនៃសមាជិកសភាដែលបានជ្រើសរើស។ គាត់ជាអ្នកឆ្លើយតប និងទទួលខុសត្រូវដល់ម្ចាស់ឆ្នោតទាំងនេះ។ គាត់គឺ ត្រូវតែតំណាងឱ្យទស្សនៈ និងធ្វើសមកម្មភាពក្នុងនាមម្ចាស់ឆ្នោតទាំងអស់នោះ។

## ស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល

នាយក និងបុគ្គលិកដែលកំពុងធ្វើការជាអង្គការសង្គមស៊ីវិល ក្នុងចំណោម NGOs ជាទូទៅគឺ មិនត្រូវបានគេបោះឆ្នោតដោយក្រុមដែលគេតំណាង និងធ្វើការងារក្នុងនាមពួកគេនោះទេ។ មានការលើកលែងដ៏តិចតួចក្នុងប្រទេសកម្ពុជា ឧទាហរណ៍: អង្គការ ADHOC។ អង្គការនេះគឺ ជាសមាគម ហើយសមាជិកជាអ្នកបោះឆ្នោតជ្រើសរើសប្រធាន និងអគ្គនាយក។ កំឡុងពេលប្រជុំ ប្រធានទទួលខុសត្រូវនឹងឆ្លើយតបលើអ្វីដែលគាត់ និងបុគ្គលិករបស់គាត់ធ្វើពីមុន។ ប៉ុន្តែក៏ដូចជា NGOs ដទៃទៀតដែរ ដែលមានក្រុមផ្សេងទៀត ដែលគេទទួលខុសត្រូវគឺ ក្រុមគោលដៅរបស់គេ ឬអតិថិជន ឬក្រុមគាំទ្រ ឬសំរាប់សកម្មភាពរបស់ NGOs ដែលគេធ្វើ។ មានឧទាហរណ៍ជាច្រើនរបស់ ណអឿស ដែលមានគោលបំណងជៀសវាងមិនមានការទទួលខុសត្រូវ ដោយក្រុមមួយដែលគេធ្វើសកម្មភាពសំរាប់ ឬអ្នកណាដែលពួកគេតំណាងឱ្យ។ មណ្ឌលនេះគឺ មានទំរង់បែបនេះ។ ប៉ុន្តែអង្គការសង្គមស៊ីវិល ដូចដែលយើងបានដឹងក្នុងប្រទេសកម្ពុជា គួរតែមានការទទួលខុសត្រូវដល់ក្រុមគោលដៅ ឬក៏អ្នកណាដែលតំណាងឱ្យពួកគេ។ តើនេះជាការពិតទេ? បាទ. ជាការពិត តែតើនរណាដែលជាម្ចាស់គំនិត។

## តើត្រូវទទួលខុសត្រូវទៅដល់អ្នកណាខ្លះ?

អង្គការសង្គមស៊ីវិលទាំងអស់ ត្រូវតែមានការទទួលខុសត្រូវសំរាប់អ្វីដែលគេធ្វើ។ នេះគឺ ជាក្រមសីលធមិសំរាប់អង្គការគ្រប់ប្រភេទ។ សំនួរសួរថា តើមានការទទួលសុខត្រូវទៅអ្នកណា? សំនួរទី១គឺ ខ្ញុំអាចឆ្លើយបានយ៉ាងងាយ ប៉ុន្តែខ្ញុំមិនមែនជាអ្នកដែលសំរេចនូវលើរឿងនេះទេ។ វាជារឿងរបស់អ្នកទាំងអស់គ្នាជាអ្នកគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវកំណត់ថា តើមណ្ឌលរបស់អ្នកត្រូវមានលក្ខណៈយ៉ាងដូចម្តេច។ តើវាជាសមាជិកភាពរបស់អ្នកឬ? ឧទាហរណ៍ កូសេកាំ គឺជាសម្ព័ន្ធមួយ ជាអង្គការដែលមានសមាជិកភាពមួយ។ ដូច្នោះយើងធ្វើសកម្មភាពក្នុង

នាមសមាជិក។ ជាការពិតណាស់ ដូច្នេះយើងគួរតែមានការទទួលខុសត្រូវសំរាប់អ្វីដែលយើងធ្វើចំពោះសមាជិករបស់យើង។

ប៉ុន្តែសមាជិករបស់យើង តើនរណាដែលគេគួរតែពន្យល់អំពីអ្វីដែលគេធ្វើ ហើយហេតុអ្វី? ឧទាហរណ៍ តើក្រុមអតិថិជននៅក្នុងមណ្ឌលគិតថា វាជាមណ្ឌលរបស់គេដែរឬទេ? បាទ, ខ្ញុំគិតថា វាដូច្នោះហើយ។ ប៉ុន្តែមានអ្នកផ្សេងៗទៀតដែលមិនយល់ស្រប។ នេះជារឿងមួយសំរាប់លើកមកពិភាក្សា។ សំនួរសួរថា បើសិនជាអតិថិជនមានភាពវ័យក្មេង តើពួកគេមានការយល់ដឹងដូចម្តេចទៅ? នៅក្នុងករណីនេះ មណ្ឌលត្រូវតែមានការទទួលខុសត្រូវចំពោះអ្នកថែទាំកុមារទាំងអស់នោះ។

តើក្រុមគោលដៅ ដែលគណៈកម្មាការព្រឹត្តិកម្មពុះពារបង្កើតនោះ វាជាមណ្ឌលឬ? ក្នុងទស្សនះរបស់គឺបាទ! ប៉ុន្តែគួរតែ គណៈកម្មាការព្រឹត្តិកម្មនេះទទួលខុសត្រូវចំពោះកុមាររងគ្រោះទាំងនេះឬ? ចំលើយគឺ បាទ និងអត់ទេ។ ខ្ញុំគិតថា ទោះបីជាគណៈកម្មាការព្រឹត្តិកម្មធ្វើសកម្មភាពក្នុងនាមតំណាងឱ្យក្រុមអ្នករងគ្រោះក៏ដោយ ដូចនេះទំនួលខុសត្រូវគឺ ត្រូវតែទទួលខុសត្រូវដោយសមាជិកម្នាក់ៗផ្ទាល់របស់គណៈកម្មាការព្រឹត្តិកម្ម។ វាដូចជានៅក្នុងសភាដែរ ក្រុមសមាជិកសភាទាំងអស់តំណាងឱ្យប្រជាពលរដ្ឋ ប៉ុន្តែសមាជិកសភាម្នាក់ៗត្រូវតែមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់គាត់ ចំពោះមណ្ឌលផ្ទាល់របស់គេនៅកន្លែងបោះឆ្នោតផ្ទាល់តាមខេត្ត។

## តើទទួលខុសត្រូវសំរាប់អ្វីខ្លះ?

បើសិនជាយើងទទួលស្គាល់ថា អង្គការរបស់យើងមានមណ្ឌល ដែលមានសិទ្ធិដឹងពីអ្វីដែលយើងធ្វើសំរាប់ពួកគេ ហើយថា វាផ្តល់សិទ្ធិឱ្យពួកយើងក្នុងការទទួលខុសត្រូវ។ សំនួរសួរថា តើយើងត្រូវទទួលខុសត្រូវទៅលើអ្វី? តើសកម្មភាព និងរឿងអ្វីដែលគួរតែពន្យល់ទៅដល់ក្រុមគោលដៅរបស់យើង ឬក្រុមដែលយើងតំណាងឱ្យ? ខ្ញុំគិតថា បញ្ហាគ្រប់គ្រង និងចាត់ចែងអង្គការ វាពុំសូវមានចំណាប់អារម្មណ៍នោះទេ សំរាប់មណ្ឌលរបស់យើង។ សំរាប់បញ្ហាទាំងនេះគឺ យើងត្រូវមានការទទួលខុសត្រូវទៅក្រុមប្រឹក្សាភិបាល ឬក៏គណៈកម្មាការនាយក។ ទេ, វាជាសកម្មភាព របស់យើងដែលយើងត្រូវធ្វើក្នុងនាមតំណាងឱ្យ ឬមណ្ឌលដែលយើងទទួលខុសត្រូវចំពោះ ហើយវាជាកម្មវិធី ដែលយើងត្រូវតែពិភាក្សាជាមួយក្រុមគោលដៅរបស់យើងដែលយើងតំណាងឱ្យ។ អ្វីដែលយើងគួរតែពិភាក្សា និងធ្វើការសំរេចដោយមណ្ឌលរបស់យើងនេះ វាមិនមែនងាយស្រួលនោះទេ។ ឧទាហរណ៍ តើយើងគួរធ្វើតាមអ្នកចូលរួមនៃវគ្គបណ្តុះបណ្តាលមួយដែលយើងគួរតែផ្តល់ឱ្យ នៅពេលដែលគេសុំប្រាក់ឧបត្ថម្ភក្នុងតំលៃខ្ពស់ដែរឬទេ? ទេ, ជាការពិតណាស់ វាពុំមែនជាបញ្ហានៅក្នុងការគ្រប់គ្រង និងការចាត់ចែងអង្គការ ដែលជាបញ្ហាគេគួរតែពិគ្រោះនោះទេ ប៉ុន្តែវាជាបញ្ហាដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ពួកគេ ក្នុងការធ្វើសេចក្តីសំរេចចិត្តឱ្យច្បាស់លាស់នោះ វាទាមទារឱ្យមានការពិភាក្សាឱ្យបានទូលំទូលាយ។

## គោលបំណងនៃសិក្ខាសាលា

គោលបំណងមួយនៃសិក្ខាសាលានេះគឺ ដើម្បីសំរេចចិត្តនូវបញ្ហាអ្វី ដែលមណ្ឌលរបស់យើងគួរតែពិភាក្សាគ្នា? ប៉ុន្តែទី១ គឺ ត្រូវមានការយល់ព្រមជាទូទៅមួយសិនលើសញ្ញាណនៃមណ្ឌលរបស់អង្គការក្រៅរដ្ឋាភិបាល ។

## តើអង្គការក្រៅរដ្ឋាភិបាល ត្រូវមានការទទួលខុសត្រូវចំពោះមណ្ឌលដែរឬទេ?

នៅពេលដែលមានការយល់ព្រមជាគោលការណ៍ នោះគេនឹងអាចពិភាក្សាលើបញ្ហាផ្សេងៗទៀតដូចជាៈ

- ❖ តើនរណាដែលជាអ្នកបង្កើតមណ្ឌលពិតប្រាកដ?
- ❖ បើសិនជាពួកគេនៅក្មេង ឬក៏ពុំបានទទួលការអប់រំ ឬអ្នកដែលគេមិនយកចិត្តទុកដាក់ តើអ្នកណាជាអ្នកតំណាងឱ្យពួកគេ?
- ❖ តើគួរតែគិតទៅលើបញ្ហាអ្វីខ្លះ?
- ❖ បើសិនជាមណ្ឌលរបស់យើងពុំមានការយល់ព្រមជាមួយសកម្មភាពរបស់យើង តើយើងគួរតែធ្វើយ៉ាងដូចម្តេច?
- ❖ តើធ្វើយ៉ាងដូចម្តេច ហើយនៅពេលណាទើបយើងធ្វើការពិគ្រោះអំពីមណ្ឌលរបស់យើង?

**រៀបចំដោយៈ លោក ចន វិហ្គេន, ទីប្រឹក្សា**

## ឧបសម្ព័ន្ធ C

**DISCUSSION PAPER on**
**COSECAM PROGRAM from YEAR 2005 Onwards**

**INTRODUCTION**

This paper aims to guide the discussion about the Year 2005 Program by the Delegate meeting (Retreat) in December 2004. A Previous version of this paper was presented and endorsed by the Steering Committee early December 2004. There are a number of considerations to keep in mind while discussing the issue:

- Office and personnel budget is fixed, due to commitments (office rent, salaries, etc)
- Core program budget is open for adjustment, but a number of activities are essential in order to achieve the objectives (e.g. Child Participation in Planning project needs to organize meetings and exchanges between group of victim children)
- Core sponsors support the current program developed for the period 2004-2006 and major changes will need to get their endorsement.

**CONSOLIDATION**

The coming year will be a period for further consolidation of the coalition in terms of partnerships with sponsors, relationship with government and international agencies, and implementing the core projects. Member organizations will be encouraged to collaborate more in joint projects. Especially special projects can better be implemented by some member organizations, while the Secretariat coordinates adn handles the reporting tasks.

The Tour and National Conference were good examples of membership joint efforts. During its presentation at the Mid-Term Review in Bangkok last November, the CNCC cited frequently the output of the national conference. This indicates that the government endorses much of the recommendations of the NGOs. However, there is still no new national plan of action drafted by the CNCC. A consultant recruited by UNICEF is currently in the process of facilitating the drafting of the new plan of action. The target for completion of the new PoA is set for mid-year 2005.

This means that there will be ample opportunity for NGOs to continue their efforts to include their point of view in the national plan of action. The coalition through its Integrated Child Issue Program (ICP) will continue to advocate for inclusion of the NGO point of view in the new national PoA on Trafficking of Women and Children. We propose the following action:

- After the broad consultation throughout the country (Tour, Provincial Workshops, and National Conference) the best strategy for continuation of our efforts to assure inclusion of the NGO views in the national PoA to work together with the UNICEF consultant and directly with the CNCC. Recruitment of a short-term consultant with legal expertise should be considered for this purpose. Further, leaders of relevant NGOs should be involved through brainstorming sessions to give their more specific and expertise input to the draft PoA on Trafficking of Women and Children.

## MANDATE AND ROLE

Three years have past since the formation of the coalition on 16 November 2001 and the original mandate ans role of the coalition has been evolved. The focus has shifted to program and policy development (advocacy) on a provicial and national level for a broader target group. Nationwide consultation and national level conferences, after provincial consultations have become the instruments for improving NGO programming and input to national plans of action. Representation of COSECAMmembers and secretariat staff in national and international events has also become a practise. Although this is part of the mandate it was not described as a role for the coalition at its inception.

Members of the coalition and thus the coalition itself include sexually and in other ways exploited or abused children in their target group. Although sexual exploited children were described as the sole target group at the inception of the coalition this is not anymore solely the case. This shift to include non-sexual exploited or abused children in the target group has been endorsed by the Steering Committee and will become practice unless Delegates object.

## EXPANSION ACTIVITIES

The coming year should also be a period of expansion in terms of special projects in new directions. Member organizations are invited to support and become involved in the plans endorsed by the Steering Committee in their meeting early December 2004 and by the Chairman of the Steering Committee during the Retreat on 18 December 2004:

- **Child Protection Regulation:** in most developed countries exist a *national council for the child* that sets rules for organizationa and individuals how to treat children in their care or when to become a guardian, or to take action in cases of wrongdoing. Although a national council for children (CNCC) exists, this issue is not taken up by that body. We propose a project that "explores" how to get a broad support for and what to do to establish a Child Protection Council with members from all sectors of society. The exploration should include a discussion on what agency should host the council, who should be the members, what should be the mandate and where to get financial support. The coalition is in a good position to initiate this process. Propose is that the first activity will be the set-up of a working group for the issue of parental power.

    - ***Working Group on Temporary Parental Power***

      We propose to establish from among the members of the coalition a small working group to address the issue of parental power in cases was children are abused and those who have parental power are involved, take no action or are not traceable. This is often the case for clients in recovery centres. The working groups' main task will be to develop an action plan for establishing procedures and mechanisms to transfer parental power temporarily to organizations that protect and care for abused children. The working group should also organise a workshop or seminar to get the plans. Cambodian Defenders Project has offered to be the lead agency. The Child Advocacy Unit of the coalition will facilitate the process.

- **<u>Monitoring interventions to address trafficking and exploitation of children</u>:** the recent National Conference on Strategies to Combat Trafficking of Children, organised by COSECAM and ECPAT-Cambodia has shown that no organisation or group has monitored in a comprehensive and effective manner interventions by government, IOs, NGOs or other group to address trafficking and (sexual) exploitation of children over the past four years. Such monitoring is essential in order to fill gaps or avoid overlap, and to identify the most effective strategies. The coalition has the mechanisms in place to monitor interventions by IOs and NGOs. Because the government is still not very active it would be difficult to include government activities in the monitoring. We propose to initiate a project for this purpose.

    - ***Monitoring Interventions that Address Trafficking & Exploitation of Children and Young Women***

      The first act should be the establishment of a working group from among the membership. One member of the coalition should take the lead supported by the Secretariat. The first phase (year 2005) should include an "exploration" of how to get a broad support, with what agencies or group to collaborate, the design of a monitoring plan and the initiation of a pilot project. The working group should organise a workshop or seminar to get broad support in civil society and from government agencies for the monitoring plans. These plans should be implemented till the new national plan of action on TWC expires in year 2009.

- **<u>Victim of Exploitation Coordinated Case Management</u>:** Victims of trafficking and exploitation in Cambodia are assisted by many organizations. These organizitions each have their strengths and weaknesses, and each has a limited capacity to accept and assist victims. Because victim assistance is not nationally coordinated some victims do not get assistance by anyone, some victims do not receive the services they need (psycho-social counseling, education, training etc.) could be and some victims are "exploited" by agencies that claim to advocate for their interests. The coalition is in the position and has the mandate to facilitate proper coordination of victim support. Contacts were made with a project in northern Thailand (TraffCord) in which NGOs, Government Agencies and Police cooperate to coordinate case management of trafficking victims. The project is supported by international organizations, in particular UNICEF, and has the endorsement from high level government officials. We propose to explore opportunities to set-up a similar project taking into account the context in Cambodia.

    - ***Assistance to Trafficking & Abused Children Coordination (ATACC)***

      The first step should be the establishment of a working group from among the membership. One member of the coalition should take the lead supported by the Secretariat. The first phase should include further information gathering about successful projects like Traffcord, an "exploration" of how to get a broad support, with what agencies or groups to collaborate, and the design of an action plan. This should be followed by a workshop or seminar to discuss the plans with stakeholders from civil society, government, police and international agencies.

- **<u>Organisational and Professional Capacity Building</u>:** the coalition has conducted training courses on advocacy, investigation, counseling and project management for program and field staff during the past two years. All members feel that this is an important activity. Global Ministries, one of our core sponsors has offered special financial support for a comprehensive and intensive training program for staff from members organisations to cover trainer fees only. The organising and participant costs are not part of this support.The members need to discuss:
    - <u>Trainer fee support</u>: Whether the coalition will apply for such capacity building support and if yes, in what form (course, on-the-job, workshop, short or long), who should participate (open for non-members? Government staff?), and whether the coalition should proovide financial support to cover travel and living costs to those members that have little HR funds.
    - <u>Training Courses</u>: A number of training courses were organised during the past year (e.g. investigation, management, psycho-social counseling). The psycho-social counseling course will be completed for the current trainees but no new course will be organised because there are now structural opportunities for such training (GTZ-SSC). The membership should discuss what other kind of training courses might be organised for staff of the members.

## COALITION MEMBERSHIP

The coalition has not increased its membership during the past year, partly for procedural reasons and partly because of time constraints. Five more members were accepted in December 2004, all from provinces. The Delegates have finalised the discussion about the system of membership that started January this year and decided to introduce a **key-member and associate membership** during their December meeting. The Steering Committee will decide on regulations, criteria and application procedures for each category, proposed by the Secretariat. The Delegates have also decide *in principle* to accept the levying of membership fees. Specific criteria and regulations will be proposed by the Secretariat and after approval by Steering Committee submitted to each key-member agency for ratification.

## PROPOSED PROGRAM 2005

[normal font: core projects. Underlined: <u>special projects</u>. *Italics: new projects*]

### Advocacy

- Follow-up Year 2005-09 National Plan Exploitation of Children (Campaign cont'd)
- Consensus about priorities and strategies to reduce child exploitation (EPI cont'd)
- Child Advocacy Unit:
    - Rape of Children (RAP cont'd)
    - Child Rights Lobby (PM Lobby cont'd)
    - *<u>Prostitution Regulation (sponsored by CIDA)</u>*
    - *<u>Child Protection Regulation</u>*: year one exploration and Working Group on Temporary Parental Power; year two coordination & implementation.
- *<u>Assistance to Trafficking & Abused Children Coordinator (ATACC):</u>* <u>(Model TraffCord</u>) year one exploration; year two coordination; year three implementation

### Research

- *<u>Monitoring Interventions that address Trafficking & Exploitation of Children and Young Women</u>*

- Data collection Local NGOs (CLO cont'd)
- Demand Factor Study (DFS cont'd): *Impact of Closing Sway Pak*
- Situation Analysis CSEC (SAC cont'd)
- Studies and surveys for Advocacy program

**IHRD**
- Collective programming (Child Issue Programming cont'd)
- Child Participation in Planning (CPP cont'd)
- Program Staff Development (CMT cont'd)
- Center Staff Development (MT cont'd)

**Rehabilitation & Reintegration**
- Victims of Trafficking Scholarship (VTF cont'd)
- *Reintegration Support Coordinator*
- *SME Support Coordinator*
- Follow-up Commodity Chain Analysis

**Coalition Building**
- Corporate Development (cont'd)
- *Member mobilization*
- Memebership development
- *Program Support*

## FINANCIAL AFFAIRS

The Steering Committee approved the program as proposed. The Delegates need to endorse the program or propose adjustment during their December 2004 meeting.

**Proposed Adjustment Budget Calculation**
Current year calculated 88% for the core program (45% Core & Personnel costs and 43% Core Program costs). A proportion of 12% was estimated for special projects subject to funding. For Year 2005 we propose a more efficient form of calculation with less than 60% of the budget for core/personnel and core program costs:
- 28% for Core & Personnel costs
- 30% for Core program activities
- 42% for special projects

The committee or expected core funding for Year 2005 covers fully the Core & Personnel costs and core program costs. The part of the budget for special projects (see underlined projects) has not yet been covered and is subject to requirements by interested sponsors. We will negotiate with potential sponsors for this special project funding.

**Personnel & Core Program Budget**
The Personnel budget will be the approximately the same as for last year, except for salary increases and new positions for the VTF project (increase 8.8%). The core program budget will be similar to last year, except for cost increases and the VTF expansion (23%).

**Proposed Budget 2005**

**Core sponsors**

| | | | | |
|---|---|---|---|---|
| **1.** | **TAF** | **VTF** | **$186,200** | **contract** |
| **2.** | **SKN** | **core** | **- 31,000** | **committed** |
| **3.** | **KIA** | **core** | **- 54,000** | **committed** |
| **4.** | **AJWS** | **core** | **- 15,000** | **expected** |
| **5.** | **Plan** | **core projects** | **- 50,000** | **expected** |
| **6.** | KIA/PSO | staff dev | - 30,000 | optional (payment directly to consultants) |
| **7.** | AJWS | volunteer | - 6,000 | requested (payment directly to vplunteer) |

Total core program funding **$372,200**

**Possible sponsors**

| | | |
|---|---|---|
| 8. EU / AusAid / Plan Int. | - 100,000 | to complement US funding for VTF |
| 9. British Embassy | - 30,000 | child advocacy |
| 10. UN agencies | - 20,000 | research (IOM, ILO, IAP, UNESCO) |
| 11. Canada Fund | - 20,000 | capacity building & advocacy |
| 12. Child Foundations | - 20,000 | special child abuse projects |
| 13. Social banks | - 40,000 | special job creation projects |

Total special project funding **$230,000**

Total aimed at **$603,200**

**BUDGET PROPORTIONS**

**Core & Personnel costs**

Year 2004 budget: $142,460 (45%); estimated Year 2005 budget (26%) $155,000

**Core Program costs**

Year 2004 budget: $134,000 (43%); estimated Year 2005 budget (36%) $217,200

**Extra Project costs**

Year 2004 budget: $ 37,500 (12%); estimated Year 2005 budget (38%) $230,000